អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា
Extraordinary Chambers in the Courts of Cambodia
Chambres Extraordinaires au sein des Tribunaux Cambodgiens

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ
Kingdom of Cambodia
Nation Religion King
Royaume du Cambodge
Nation Religion Roi

---

អង្គជំនុំជម្រះសាលាដំបូង
Trial Chamber
Chambre de Premiere instance

ឯកសារដើម
ORIGINAL/ORIGINAL
ថ្ងៃ ខែ ឆ្នាំ (Date): 06-Dec-2011, 13:00
CMS/CFO: Kauv Keoratanak

**<u>កំណត់ហេតុជាលាយលក្ខណ៍អក្សរនៃកិច្ចដំណើរការនីតិវិធី</u>**

**<u>ជំនុំជម្រះនៅដំណាក់កាលដំបូង</u>**

**<u>សាធារណៈ</u>**

សំណុំរឿងលេខ ០០២/១៩-០៩-២០០៧/អវតក/អជសដ

**ថ្ងៃទី០៥ ខែធ្នូ ឆ្នាំ២០១១**

**ម៉ោង ០៩: ០៣នាទី**

**សវនាការលើកទី៤**

**ចៅក្រមសាលាដំបូង៖**

ចៅក្រម និល ណុន ជាប្រធាន

ចៅក្រម ស៊ីលវៀ ខាតរ៉ាយថ៍
*(Judge Silvia CARTWRIGHT)*

ចៅក្រម យ៉ា សុខន

ចៅក្រម ហ្សង់ម៉ាក ឡាវែន៍
*(Judge Jean-Marc LAVERGNE)*

ចៅក្រម យូរ ឧត្តរា

ចៅក្រម ធូ មណី (បម្រុង)

ចៅក្រម ក្លូឌា ហ្វេនស៍ (បម្រុង)
*(Judge Claudia FENZ)*

**ក្រឡាបញ្ជីសាលាដំបូង៖**

លោក ម៉ាតេអូ គ្រីប៉ា
*(Mr.Matteo CRIPPA)*

លោក ឌុច ផារី

លោក ដាវ អានសាន

កញ្ញា ហ្វៃហ្សា ស៊ូអាគ្រី
*(Ms. Faiza ZOUAKRI)*

**ការិយាល័យសហព្រះរាជអាជ្ញា៖**

លោកស្រី ជា លាង

លោក អាន់ឌ្រូ ខេលី *(Mr.Andrew CAYLEY)*

លោក សេង ប៊ុនឃាង

លោក ឌេល លីសាក់ *(Mr. Dale LYSAK)*

**ជនជាប់ចោទ៖**

លោក នួន ជា

លោក ខៀវ សំផន

លោក អៀង សារី

**មេធាវីការពារជនជាប់ចោទ នួន ជា៖**

លោក សុន អរុណ

លោក ម៉ៃខល ផេសមិន

*(Mr. Michiel PESTMAN)*

លោក អេនឌ្រូ អ៊ីនូហ្ស៊ី

*(Mr. Andrew IANUZZI)*

**មេធាវីការពារជនជាប់ចោទ ខៀវ សំផន៖**

លោក គង់ សំអុន

លោក អាកទួរ វែកគែន

*(Mr. Arthur VERCKEN)*

**មេធាវីការពារជនជាប់ចោទ អៀង សារី៖**

លោក អាង ឧត្តម

លោក ម៉ៃខល កាណាវាស

*(Mr.Michael KARNAVAS)*

**មេធាវីតំណាងដើមបណ្តឹងរដ្ឋប្បវេណី៖**

លោក ពេជ អង្គ

លោកស្រី អេលីហ្សាបេត ស៊ីម៉ុនណូហ្វត

*(Ms. Elisabeth SIMONNEAU-FORT)*

លោកស្រី ម៉ុច សុវណ្ណារី

លោក សំ សុគង់

លោក ប៉ាស្កាល់ អូប៊ីង

*(Mr. Pascal AUBOUIN)*

លោក វ៉ែន ពៅ

លោក ហុង គឹមសួន

លោក គ្រីស្ទីន ម៉ាទីណូ

*(Mr. Chritine MARTINAU)*

**ផ្នែកគ្រប់គ្រងតុលាការ៖**

លោក អ៊ុច អរុណ

## បញ្ជីឈ្មោះអ្នកនិយាយ៖

ភាសាដែលបានប្រើ លើកលែងតែមានការបញ្ជាក់ផ្សេងទៀតនៅក្នុងប្រតិចារឹក

| **អ្នកនិយាយ** | **ភាសា** |
|---|---|
| ចៅក្រម និល ណុន (ប្រធានអង្គជំនុំ) | ខ្មែរ |
| ចៅក្រម ស៊ីលវៀ ខាតវ៉ាយថ៍ | អង់គ្លេស |
| ចៅក្រម ហ្សង់ម៉ាក ឡាវែន៍ | បារាំង |
| លោក អេនឌ្រូ អ៊ីនូហ្វ៊ី | អង់គ្លេស |
| លោក ឌេល លីសាក់ | អង់គ្លេស |
| លោក អាកទួរ វែកគែន | បារាំង |
| ពេជ អង្គ | ខ្មែរ |
| លោកស្រី អេលីហ្សាបេត ស៊ីម៉ុនណូហ្វត | អង់គ្លេស |
| លោក សំ សុគង់ | ខ្មែរ |
| លោក ម៉ៃខល ផេសមិន | អង់គ្លេស |
| លោក អាង ឧត្តម | ខ្មែរ |
| លោក ម៉ៃខល កាណាវាស | អង់គ្លេស |
| លោក សុន អរុណ | ខ្មែរ |
| លោក នួន ជា | ខ្មែរ |
| ក្រឡាបញ្ជី | ខ្មែរ |

# ឧបសម្ព័ន្ធ

## ការសួរសំណួរទៅជនជាប់ចោទ នួន ជា៖

ការតាំងសំណួរដោយចៅក្រម

សួរដោយប្រធានអង្គជំនុំ ផ្តើមពី ........................................ទំព័រ ៣០
សួរដោយចៅក្រម ស៊ីលវៀ ខាតវ៉ាយថ៍ផ្តើមពី ........................................ទំព័រ ៤៩
សួរដោយចៅក្រម ស៊ីលវៀ ខាតវ៉ាយថ៍ផ្តើមពី ........................................ទំព័រ ៦០

# កិច្ចដំណើរការនីតិវិធី

[០៩:០៣:២៣]

**ប្រធានអង្គជំនុំ៖**

សូមអញ្ជើញអង្គុយចុះ!

អង្គជំនុំជម្រះសាលាដំបូងប្រកាសបន្តកិច្ចដំណើរការនីតិវិធីសវនាការលើអង្គសេចក្ដីសំណុំរឿងក្ដីលេខ០០២។ ដូចដែលអង្គជំនុំជម្រះសាលាដំបូងបានជម្រាបជូនភាគី និងសាធារណជនរួចហើយកាលពីថ្ងៃទី២៣ ខែវិច្ឆិកា ឆ្នាំ២០១១ ថា ចាប់ពីថ្ងៃទី០៥ ខែធ្នូ ឆ្នាំ២០១១ នេះតទៅ អង្គជំនុំជម្រះសាលាដំបូងចាប់ផ្ដើមដំណើរការនីតិវិធីសវនាការ ដោយការពិភាក្សាដេញដោលពិនិត្យភស្តុតាងលើសំណុំរឿងក្ដីលេខ០០២។

[០៩:០៥:០០]

**ប្រធានអង្គជំនុំ៖**

លោកឌុច ផារី ឡើងរាយការណ៍អំពីស្ថានភាពវត្តមាន អវត្តមានភាគី និងបុគ្គលដែលត្រូវបានអង្គជំនុំជម្រះសាលាដំបូងអញ្ជើញឲ្យចូលរួមនៅក្នុងកិច្ចដំណើរការសវនាការនេះ។

**ក្រឡាបញ្ជី៖**

សូមគោរពលោកប្រធាន! ស្ថានភាពវត្តមាន និងអវត្តមានរបស់ភាគីក្នុងសវនាការថ្ងៃនេះមានដូចខាងក្រោម៖

ការិយាល័យសហព្រះរាជអាជ្ញា មានវត្តមានគ្រប់ចំនួន។

ក្រុមមេធាវីការពារជនជាប់ចោទ មានវត្តមាន តែអវត្តមានលោកមេធាវី វ៉ិចទ័រ កូប៉េ

ក្រុមមេធាវីការពារជនជាប់ចោទ អៀង សារី មានវត្តមាន។

ក្រុមមេធាវីការពារជនជាប់ចោទ ខៀវ សំផន មានវត្តមានរបស់លោកមេធាវីជាតិ និងអវត្តមានមេធាវីអន្តរជាតិ។ ជនជាប់ចោទ នួន ជា, អៀង សារី និង ខៀវ សំផន មានវត្តមាន។

មេធាវីតំណាងដើមបណ្ដឹងរដ្ឋប្បវេណីនិងមេធាវីតំណាងដើមបណ្ដឹងរដ្ឋប្បវេណីនាំមុខ មានវត្តមាននៅក្នុងសវនាការថ្ងៃនេះ។

សូមជម្រាបលោកប្រធានផងដែរថា នៅក្នុងសវនាការថ្ងៃនេះ ក្រុមមេធាវីការពាររបស់ជនជាប់ចោទ នួន ជា មានមេធាវីបរទេសម្នាក់ឈ្មោះ អេនឌ្រូ អ៊ីនូហ្សី ដែលអង្គជំនុំ ជម្រះបានទទួលស្គាល់រួច

ហើយ តាមរយៈសេចក្តីសម្រេចចុះថ្ងៃទី២៤ ខែវិច្ឆិកា ឆ្នាំ២០១១ ដែលមាន ឯកសារ E143។

[០៩:០៦:៤៨]

អង្គជំនុំជម្រះក៏បានកត់សម្គាល់ផងដែរថា ក្នុងសវនាការថ្ងៃនេះ មេធាវីតំណាងដើមបណ្តឹងរដ្ឋប្បវេណីមួយរូប ដែលមានឈ្មោះ គ្រីស្ទីន ម៉ាទីណូ ដែលមិនទាន់បានទទួលស្គាល់នៅចំពោះមុខអង្គជំនុំជម្រះ ក៏មានវត្តមានផងដែរ។

សូមអរគុណ។

**ប្រធានអង្គជំនុំ៖**

សូមអរគុណលោក ផារី។ ជាកិច្ចបន្តនេះ មុននឹងចូលដល់កិច្ចពិភាក្សាដេញដោល អង្គជំនុំជម្រះធ្វើកិច្ចនីតិវិធីនៃការទទួលស្គាល់មេធាវីអន្តរជាតិនៅចំពោះមុខអង្គជំនុំជម្រះ ដែលនៅក្នុងសវនាការមុនៗគាត់មិនទាន់ត្រូវបានទទួលស្គាល់ដោយអង្គជំនុំជម្រះ ឬក៏ដោយដីកាសម្រេចជាលាយលក្ខណ៍អក្សរ។

[០៩:០៧:៣៣]

ជាកិច្ចបន្តនេះ អនុលោមទៅតាមវិធាន២២(២)(ក) នៃវិធានផ្ទៃក្នុង អង្គជំនុំជម្រះសូមអញ្ជើញលោកពេជ អង្គ ជាសហមេធាវីជាតិ នៃមេធាវីនាំមុខតំណាងដើមបណ្តឹងរដ្ឋប្បវេណីឡើងធ្វើការស្នើសុំទទួលស្គាល់មេធាវីអន្តរជាតិតំណាងដើមបណ្តឹងរដ្ឋប្បវេណីដែលមានវត្តមាននៅក្នុងសវនការនេះ ហើយមេធាវីរូបនេះមិនទាន់បានទទួលស្គាល់ពីអង្គជំនុំជម្រះពីដំណើរការសវនាការរឿងក្តីនេះពីមុនៗមក។

សូមអញ្ជើញ!

**លោក ពេជ អង្គ៖**

បាទ, សូមគោរពលោកចៅក្រមប្រធាន លោក លោកស្រីចៅក្រម។ នៅទីនេះមានវត្តមានលោកស្រីមេធាវី គ្រីស្ទីន ម៉ាទីណូ ជាមេធាវីដែលចុះឈ្មោះនៅការិយាល័យមេធាវីនៅប្រទេសបារាំងទីក្រុងប៉ារីស ហើយគាត់ជាមេធាវីនៅក្នុងករណី០០១ ករណីឌុច នៅចំពោះមុខអង្គជំនុំជម្រះ ហើយនៅក្នុងករណី០០២ នេះគឺមិនទាន់បានទទួលស្គាល់នៅឡើយទេ។ គាត់ជាសមាជិកនៃក្រុមមេធាវីគ្មានព្រំដែនរបស់បារាំង ហើយខ្ញុំ មេធាវីនាំមុខសូមអនុញ្ញាតលោកប្រធានមេត្តាទទួលស្គាល់លោកស្រីដើម្បីឲ្យមានសិទ្ធិពេញសិទ្ធិជាមេធាវីការពារតំណាងឲ្យដើមបណ្តឹងរដ្ឋប្បវេណីចំពោះមុខអង្គជំនុំជម្រះករណី០០២។

សូមអរគុណ។

[០៩:០៨:៥៥]

**ប្រធានអង្គជំនុំ៖**

អរគុណលោកមេធាវី ពេជ អង្គ។ លោកស្រី គ្រីស្ទីន ម៉ាទីណូ លោកស្រី ត្រូវបានអង្គជំនុំជម្រះសាលាដំបូងទទួលស្គាល់ជាមេធាវីតំណាងដើមបណ្តឹងរដ្ឋប្បវេណី សម្រាប់គោលបំណងនៃកិច្ចដំណើរការសវនាការនៅចំពោះមុខអង្គជំនុំជម្រះសាលាដំបូងនាពេលនេះ អនុលោមតាមការទទួលស្គាល់នេះ លោកស្រីមានសិទ្ធិ និងបុព្វសិទ្ធិដូចគ្នានឹងមេធាវីជាតិតំណាងឲ្យដើមបណ្តឹងរដ្ឋប្បវេណីដែរ។ សូមអញ្ជើញអង្គុយចុះ!

អង្គជំនុំជម្រះកត់សម្គាល់នូវសេចក្តីសម្រេចជាលាយលក្ខណ៍អក្សររបស់ខ្លួន ចុះថ្ងៃទី២៤ ខែវិច្ឆិកា ឆ្នាំ២០១១ ឯកសារមានលេខE143 ដែលបានទទួលស្គាល់មេធាវីអន្តរជាតិ អេនឌ្រូ អ៊ីន្ទូហ្សី ជាមេធាវីការពារក្តីឲ្យជនជាប់ចោទ នួន ជា ដែលតាមរបាយការណ៍របស់ក្រឡាបញ្ជី គឺមេធាវីគាត់មានវត្តមាននៅក្នុងសវនាការនេះដែរ។

[០៩:១០:០០]

**លោក អេនឌ្រូ អ៊ីន្ទូហ្សី៖**

ខ្ញុំ អេនឌ្រូ អ៊ីន្ទូហ្សី មេធាវីតំណាងការពារក្តី នួន ជា ប៉ុន្តែខ្ញុំសូមលើកឡើងបញ្ហាមួយចំនួនមុនពេលដែលយើងបន្តនីតិវិធីសវនាការនៅថ្ងៃនេះ។

សូមអនុញ្ញាតពីលោកប្រធាន តើខ្ញុំអាចលើកបញ្ហាទាំងអស់នេះដែរឬទេ?

**ប្រធានអង្គជំនុំ៖**

លោកមេធាវី ចាំមុននឹងកិច្ចដំណើរការសួរដេញដោល សូមលោកអាចធ្វើសំណើចំណាប់អារម្មណ៍អ្វីមុននឹងចាប់ផ្តើមបាន។ ប៉ុន្តែឥឡូវនេះ អង្គជំនុំជម្រះកំពុងតែធ្វើនូវកិច្ចការទូទៅ ដើម្បីជម្រាបជូនដល់ភាគី និងសាធារណជនអំពីកិច្ចដំណើរការនីតិវិធី តើគួរតែធ្វើយ៉ាងម៉េច ដើម្បីល្អប្រសើរនៅក្នុងកិច្ចដំណើរការនេះ ចៀសវាងមានបញ្ហា។ អ៊ីចឹង គឺអង្គជំនុំជម្រះនឹងទុកឱកាសនៅពេលក្រោយ នៅមុនដេញដោលកូនក្តីរបស់លោក។

**លោក អេនឌ្រូ អ៊ីន្ទូហ្សី៖**

សូមអរគុណលោកប្រធាន។ ថាតើនីតិវិធីរបស់យើងរួមបញ្ចូលទាំងការអាននូវផ្នែកដែលពាក់ព័ន្ធនៅក្នុងដីកាដំណោះស្រាយដែរឬទេ? ដូច្នេះ បើសិនជាអានទៅលើផ្នែកដែលពាក់ព័ន្ធនោះ អ្វីដែលជាចំណាប់របស់ខ្ញុំ គឺពាក់ព័ន្ធនឹងបញ្ហានោះឯង។ សូមអរគុណ។

[០៩:១២:០៤]

**ប្រធានអង្គជំនុំ៖**

លោកមេធាវីមានបញ្ហាអីទៀត? អង្គជំនុំជម្រះដូចបានសម្រេចរួចហើយ ថាលោកមេធាវីចង់មានសំណើសុំ ឬក៏ចាប់អារម្មណ៍អ្វី មុននឹងចាប់ផ្តើមសួរដេញដោលកូនក្តីរបស់លោក ដែលនឹងចាប់ផ្តើមមុនគេ ក្រោយពីអង្គជំនុំជម្រះ គឺរូបយើងប្រធានអង្គជំនុំជម្រះនឹងជ្រាបជូនដល់ភាគីដែលពាក់ព័ន្ធនឹងបញ្ហានេះ នៅក្នុងការរំឭកដាស់តឿននូវកិច្ចដំណើរការនីតិវិធីនៃវិធាននៃការពិភាក្សាដេញដោលមួយចំនួន។ នោះ គឺអង្គជំនុំជម្រះនឹងផ្តល់ឱកាសជូនលោកហើយ។

ជាកិច្ចបន្ត អង្គជំនុំជម្រះសូមរំឭកដល់ភាគីថា តាមរយៈដីកាចុះថ្ងៃទី២២ ខែកញ្ញា ឆ្នាំ២០១១ ឯកសារ E124 សំណុំរឿង០០២ ត្រូវបានបំបែកកិច្ចដំណើរការនីតិវធី ដោយអនុលោមតាមវិធាន៨៩ ស្ទួនពីរ នៃវិធានផ្ទៃក្នុងរបស់ អ.វ.ត.ក ហើយការពិភាក្សាដេញដោលនៅក្នុងសវនាការត្រូវអនុវត្តតាមអង្គហេតុដែលបានបង្ហាញជូនភាគីរួចហើយ តាមរយៈឯកសារឧបសម្ព័ន្ធ E124/7 ដើម្បីធានាឲ្យមានលំដាប់លំដោយក្នុងការពិភាក្សាដេញដោលជនជាប់ចោទ ដើមបណ្តឹងរដ្ឋប្បវេណី សាក្សី និងអ្នកជំនាញនោះ ការសួរចម្លើយជនជាប់ចោទនឹងចាប់ផ្តើមជាដំបូងគេនៅក្នុងសវនាការនេះ អំពីប្រវត្តិបក្សកុម្មុយនីស្តកម្ពុជា ដូចមានបង្ហាញនៅក្នុងដីកាដំណោះស្រាយចាប់ពីកថាខណ្ឌទី១៨ ដល់៣២ អង្គហេតុចោទប្រកាន់មានលក្ខណៈទូទៅ និងបណ្តាកថាខណ្ឌមួយចំនួនទៀត ដែលទាក់ទងនឹងប្រវត្តិសាវតាររបស់ជនជាប់ចោទម្នាក់ៗ ដាច់ដោយឡែកពីគ្នា គឺចំពោះលោក នួន ជា ពីកថាខណ្ឌ៨៦២ ដល់៨៦៨ និងចាប់ពីកថាខណ្ឌ១៥៧៧ ដល់ ១៥៧៩។

[០៩:១៤:៣២]

ចំពោះលោក អៀង សារី ពីកថាខណ្ឌ៩៩៤ ដល់កថាខណ្ឌ១០០០។ កថាខណ្ឌ១០៩១ និងកថាខណ្ឌចាប់ពី ១៥៨៥ ដល់១៥៨៨។

ចំពោះលោក ខៀវ សំផន ពីកថាខណ្ឌ១២២៦ ដល់១១៣០ និងចាប់ពីកថាខណ្ឌ១៥៩៨ ដល់១៦០០។ ការសួរដេញដោលចំពោះជនជាប់ចោទនៅក្នុងវគ្គដំបូងនៃការបំបែកកិច្ចដំណើរការនីតិវិធីសម្រាប់ធ្វើសវនាការទីមួយ ឬអាចកត់សម្គាល់ម្យ៉ាងទៀតថាជាសំណុំរឿងលេខ០០២/០១ នេះកម្រិតកំណត់ត្រឹមអង្គហេតុ ដែលបានបង្ហាញនៅក្នុងបណ្តាកថាខណ្ឌដូចរៀបរាប់ខាងលើនេះក្នុងដីកាដំណោះស្រាយតែប៉ុណ្ណោះ។

អង្គហេតុដែលបានបង្ហាញនៅក្នុងកថាខណ្ឌនៃដីកាដំណោះស្រាយដូចខាងលើនេះ អង្គជំនុំជម្រះនឹងចាត់ឲ្យក្រឡាបញ្ជីសវនាការអានជូនភាគី និងសាធារណជនបានជ្រាបជាមុន មុននឹងដាក់ជូនអង្គសវនាការពិភាក្សាដេញដោល។

[០៩:១៥:៤៨]

លំដាប់លំដោយនៃកិច្ចដំណើរការនីតិវិធីក្នុងដំណាក់កាលជំនុំជម្រះ ដូចមានចែងមានក្នុងវិធាន ៩១ស្ទួន នៃវិធានផ្ទៃក្នុងអ.វ.ត.ក អង្គជំនុំជម្រះត្រូវកំណត់អំពីលំដាប់លំដោយដែលចៅក្រម សហព្រះរាជអាជ្ញា មេធាវី អ្នកភាគីដទៃទៀតមានសិទ្ធិសួរសំណួរទៅកាន់ជនជាប់ចោទ ដើមបណ្ដឹងរដ្ឋប្បវេណី សាក្សី និងអ្នកជំនាញ។

នៅក្នុងដំណាក់នៃការសួរដេញដោលចំពោះជនជាប់ចោទ អង្គជំនុំជម្រះកំណត់លំដាប់លំដោយនៃការសួរដេញដោលជនជាប់ចោទដូចខាងក្រោម៖

ជនជាប់ចោទនឹងត្រូវសួរដោយប្រធានសវនាការជាបឋម និងត្រូវសួរដោយចៅក្រមប្រឹក្សានៃអង្គជំនុំជម្រះដែលត្រូវបានប្រធានប្រគល់ភារកិច្ចឲ្យសួរ និងបន្ទាប់មកចៅក្រមប្រឹក្សាផ្សេងទៀតនៃអង្គជំនុំជម្រះសាលាដំបូងអាចសួរសំណួរបន្ថែម។

បន្ទាប់មកសហព្រះរាជអាជ្ញា បន្ទាប់សហមេធាវីនាំមុខតំណាងដើមបណ្ដឹងរដ្ឋប្បវេណី បន្ទាប់មកមេធាវីការពារក្ដីតាមលំដាប់ចាប់ពីមេធាវី នួន ជា មេធាវី អៀង សារី រួចមេធាវី ខៀវ សំផន។

នេះជាលំដាប់លំដោយមានលក្ខណៈទូទៅ និងក្នុងករណីពិសេសដោយឡែក មេធាវីការពារក្ដីដែលកូនក្ដីរបស់ខ្លួនបាន និងកំពុងស្ថិតនៅជាគោលដៅនៃការសួរដេញដោលដោយអង្គជំនុំជម្រះ និងភាគីមេធាវីការពារក្ដីរបស់ជនជាប់ចោទរូបនេះត្រូវតាំងសំណួរនៅលំដាប់ក្រោយគេបង្អស់។

[០៩:១៧:៣៤]

អង្គជំនុំជម្រះក៏សូមជម្រាបដល់ភាគី និងសាធារណជនបានជ្រាបផងដែរអំពីដំណាក់កាលដំបូងនៃការជំនុំជម្រះដែលចាប់ផ្ដើមថ្ងៃនេះទៅ រហូតដល់យ៉ាងយូរត្រឹមថ្ងៃទី១៦ ខែធ្នូ ឆ្នាំ២០១១ បន្ទាប់មកអង្គជំនុំជម្រះនឹងឈប់សម្រាក ហើយនិងចាប់ផ្ដើមបន្តសវនាការចាប់ពីថ្ងៃទី១០ ខែមករា ឆ្នាំ២០១២តទៅទៀត។

ក្រោយពីការសួរដេញដោលចំពោះជនជាប់ចោទទាំងអស់អំពីប្រធានបទ ឬអង្គហេតុស្ដីពីប្រវត្តិបក្សកុម្មុយនីស្តកម្ពុជាដូចបានជម្រាបជូនខាងលើ បន្ទាប់មកអង្គជំនុំជម្រះ និងភាគីទាំងអស់នឹងសួរដេញ

ដោលដើមបណ្តឹងរដ្ឋប្បវេណី សាក្សី អ្នកជំនាញ ពាក់ព័ន្ធនឹងអង្គហេតុស្តីពីប្រវត្តិបក្សកុម្មុយនីស្តកម្ពុជា ដូចខាងលើ ដែលពួកគាត់មានលទ្ធភាពដឹងដោយស្ទួរដេញដោលតាមលំដាប់លំដោយនៃអង្គហេតុស្តីពីប្រវត្តិបក្សកុម្មុយនីស្តកម្ពុជា និងអង្គហេតុដូចដែលអង្គជំនុំជម្រះសាលាដំបូងបានកំណត់នៅក្នុងឯកសារឧបសម្ព័ន្ធ E124/7.1/correct2 ជាវិធានទូទៅសំណួរដែលមិនពាក់ព័ន្ធនឹងអង្គហេតុនានានៅក្នុងសវនាការដំណាក់កាលដំបូងនៃសំណុំរឿងក្តីលេខ០០២នេះ នឹងមិនត្រូវបានអនុញ្ញាតដោយអង្គជំនុំជម្រះឡើយ។

ដើមបណ្តឹងរដ្ឋប្បវេណី សាក្សី អ្នកជំនាញ នឹងអាចត្រូវស្ទួរដេញដោលដោយចៅក្រមជំនុំជម្រះភាគីទៅតាមលំដាប់លំដោយកំណត់ដោយអង្គជំនុំជម្រះ ប្រហាក់ប្រហែលគ្នាទៅនឹងការស្ទួរចម្លើយជនជាប់ចោទដែរ។

[០៩:១៩:២៩]

ក្រោយពីបានផ្តល់ចម្លើយ ដើមបណ្តឹងរដ្ឋប្បវេណីអាចលើកឡើង ឬថ្លែងរៀបរាប់អំពីព្យសនកម្មនានាដែលខ្លួនបានទទួលរងនៅពេលដែលព្យសនកម្មទាំងនោះ ស្ថិតនៅក្នុងវង្វង់សំណុំរឿងលេខ ០០២/០១។

ដោយហេតុថាដើមបណ្តឹងរដ្ឋប្បវេណី សាក្សី អ្នកជំនាញទាំងអស់ មិនមែនសុទ្ធតែបានដឹង និងមានភាពពាក់ព័ន្ធទៅនឹងអង្គហេតុដែលបាននិងកំពុងលើកយកមកធ្វើសវនាការដូចៗគ្នាទេ។ ទើបអង្គជំនុំជម្រះពិចារណាថា មិនទាន់ដល់ពេលសមស្របឡើយដែលអង្គជំនុំជម្រះត្រូវកំណត់ការបែងចែកពេលវេលាសម្រាប់ភាគីនានាក្នុងការស្ទួរដេញដោលនៅក្នុងដំណាក់កាលនេះ។ ទោះបីជាយ៉ាងនេះក្តី ភាគីទាំងអស់ត្រូវតែកម្រិត កំណត់នូវសំណួររបស់ខ្លួនឲ្យនៅត្រឹមផ្នែកដែលពាក់ព័ន្ធនឹងអង្គហេតុដែលបានកំណត់នៅក្នុងឯកសារឧបសម្ព័ន្ធ E124/7.1/Correct2 ភាគីទាំងអស់ត្រូវចៀសវាងនូវស្ទួរសំណួរច្រំដែលសំណួរក្រៅអង្គហេតុដែលអង្គជំនុំជម្រះបានកំណត់សម្រាប់ធ្វើសវនាការនៅដំណាក់កាលទីមួយ សំណួរមិនជាប់ពាក់ព័ន្ធ សំណួរបែបឧបមានវិធីជាដើម ដែលគ្មានប្រយោជន៍ដល់ការស្វែងរកការពិត និងអូសបន្លាយពេលវេលាសវនាការដោយឥតប្រយោជន៍។

[០៩:២០:៥៧]

ដូចដែលបានកំណត់ដោយអង្គជំនុំជម្រះ ក្រោយពីការស្ទួរដេញដោលលើជនជាប់ចោទទាំងអស់ចប់រួចហើយលើអង្គហេតុសម្រាប់ធ្វើសវនាការនៅវគ្គដំបូងនេះ។ បន្ទាប់មក អង្គជំនុំជម្រះមានបំណង

ស្ដាប់ដើមបណ្ដឹងរដ្ឋប្បវេណីចំនួនពីររូប ដែលមានរហស្សនាម TCCP185 និង TCCP123។ យោងឯកសារឧបសម្ព័ន្ធសម្ងាត់(ខ) E131/1.2 អង្គជំនុំជម្រះបានចាត់តាំងសហមេធាវីនាំមុខតំណាងដើមបណ្ដឹងរដ្ឋប្បវេណីឱ្យសួរសំណួរទៅពួកគាត់មុនភាគីដទៃបន្ទាប់ពីប្រធាន ឬចៅក្រមប្រឹក្សាដែលប្រធានចាត់តាំងឱ្យសួរសំណួរបឋម។ រួចឯកសារ E131/10 ភាគីផ្សេងទៀតមានដូចជា សហព្រះរាជអាជ្ញាបន្ទាប់មកសហមេធាវីការពារក្ដីនឹងត្រូវបានអនុញ្ញាតឱ្យសួរសំណួរទៅដើមបណ្ដឹងរដ្ឋប្បវេណីទាំងនេះ នៅពេលដែលដើមបណ្ដឹងរដ្ឋប្បវេណី សាក្សី ឬអ្នកជំនាញណាម្នាក់មិនអាចមានវត្តមានតាមពេលវេលាដែលអង្គជំនុំជម្រះបានកំណត់ អង្គជំនុំជម្រះនឹងធ្វើសវនាការស្ដាប់សាក្សី ដើមបណ្ដឹងរដ្ឋប្បវេណី អ្នកជំនាញនៅលំដាប់បន្ទាប់ ហើយលើកពេលសម្រាប់ការស្ដាប់ចម្លើយដើមបណ្ដឹងរដ្ឋប្បវេណី សាក្សី ឬអ្នកជំនាញនោះទៅធ្វើនៅពេលក្រោយ។

[០៩:២២:៣៥]

នៅក្នុងអំឡុងពេលនៃវគ្គដំបូងសវនាការនេះ បន្ទាប់ពីការសួរដេញដោលចំពោះដើមបណ្ដឹងរដ្ឋប្បវេណីចំនួនពីររូបលើអង្គហេតុសម្រាប់ធ្វើសវនាការនៅវគ្គដំបូងបានចប់ អង្គជំនុំជម្រះក៏មានបំណងផងដែរក្នុងការចាប់ផ្ដើមសួរសាក្សីចំនួនបួនរូបដំបូងដែលមានរហស្សនាម TCW564, TCW583, TCW 542 និង TCW395។

[០៩:២៣:១៦]

អង្គជំនុំជម្រះសាលាដំបូងបានចាត់តាំងសហព្រះរាជអាជ្ញាឱ្យសួរសំណួរទៅពួកគាត់មុនភាគីដទៃ បន្ទាប់ពីប្រធាន ឬចៅក្រមប្រឹក្សាដែលប្រធានចាត់តាំងបានសួរសំណួរបឋមរួច។ ភាគីផ្សេងទៀតនឹងត្រូវបានអនុញ្ញាតឱ្យសួរសំណួរទៅកាន់សាក្សីទាំងនេះទៅតាមលំដាប់លំដោយដូចគ្នាទៅនឹងលំដាប់លំដោយដែលបានបញ្ជាក់ខាងលើ។

អំពីការជំទាស់ទៅនឹងឯកសារ ពេលវេលាផុតកំណត់នៃការជំទាស់ទៅនឹងការដាក់ឯកសារនិងវត្ថុតាងផ្សេងៗនៅចំពោះមុខអង្គជំនុំជម្រះ និងទម្រង់បែបបទ ដើម្បីឱ្យការជំទាស់ទៅនឹងឯកសារ ឬវត្ថុតាងអាចទទួលយកបាននៅក្នុងសវនាការនៅដំណាក់កាលដំបូងនេះ គឺបានជម្រាបជូននៅក្នុងអនុស្សរណៈរបស់អង្គជំនុំជម្រះសាលាដំបូងដែលបានផ្ញើជូនទៅភាគីកាលពីថ្ងៃទី២៥ ខែតុលា ឆ្នាំ២០១១ ឯកសារ E131/1 អង្គជំនុំជម្រះនឹងធ្វើសេចក្ដីសម្រេចលើបណ្ដឹងជំទាស់នេះនិងឯកសារដែលបានដាក់មុននេះទាក់ទងទៅនឹងសវនាការនៅដំណាក់កាលដំបូងនេះក្នុងចិរវេលាមួយសមស្រប។

[០៩:២៤:២៧]

ការជំទាស់ទៅនឹងការស្តាប់សាក្សីត្រូវបានអនុវត្តតាមខ្លឹមសារនៃវិធាន៩១(៣) នៃវិធានផ្ទៃក្នុង អ.វ.ត.ក និងបទប្បញ្ញត្តិមាត្រា៣២៧ នៃក្រមនីតិវិធីព្រហ្មទណ្ឌខ្មែរ ឆ្នាំ២០០៧។ អង្គជំនុំជម្រះសូមរំឭកដល់ភាគីថា ឈ្មោះសាក្សី ដើមបណ្តឹងរដ្ឋប្បវេណី អ្នកជំនាញដែលមាននៅក្នុងឯកសារឧបសម្ព័ន្ធសម្ងាត់ (ក) E131/1.1 ត្រូវប្រើរហស្សនាមរហូតដល់វិធានការការពារត្រូវបានសម្រេច។

អង្គជំនុំជម្រះសូមរំឭកដល់ភាគីផងដែរថា នៅពេលឡើងធ្វើការតាំងសំណួរ ឬធ្វើសេចក្តីថ្លែងការណ៍ផ្សេងៗ ត្រូវប្រព្រឹត្តទៅប្រកបដោយសីលធម៌វិជ្ជាជីវៈខ្ពស់ ចៀសវាងការប្រើពាក្យអសុរោះ ពាក្យប្រមាថ មើលងាយដល់ភាគីដទៃទៀត ឬដល់គោលដៅដែលត្រូវសួរ ឬដល់អ្នកដទៃផ្សេងទៀត។

ជាកិច្ចបន្តអង្គជំនុំជម្រះនឹងចាត់តាំងឲ្យក្រឡាបញ្ជីសវនាការចំនួនពីររូប ឡើងអាននូវកថាខណ្ឌនៃដីកាដំណោះស្រាយដែលទាក់ទងទៅនឹងអង្គហេតុដែលបានចោទប្រកាន់ចំពោះជនជាប់ចោទ ដែលត្រូវលើកយកមកធ្វើការពិភាក្សាដេញដោលនាសវនាការនានៅវគ្គដំបូងនេះ។ ដោយលោក ឌុច ផារី ក្រឡាបញ្ជីនៃអង្គជំនុំជម្រះសាលាដំបូងនឹងឡើងអាននូវអង្គហេតុដែលបានចោទប្រកាន់ ដែលត្រូវលើកឡើង លើកយកមកពិភាក្សាដេញដោលនូវសនវការដំបូងនេះ ចាប់ពីកថាខណ្ឌ១៨ ដល់កថាខណ្ឌ៣២ នៃដីកាដំណោះស្រាយ។ ឯលោក ដាវ អានសាន នឹងឡើងអាននូវអង្គហេតុដែលបានចោទប្រកាន់ ដែលបានលើកឡើងយកមកធ្វើការពិភាក្សាដេញដោលនាសវនាការវគ្គដំបូងនេះនូវបណ្តាកថាខណ្ឌមួយចំនួនដែលពាក់ព័ន្ធទៅនឹងប្រវត្តិសាវតាររបស់ជនជាប់ចោទទាំងបីរូប។

[០៩:២៦:៣០]

មុននឹងអង្គជំនុំជម្រះបង្គាប់ឲ្យក្រឡាបញ្ជីអាននូវកថាខណ្ឌ ដែលពាក់ព័ន្ធនឹងដីកាដំណោះស្រាយដែលបានដាក់ថា “កោសលុប” ដោយការិយាល័យសហចៅក្រមស៊ើបអង្កេតនោះ អង្គជំនុំជម្រះសូមជម្រាបជូនដល់ភាគី និងសាធារណជនឲ្យបានជ្រាបថា ត្រង់ចំណុចដែលក្រឡាបញ្ជីអានថា “កោសលុប” គឺអាចជាឈ្មោះរបស់សាក្សី ឈ្មោះដើមបណ្តឹងរដ្ឋប្បវេណី ឬព័ត៌មានមួយចំនួនដែលអាចបញ្ជាក់អំពីអត្តសញ្ញាណរបស់បុគ្គល ដែលនឹងត្រូវទទួលវិធានការការពារ ឬអាចនឹងមកផ្តល់សក្ខីកម្មនៅចំពោះមុខអង្គជំនុំជម្រះ។

ជាបន្តសូមអញ្ជើញលោក ឌុច ផារី ឡើងអានដីកាដំណោះស្រាយចាប់ពីកថាខណ្ឌ១៨ ដល់កថាខណ្ឌ៣២។ សូមអញ្ជើញ!

**ក្រឡាបញ្ជី៖**

ជំពូកទី១៖ ការកត់សម្គាល់ឃើញអំពីអង្គហេតុ

ផ្នែកទី១៖ ប្រវត្តិបក្សកុម្មុយនីស្តកម្ពុជា

កថាខណ្ឌ១៨៖ អត្ថិភាពរបស់បក្សកុម្មុយនីស្តកម្ពុជាត្រូវបានប្រកាសជាផ្លូវការនាខែកញ្ញា ឆ្នាំ ១៩៧៧។ ខណៈដែលបក្សកុម្មុយនីស្តកម្ពុជានេះកាន់អំណាចជាងពីរឆ្នាំមកហើយ ពីដើមឡើយពាក្យ "អង្គការ" ត្រូវបានប្រើប្រាស់តាំងពីទសវត្សរ៍ឆ្នាំ១៩៤០ និងមានន័យថា "អង្គការចាត់តាំង" ដោយសំដៅដល់បក្សទាំងមូលផង និងសំដៅដល់ថ្នាក់ដឹកនាំនៅកម្រិតផ្សេងៗទៀតផង ដោយមិនបានបញ្ជាក់ច្បាស់លាស់ពីអ្វីផ្សេងពីនេះទៀតឡើយ។

[០៩:២៨:២៧]

នៅក្នុងប្រទេសកម្ពុជាក្រុមដែលបានប្រកាន់យកមនោគមន៍វិជ្ជា-- មនោគមន៍ វិជ្ជាកុម្មុយនីស្តមានអត្ថិភាពចាប់តាំងតែពីមុនកាលវិច្ឆេទនេះមកម្ល៉េះ។ ទោះបីជាបក្សកុម្មុយនីស្តកម្ពុជាមាននិន្នាការតាក់តែងប្រវត្តិសាស្ត្រខ្លួនឡើងវិញក៏ដោយ ក៏គេនូវអាចកំណត់បាននូវការវិវត្តន៍របស់បក្សនេះតាមរយៈកាលបរិច្ឆេទសំខាន់ៗជាច្រើន ដែលមានសារៈសំខាន់ដល់ការស៊ើបសួរ។

កថាខណ្ឌ១៩៖ អង្គការចាត់តាំងមួយក្នុងចំណោមអង្គការចាត់តាំងកុម្មុយនីស្តដំបូងនៅក្នុងតំបន់នេះ គឺបក្សកុម្មុយនីស្តឥណ្ឌូចិន ដែលបានបង្កើតឡើងនៅក្នុងឆ្នាំ១៩៣០។ ដោយមានការទទួលឥទ្ធិពលយ៉ាងខ្លាំងពីជនកុម្មុយនីស្តវៀតណាម។ បក្សកុម្មុយនីស្តឥណ្ឌូចិន ត្រូវបានរំលាយជាផ្លូវការនៅក្នុងឆ្នាំ ១៩៥១ ហើយអតីតសមាជិករបស់បក្សនេះក៏បានបង្កើតអង្គការបដិវត្តន៍ដាច់ដោយឡែកពីគ្នា នៅក្នុងប្រទេសនីមួយៗ។

[០៩:២៩:៤៦]

បក្សថ្មីមួយដែលត្រូវបានបង្កើតឡើងនៅកម្ពុជាមានឈ្មោះថា "បក្សប្រជាជនបដិវត្តន៍ខ្មែរ"។ បក្សប្រជាជនបដិវត្តន៍ខ្មែរមានឥទ្ធិពលយ៉ាងខ្លាំងនៅក្នុងបណ្តាក្រុមឥស្សរៈ ដែលបានតតាំងទាមទារយកឯករាជ្យ ហើយទីបំផុតការទាមទារនេះបានទទួលជោគជ័យ និងបានទទួលស្គាល់នៅឯសន្និសីទនាទីក្រុងហ្សឺណែវក្នុងឆ្នាំ១៩៥៤។

កថាខណ្ឌ២០៖ ឯកសារ និងសេចក្តីថ្លែងការណ៍ផ្លូវការនានារបស់បក្សកុម្មុយនីស្តកម្ពុជា ក្រោយពីថ្ងៃទី១៧ ខែមេសា ឆ្នាំ១៩៧៥ បង្ហាញថា មហាសមាជនាថ្ងៃទី៣០ ខែកញ្ញា ឆ្នាំ១៩៦០ ដែលពេលនោះ

"បក្សប្រជាជនបដិវត្តន៍ខ្មែរ" ត្រូវប្តូរឈ្មោះទៅ "ជាបក្សពលករខ្មែរ" គឺជាចំណុចចាប់ផ្តើមពិតប្រាកដនៃការបង្កើតចលនាកុម្មុយនីស្តខ្មែរ។ មានមនុស្សចំនួនប្រមាណ២០នាក់បានចូលរួមក្នុងសមាជនេះ ក្នុងនោះមាន នួន ជា អនុលេខាបក្សដែលបានទទួលការបោះឆ្នោតតែងតាំង សាឡុត ស ហៅ ប៉ុល ពត សមាជិកគណៈអចិន្ត្រៃយ៍, អៀង សារី និង សោ ភឹម សមាជិកបម្រុងនៃគណៈអចិន្ត្រៃយ៍ និង វន វ៉េត។ ការចេញផ្សាយទស្សនាវដ្តីទង់បដិវត្ត ជាទស្សនាវដ្តីមួយក្នុងចំណោមទស្សនាវដ្តីផ្លូវការរបស់បក្ស។

នៅខែសីហា ឆ្នាំ១៩៧៥ បានលើកឡើងថា មាគ៌ាជាយុទ្ធសាស្ត្រ និងជាយុទ្ធវិធីរបស់បក្សកុម្មុយនីស្តកម្ពុជា បានធ្វើឡើងច្បាស់លាស់ និងត្រឹមត្រូវជាមូលដ្ឋាននៅឆ្នាំ១៩៦០។ ក្នុងមហាសន្និបាតបក្សលើកទីមួយ ពិតមែនតែបក្សយើងកកើតតាំងពីឆ្នាំ១៩៥១ ម្ល៉េះ។ នៅថ្ងៃទី៣០ ខែមីនា ឆ្នាំ១៩៧៦ គណៈមជ្ឈិមបានសម្រេចថា កំណត់កំណើតបក្សពីឆ្នាំ១៩៦០ វិញ មិនយកឆ្នាំ១៩៥១ ទេ ដើម្បីកុំឲ្យជាប់ជាមួយគេឯង ឲ្យដាច់ស្រឡះ។ នួន ជា បានលើកឡើងថា "បើគ្មានរូបលោកផ្ទាល់ និង ប៉ុល ពត ទេ បក្សកុម្មុយនីស្តកម្ពុជានឹងត្រូវបានរៀតណាមក្តោបក្តាប់ទៅហើយ"។

[០៩:៣២:៥២]

កថាខណ្ឌ២១៖ បន្ទាប់ពីសន្និសីទនាឆ្នាំ១៩៥៤ ចលនាកុម្មុយនីស្តបានបង្កើតក្រុមមួយជាសាធារណៈ គឺក្រុមប្រជាជន និងព្យាយាមកែទម្រង់ឲ្យទៅជារបបសង្គមនិយម តាមរយៈដំណើរការប្រជាធិបតេយ្យ ប៉ុន្តែក្រោមការបង្ក្រាបខ្លាំងក្លារបស់រដ្ឋាភិបាល មេដឹកនាំបក្សពលករខ្មែរបានពិចារណាអំពីការតស៊ូចាំបាច់ដោយអាវុធដើម្បីយកជ័យជម្នះ ហើយបានចាប់ផ្តើមរៀបចំការតស៊ូនេះ ដើម្បីដណ្តើមយកអំណាចរបស់រដ្ឋ។ នាដើមទសវត្សរ៍ឆ្នាំ១៩៦០ បក្សពលករខ្មែរបានបង្កើតកងការពារសម្ងាត់ដើម្បីការពារកម្មាភិបាល និងសកម្មភាពនយោបាយរបស់ខ្លួន រួមទាំងដើម្បីកម្ទេចខ្មាំង។ ឌុច បានបញ្ជាក់ថា គោលនយោបាយនេះបានអនុម័តនៅក្នុងពេលមហាសន្និបាតលើកទី១ ដើម្បីអូសទាញកម្លាំងដែលស្ទាក់ស្ទើរ អព្យាក្រឹត្យ កម្លាំងមិនឃោរឃៅ ឯកកោ ហើយកម្ទេចកម្លាំងដែលសេសសល់។

កថាខណ្ឌ២២៖ បន្ទាប់ពីការបាត់ខ្លួនលេខាបក្សពលករខ្មែរឈ្មោះ ទូ សាមុត នៅឆ្នាំ១៩៦២ មិនដែលមានការបំភ្លឺច្បាស់លាស់អំពីរឿងនេះ។ សមាជលើកទី២ របស់បក្សត្រូវបានធ្វើឡើងនៅចុងខែកុម្ភៈ ឆ្នាំ១៩៦៣ ដែលពេលនោះ សាឡុត ស បានក្លាយខ្លួនជាលេខាបក្សថ្មី ចំណែក នួន ជា នៅបន្តធ្វើជាអនុលេខាបក្សដដែល។

[០៩:៣៥:០២]

សមាជនេះ ត្រូវបានធ្វើឡើងនៅទីក្រុងភ្នំពេញ ដោយមានកម្រិតចំនួនអ្នកចូលរួមត្រឹមមនុស្សសំខាន់ៗដូចជា អៀង សារី និង សោ ភឹម អ្នកទាំងពីរត្រូវបានបោះឆ្នោតជ្រើសតាំងជាសមាជិកពេញសិទ្ធិនៃគណៈអចិន្ត្រៃយ៍ តាម៉ុក, វន វ៉េត, សុន សេន, រស់ ញឹម, និង គង់ សុផល។ ប៉ុន្មានខែក្រោយមកបន្ទាប់ពីរដ្ឋាភិបាល បានចេញផ្សាយនូវបញ្ជីឈ្មោះមនុស្សដែលគេស្គាល់ថា ជាអ្នកឆ្វេងនិយមចំនួន៣៤រូប ប៉ុល ពត និងមេដឹកនាំបក្សពលករខ្មែរមួយចំនួន ដែលមានឈ្មោះក្នុងបញ្ជីនោះ រួមទាំង អៀង សារី និង សុន សេន ក៏បានភៀសខ្លួនពីទីក្រុង។ អ្នកទាំងនោះបានទៅជ្រកកោននៅឯបន្ទាយវៀតណាមមួយនៅតាមបណ្តោយព្រំដែន ដែលនៅទីនោះ ពួកគេបានបង្កើតមន្ទីរមួយឈ្មោះថា "មន្ទីរ១០០"។

មកដល់ឆ្នាំ១៩៦៥ ប្រពន្ធរបស់អ្នកទាំងនោះ ដូចជា ខៀវ ប៉ុណ្ណារី, អៀង ធីរិទ្ធ, និង យុន យ៉ាត បានចូលរួមជាមួយពួកគេនៅមន្ទីរ១០០នោះ។

ដោយសារអត្តសញ្ញាណរបស់ នួន ជា មិនត្រូវបានគេស្គាល់ ហើយឈ្មោះរបស់គាត់ ពុំស្ថិតនៅក្នុងបញ្ជីឈ្មោះមនុស្សទាំង៣៤នាក់នោះ គាត់បានបន្តស្នាក់នៅភ្នំពេញ និងទទួលបន្ទុករាល់ប្រតិបត្តិការនានារបស់បក្សពលករខ្មែរក្នុងទីក្រុង និងតំបន់ជាច្រើន។

កថាខណ្ឌ២៣ នៅខែមករា ឆ្នាំ១៩៦៥ បក្សពលករខ្មែរបានអនុម័តសេចក្តីសម្រេចមួយដែលបានទាត់ចោលនូវលទ្ធភាពនៃការការផ្លាស់ប្តូរដោយសន្តិវិធីទៅកាន់លទ្ធិសង្គមនិយម និងបានបញ្ជាក់អះអាងថា ជាការចាំបាច់ដែលត្រូវបានប្រើប្រាស់ហិង្សាបដិវត្តន៍ក្នុងការតស៊ូប្រឆាំងនឹងពួកចក្រពត្តិ។

ក្នុងអង្គប្រជុំគណៈមជ្ឈិម កាលពីខែកញ្ញា ឬខែតុលា ឆ្នាំ១៩៦៦ មេដឹកនាំបក្សពលករខ្មែរបានសម្រេចប្តូរឈ្មោះបក្សទៅជាបក្សកុម្មុយនីស្តកម្ពុជា។ ទោះជាគេរក្សាសេចក្តីសម្រេចនោះទុកជាការសម្ងាត់រហូតដល់សមាជលើកក្រោយក្តី និងប្តូរទីតាំងមន្ទីរ១០០ទៅ ខេត្តរតនគិរី និងបានចាប់ផ្តើមរៀបចំការតស៊ូប្រដាប់អាវុធនៅតាមតំបន់នីមួយៗ។

[០៩:៣៨:១១]

នៅអំឡុងឆ្នាំ១៩៦៧ មេដឹកនាំមួយចំនួនរបស់បក្សបានឯកភាព ធ្វើការបះបោរប្រដាប់អាវុធមួយនៅឆ្នាំ១៩៦៨។ មិនយូរប៉ុន្មានទីស្នាក់ការគណៈមជ្ឈិមថ្មីមួយឈ្មោះ "មន្ទីរ១០០" ដែរ ត្រូវបានបង្កើតឡើងក្នុងខេត្តរតនគិរី ចម្ងាយប្រហែលប៉ុន្មានគីឡូម៉ែត្រពីមន្ទីរ១០២ ដែលជាមន្ទីរភូមិភាគព្ឆិសាន ដែលត្រូវបានប្រើប្រាស់ដោយ អៀង សារី។ គាត់ត្រូវបានតែងតាំងជាលេខាភូមិភាគ។

[០៩:៣៨:៥៦]

កថាខណ្ឌ២៤៖ នៅថ្ងៃទី១៧ ខែមករា ឆ្នាំ១៩៦៨ តាមការបញ្ជារបស់ នួន ជា កងកម្លាំងរបស់បក្សកុម្មុយនីស្តកម្ពុជា បានវាយប្រហារបន្ទាយកងទ័ពរបស់រដ្ឋាភិបាលនៅភូមិបាយតម្រាំ ភាគខាងត្បូងក្រុងបាត់ដំបង ដោយរឹបអូសបានអាវុធមួយចំនួន។ បន្ទាប់មក កាលបរិច្ឆេទខាងលើនេះ ត្រូវបានបក្សកុម្មុយនីស្តកម្ពុជាចាត់ទុកថាជាថ្ងៃកំណើតរបស់កងទ័ពបដិវត្តន៍កម្ពុជា។ នៅប៉ុន្មានខែបន្ទាប់ កងកម្លាំងរបស់បក្សកុម្មុយនីស្តកម្ពុជា បានបន្តការវាយប្រហាររបស់ខ្លួននៅទូទាំងប្រទេស។

[០៩:៣៩:៥០]

កថាខណ្ឌ២៥៖ នៅថ្ងៃទី១៨ ខែមីនា ឆ្នាំ១៩៧០ សម្តេច នរោត្តម សីហនុ ត្រូវបានឧត្តមសេនីយ៍ លន់ នល់ និងព្រះអង្គម្ចាស់សិរិមតៈទម្លាក់ពីតំណែង ហើយពួកគេបានបង្កើតរបបមួយឈ្មោះថា សាធារណរដ្ឋខ្មែរ។ នៅថ្ងៃទី២៣ ខែមីនា ឆ្នាំ១៩៧០ សម្តេច សីហនុ បានប្រកាសអំពីការបង្កើតរណសិរ្សរួបរួមជាតិកម្ពុជា និងបានអំពាវនាវឲ្យអ្នកស្នេហាជាតិធ្វើការបះបោរប្រឆាំងនឹងរដ្ឋាភិបាលថ្មី។ សម្តេច សីហនុ និងបក្សកុម្មុយនីស្តកម្ពុជា បានបង្កើតសម្ព័ន្ធភាពមួយ និងរដ្ឋាភិបាលនិរទេសមួយ ដែលមានមូលដ្ឋាននៅទីក្រុងប៉េកាំងមានឈ្មោះថា “រដ្ឋាភិបាលរួបរួមជាតិកម្ពុជា”។

រដ្ឋាភិបាលនេះ ត្រូវបានប្រកាសជាផ្លូវការណ៍នៅថ្ងៃទី០៥ ខែឧសភា ឆ្នាំ១៩៧០។ “លុប” ជាអតីតប្រធានរណសិរ្សរួបរួមជាតិកម្ពុជា ហើយលោក ប៉ែន នុត ដែលមិនមែនជាជនកុម្មុយនីស្តជានាយករដ្ឋមន្ត្រីនៃរាជរដ្ឋាភិបាលរួបរួមជាតិកម្ពុជា រីឯ ខៀវ សំផន ជាអតីតឧបនាយករដ្ឋមន្ត្រី និងរដ្ឋមន្ត្រីក្រសួងការពារជាតិ។

ខែសីហា ឆ្នាំ១៩៧០ អៀង ធីរិទ្ធ ត្រូវបានតែងតាំងជាអនុរដ្ឋមន្ត្រីក្រសួងវប្បធម៌ អប់រំ និងយុវជន។

កថាខណ្ឌ២៦៖ នៅពេលនោះមេដឹកនាំបក្សកុម្មុយនីស្តកម្ពុជា បានចាកចេញពីខេត្តរតនគិរី និងបានចាប់ផ្តើមធ្វើដំណើរអស់រយៈពេលប៉ុន្មានខែទៅភាគខាងត្បូងស្ទឹងជីនិត តាមបណ្តោយព្រំប្រទល់ខេត្តកំពង់ចាម និងកំពង់ធំ ដែលជាទីតាំងទីស្នាក់ការលេខាភូមិភាគឧត្តរឈ្មោះ កុយ ធួន។ ដំបូង ប៉ុល ពត និង នួន ជា បានស្នាក់នៅឯបន្ទាយមួយឈ្មោះ ក-១ ស្ថិតនៅភូមិដងក្តារ ប៉ែកឦសាននៃឃុំស្ទឹង។ បន្ទាប់មកនៅចុងឆ្នាំ១៩៧០ ពួកគេបានប្តូរទៅកាន់ទីតាំងធំក្បែរនោះ និងត្រូវបានគេឲ្យឈ្មោះថា មន្ទីរ ស-៧១។ ក្នុងចំណោមមេដឹកនាំបក្ស ដែលបោះមូលដ្ឋាននៅទីកន្លែងនេះមានដូចជា ប៉ុល ពត, នួន ជា, ខៀវ សំផន និង ឈឹម សំអោក ហៅ ប៉ង់។

[០៩:៤៣:១៣]

កថាខណ្ឌ២៧៖ នៅខែធ្នូ ឆ្នាំ១៩៧០ អៀង សារី បានធ្វើដំណើរទៅហាណូយ ដើម្បីរៀបចំឡើងវិញនូវវិទ្យុសំឡេងរណសិរ្សរួបរួមជាតិកម្ពុជា ដែលត្រូវបានដាក់ឲ្យស្ថិតនៅក្រោមអំណាច និងការគ្រប់គ្រងរបស់ អៀង ធីរិទ្ធ រហូតដល់ខែឧសភា ឆ្នាំ១៩៧៥។ បន្ទាប់មក នៅក្នុងខែមេសា ឆ្នាំ១៩៧១ គាត់បានធ្វើដំណើរទៅកាន់ទីក្រុងប៉េកាំង ដើម្បីស្នាក់នៅជាមួយ "លុប" និងធ្វើជាបេសកជនពិសេសនៃចលនាតស៊ូ។ នៅភូមិគ្រឹះរបស់គាត់នៅទីក្រុងប៉េកាំង អៀង សារី មានទំនាក់ទំនងតាមរយៈទូរលេខផ្ទាល់ជាមួយមន្ទីរស-៧១។

[០៩:៤៤:១៥]

កថាខណ្ឌ២៨៖ នៅខែមករា ឆ្នាំ១៩៧១ គណៈមជ្ឈិមនៃបក្សកុម្មុយនីស្តកម្ពុជាបានជួបប្រជុំគ្នាជាលើកទីមួយ ចាប់តាំងពីខែតុលា ឆ្នាំ១៩៦៦ រយៈពេលបីថ្ងៃនៅមន្ទីរស-៧១ ដោយមានសមាជិកចូលរួមចំនួន២៧រូប ក្នុងនោះមាន ប៉ុល ពត, នួន ជា, សោ ភឹម, វន វ៉េត, តាម៉ុក, រស់ ញឹម, គង់ សុផល, ជូ ជេត, កង ចាប, កុយ ធួន, កែ ពក, សៀ វ៉ាស៊ី ហៅ ឌឿន និង ប៉ង់។

កថាខណ្ឌ២៩៖ តាមរយៈវគ្គរៀនសូត្រដែលដឹកនាំដោយ ប៉ុល ពត ឆ្នាំ១៩៧១ នៅឯទីស្នាក់ការភូមិភាគឧត្តរចំពោះកម្មាភិបាលស្រុក តំបន់ និងភូមិភាគ ចំនួន ២០០នាក់ចូលរួម ត្រូវបានជ្រើសរើស និងត្រូវបាននាំចេញទៅប៉ុន្មានគីឡូម៉ែត្រពីទីនោះ ឆ្ពោះទៅកាន់ជំរំមួយនៅក្នុងព្រៃ ដែលជាកន្លែងប្រារព្ធសមាជលើកទីបី។ សមាជលើកនេះមានប្រតិភូចូលរួមប្រហែល៦០នាក់ ក្នុងនោះមាន ខៀវ សំផន លេខាភូមិភាគទាំងអស់ និងមេបញ្ជាការយោធា ដូចជា កែ ពក ជាដើម។ សមាជនេះបានអនុម័តលក្ខន្តិកៈបក្សថ្មី ទទួលយកជាផ្លូវការនូវឈ្មោះ "បក្សកុម្មុយនីស្តកម្ពុជា" ដែលត្រូវបានប្រើប្រាស់អស់រយៈពេល៥ឆ្នាំ រួចមកហើយ និងបានបោះឆ្នោតតែងតាំងគណៈមជ្ឈិមថ្មី ដែលបានដាក់បញ្ចូល ខៀវ សំផន ជាសមាជិកបម្រុង ឬសមាជិកត្រៀម។

កថាខណ្ឌ៣០៖ នៅខែឧសភា ឆ្នាំ១៩៧២ គណៈមជ្ឈិមថ្មីបានជួបប្រជុំគ្នា នៅក្នុងឱកាសនេះ គណៈមជ្ឈិមថ្មីបានចេញសេចក្តីណែនាំទៅកាន់សមាជិកបក្ស ឲ្យខំពង្រឹងការតស៊ូប្រឆាំងនឹងវណ្ណៈជិះជាន់ផ្សេងៗ និងបានឯកភាពលើផែនការសម្ងហភាវូបនីយកម្មវិស័យកសិកម្ម។ បក្សកុម្មុយនីស្តកម្ពុជាបានបង្កើតឡើងជាផ្លូវការ នូវសហករណ៍នៅតាមបណ្តាតំបន់នានា ដែលពួកគេបានចូលកាន់កាប់មួយឆ្នាំក្រោយមក ពោលគឺនៅថ្ងៃទី២០ ខែឧសភា ឆ្នាំ១៩៧៣។

[០៩:៤៧:២៥]

កថាខណ្ឌ៣១៖ បន្ទាប់មកទៀត នៅ១៩៧៣ បក្សកុម្មុយនីស្តកម្ពុជា បានបង្កើតមូលដ្ឋានជួរមុខថ្មីមួយ នៅក្បែរភូមិច្រកស្តេច ខាងលិចឧដុង្គ ក្នុងស្រុកកំពង់ត្រឡាចលើ ជិតនឹងទីតាំងទីស្នាក់ការភូមិភាគពិសេសរបស់ វន វេត និងបន្ទាយបញ្ជាការរបស់ សុន សេន។ កងវរសេនាតូចចំនួន២៥ របស់បក្សកុម្មុយនីស្តកម្ពុជា បានកាន់កាប់ទីតាំងនានាជុំវិញតំបន់ឧដុង្គ និងបានបើកការវាយប្រហារទៅលើទីតាំងអតីតរាជធានីមួយនេះ នៅថ្ងៃទី០៣ ខែមីនា ឆ្នាំ១៩៧៤។

កថាខណ្ឌ៣២៖ នៅខែមិថុនា ឆ្នាំ១៩៧៤ គណៈមជ្ឈិមបានជួបប្រជុំគ្នានៅឃុំព្រែកគោក នៅជិតអតីតទីតាំងមន្ទីរក-១ និងបានសម្រេចបើកការវាយលុកផ្តាច់ព្រ័ត្រដើម្បីរំដោះភ្នំពេញ និងប្រទេសទាំងមូល។ ការវាយប្រហារផ្តាច់ព្រ័ត្រយកទីក្រុងភ្នំពេញ ត្រូវបានចាប់ផ្តើមអនុវត្តនៅខែមករា ឆ្នាំ១៩៧៥។ នៅដើមខែមីនា ឆ្នាំ១៩៧៥ ប៉ុល ពត បានបង្កើតមូលដ្ឋានបញ្ជាការមួយ នៅភូមិស្តុកទ័ល ស្រុកឧដុង្គ ឬពញាឮ ចម្ងាយប្រហែល៣០គីឡូម៉ែត្រប៉ុណ្ណោះពីភ្នំពេញ។

[០៩:៤៩:១៩]

នៅថ្ងៃទី០១ ខែមេសា ឆ្នាំ១៩៧៥ បន្ទាប់ពីកងកម្លាំងបក្សកុម្មុយនីស្តកម្ពុជាបានរំដោះយកបានអ្នកលឿង លន់ នល់ បានចុះពីតំណែង និងនិរទេសខ្លួនទៅរដ្ឋហាវ៉ៃ។ នៅព្រឹកថ្ងៃទី១៧ ខែមេសា ឆ្នាំ១៩៧៥ កងកម្លាំងបក្សកុម្មុយនីស្តកម្ពុជាបានចូលដល់ទីក្រុងភ្នំពេញ។

បាទ, សូមអរគុណលោកប្រធាន។

**ប្រធានអង្គជំនុំ៖**

បាទ អរគុណលោក ផារី។ ជាកិច្ចបន្តសូមអញ្ជើញលោក ដាវ អានសាន ឡើងអាននូវអង្គហេតុដែលបានចោទប្រកាន់នៅក្នុងដីកាដំណោះស្រាយ ដែលលើកឡើងពិភាក្សាដេញដោលនៅសវនាការវគ្គដំបូងនេះ នៅកថាខណ្ឌមួយចំនួនដែលពាក់ព័ន្ធប្រវត្តិសាវតារជនជាប់ចោទចំពោះលោក នួន ជា ពីកថាខណ្ឌ៨៦២ ដល់កថាខណ្ឌ៨៦៨ និងចាប់ពីកថាខណ្ឌ១៥៧៧ ដល់ ១៥៧៩។ ចំពោះលោក អៀង សារី កថាខណ្ឌ៩៩៤ ដល់១០០០ កថាខណ្ឌ១០៩១ និងកថាខណ្ឌចាប់ពី១៥៨៥ ដល់១៥៨៨ និងចំពោះលោក ខៀវ សំផន កថាខណ្ឌ១១២៦ ដល់១១៣០ និងចាប់ពីកថាខណ្ឌ១៥៩៨ ដល់១៦០០។ សូមអញ្ជើញ!

[០៩:៥០:៥៩]

**ក្រឡាបញ្ជី៖**

កថាខណ្ឌ៨៦២៖ នួន ជា បានចាប់ផ្តើមចូលប្រឡូកយ៉ាងសកម្មក្នុងសកម្មភាពនយោបាយនៅចុងទសវត្សរ៍ឆ្នាំ១៩៤០ នៅពេលដែលគាត់បានធ្វើការនៅក្នុងប្រទេសថៃ។ នួន ជា បានចូលរួមជាមួយអង្គការយុវជនប្រជាធិបតេយ្យដែលស្ថិតនៅក្រោមបក្សកុម្មុយនីស្តថៃ ជាបក្សដែលគាត់បានចូលជាសមាជិកផងដែរ។

កថាខណ្ឌ៨៦៣៖ បន្ទាប់មក នួន ជា បានត្រឡប់មកប្រទេសកម្ពុជាដើម្បីចូលរួមចលនាតស៊ូរបស់បក្សកុម្មុយនីស្តឥណ្ឌូចិននៅតំបន់សំឡូត ដែលគាត់ទទួលបន្ទុកខាងឃោសនានៅក្នុងបក្ស។ នៅពេលនោះ គាត់ក៏បានទាក់ទងយ៉ាងសកម្មជាមួយបក្សកុម្មុយនីស្តវៀតណាម និងសមាសភាពកុម្មុយនីស្តនៃចលនាខ្មែរឥស្សរៈឆ្នាំ១៩៥០ ដល់ឆ្នាំ១៩៥៣។ គាត់នៅតែជាសមាជិកសកម្មម្នាក់ក្នុងចលនាកុម្មុយនីស្តនេះ បន្ទាប់ពីការបង្កើតបក្សប្រជាជនបដិវត្តន៍កម្ពុជានាឆ្នាំ១៩៥១។ ចាប់ពីឆ្នាំ១៩៥១ ដល់ឆ្នាំ១៩៥៣ គាត់បានសិក្សាវគ្គនយោបាយនៅភាគខាងត្បូង និងភាគខាងជើងនៃប្រទេសវៀតណាម។ បន្ទាប់ពីការចុះហត្ថលេខាលើកិច្ចព្រមព្រៀងទីក្រុងហ្សឺណែវ ជាមួយនឹងមុខរបរជំនួញផងនោះ នួន ជា ជាមេដឹកនាំម្នាក់នៃចលនាកុម្មុយនីស្តសម្ងាត់នៅទីក្រុងភ្នំពេញ។

[០៩:៥២:២៨]

កថាខណ្ឌ៨៦៤៖ នៅខែកញ្ញា ឆ្នាំ១៩៦០ នួន ជា ត្រូវបានជ្រើសរើសជាអនុលេខាបក្សប្រជាជនបដិវត្តកម្ពុជា ដែលក្រោយមកបានប្តូរឈ្មោះថាជា “បក្សពលករខ្មែរ” និងក្រោយមកទៀត ប្តូរឈ្មោះទៅជា “បក្សកុម្មុយនីស្តកម្ពុជា” ជាមួយ សាឡុត ស និង ទូ សាមុត។ នួន ជា នៅតែកាន់តំណែងអនុលេខានៅពេល សាឡុត ស បានក្លាយទៅជាលេខាបក្ស បន្ទាប់ពីបាត់ខ្លួន ទូ សាមុត នៅឆ្នាំ១៩៦២។

កថាខណ្ឌ៨៦៥៖ បន្ទាប់ពីការទម្លាក់សម្តេចនរោត្តម សីហនុ នៅថ្ងៃទី១៨ ខែមីនា ឆ្នាំ១៩៧០ នួន ជា បានគេចខ្លួនចេញពីភ្នំពេញ ដើម្បីចូលរួមចលនាព្រៃម៉ាគីជាមួយនឹងមេដឹកនាំដទៃទៀត ដូចជា សាឡុត ស, សុន សេន, តាម៉ុក និង សោ ភឹម។ មេដឹកនាំបក្សកុម្មុយនីស្តកម្ពុជាទាំងនេះ បានបង្កើតទីស្នាក់ការកណ្តាលរបស់ពួកគេជាបន្តបន្ទាប់ នៅក្នុងខេត្តផ្សេងៗមួយចំនួនដូចជា ខេត្តកំពង់ធំ ខេត្តកំពង់ចាម និងខេត្តកំពង់ឆ្នាំង។

កថាខណ្ឌ៨៦៦៖ ចន្លោះឆ្នាំ១៩៧០ ដល់ឆ្នាំ១៩៧៥ នួន ជា គឺជាអនុបញ្ជាការយោធាជាន់ខ្ពស់កងទ័ពប្រជាជននៃចលនារំដោះជាតិកម្ពុជា និងជាប្រធានផ្នែកនយោបាយរបស់កងទ័ព។ នួន ជា ទទួលបន្ទុកជាពិសេសផងដែរ ក្នុងការធ្វើការទំនាក់ទំនងជាមួយនឹងវៀតណាម។

[០៩:៥៤:១៤]

កថាខណ្ឌ៨៦៧៖ នៅដើមខែមេសា ឆ្នាំ១៩៧៥ នួន ជា នៅជាមួយប៉ុល ពត និងមេដឹកនាំយោធា និងនយោបាយសំខាន់ៗផ្សេងទៀតរបស់បក្សកុម្មុយនីស្តកម្ពុជា ដូចជា កុយ ធួន, សោ ភឹម, តា ម៉ុក និង សុន សេន រហូតដល់ការកាន់កាប់ទីក្រុងភ្នំពេញ។

កថាខណ្ឌ៨៦៨៖ នៅក្នុងរបបកម្ពុជាប្រជាធិបតេយ្យ នួន ជា ត្រូវបានគេហៅឈ្មោះខុសៗគ្នា ដោយប្រើនាមត្រកូលរបស់គាត់ នួន ហៅថា បងនួន ឬអ៊ំនួន ឬក៏ប្រើថ្នាក់នៅក្នុងបក្សរបស់គាត់ហៅថា សមមិត្តអនុលេខា។ នួន ជា ត្រូវបានគេហៅឈ្មោះហៅក្រៅផងដែរ "បងទី២"។

[០៩:៥៥:០៦]

កថាខណ្ឌ១៥៧៧៖ នួន ជា កើតនៅថ្ងៃទី៧ ខែកក្កដា ឆ្នាំ១៩៦២-- (សុំទោស) ឆ្នាំ១៩២៦ នៅ ភូមិវត្តគរ ឃុំវត្តគរ ស្រុកសង្កែ ខេត្តបាត់ដំបង។ នៅពេលចូលខ្លួនដំបូង នួន ជា បានឆ្លើយប្រាប់ថា ឈ្មោះកំណើតរបស់គាត់គឺ ឡៅ គឹមឡន ដោយបញ្ជាក់ថាឈ្មោះនេះឈប់ប្រើយូរហើយ។ នួន ជា គឺ ជាកូនទីបី ក្នុងចំណោមបងប្អូនចំនួន៩នាក់។ ឪពុកគាត់មានឈ្មោះថា ឡៅ លីវ ជាខ្មែរស្រឡាយចិន ជនជាតិហាន ប្រកបរបរទិញលក់ពោតនៅខេត្តបាត់ដំបង។ ម្តាយគាត់ឈ្មោះ ដុស ពាញ ជាជាង កាត់ដេរ។ ម្តាយគាត់ក៏មានដើមកំណើតកូនកាត់ចិនផងដែរ ប៉ុន្តែ នួន ជា ត្រូវបានចិញ្ចឹមបីបាច់នៅក្នុង គ្រួសារចម្រុះវប្បធម៌ដែលនិយាយភាសាខ្មែរ។

កថាខណ្ឌ១៥៧៨៖ នួន ជា បានរៀបការជាមួយ លី គឹមសេង និងមានកូនបីនាក់ ថែមទាំងមាន កូនចិញ្ចឹមម្នាក់ផងដែរ។

កថាខណ្ឌ១៥៧៩៖ បន្ទាប់ពីបានទទួលសញ្ញាប័ត្របឋមសិក្សា នួន ជា បានបន្តការសិក្សាថ្នាក់ មធ្យមនៅខេត្តបាត់ដំបង។ ការសិក្សានេះត្រូវបានផ្អាកនៅក្នុនសម័យសង្គ្រាមលោកលើកទីពីរ នៅឆ្នាំ ១៩៤១ នៅពេលខេត្តបាត់ដំបងស្ថិតនៅក្រោមការកាន់កាប់របស់ប្រទេសថៃ ដែលជាសម្ព័ន្ធមិត្តរបស់ ជប៉ុន។

[០៩:៥៦:៤៧]

ដូចនេះ នួន ជា បានសិក្សាភាសាថៃ បន្ទាប់មកបានធ្វើដំណើរទៅទីក្រុងបាងកក ដែលនៅទីនោះ គាត់បានរស់នៅជាមួយនឹងព្រះសង្ឃខ្មែរជាច្រើនអង្គនៅក្នុងវត្តមួយ។ នួន ជា បានសិក្សាមុខវិជ្ជាច្បាប់មិន បានចប់ទេ នៅសាកលវិទ្យាល័យធម្មសាធ នាទីក្រុងបាងកក ដោយប្រើឈ្មោះថា រ៉ុងឡឹត ឡៅឌី និង

បានធ្វើការងារក្រៅម៉ោងក្នុងតួនាទីជាស្មៀន ដោយដំបូងនៅក្រសួងហារិញ្ញវត្ថុ បន្ទាប់មកនៅក្រសួងការបរទេសរបស់ថៃពីឆ្នាំ១៩៤៥ ដល់ឆ្នាំ១៩៤៩ មុនគាត់ចូលមកក្នុងប្រទេសកម្ពុជាវិញនាឆ្នាំ១៩៥០ ជាពេលដែលគាត់ចូលប្រឡូកនៅក្នុងសកម្មភាពបដិវត្តន៍។

កថាខណ្ឌ៩៩៤៖ អៀង សារី បានចាប់ផ្ដើមចូលរួមក្នុងសកម្មភាពនយោបាយក្នុងទសវត្សរ៍ឆ្នាំ១៩៤០ ខណៈគាត់ជានិស្សិតវិទ្យាល័យព្រះស៊ីសុវត្ថិ។ ក្នុងអំឡុងពេលនោះ គាត់បានជួបជាមួយ អៀង ធីរិទ្ធ និង សាឡុត ស។

កថាខណ្ឌ៩៩៥៖ ក្នុងឆ្នាំ១៩៥០ អៀង សារី បានធ្វើដំណើរទៅទីក្រុងប៉ារីស ដើម្បីសិក្សា។ នាពេលនោះ អៀង សារី បានក្លាយជាសមាជិកបក្សកុម្មុយនីស្តបារាំងជាមួយ ប៉ុល ពត និង ខៀវ សំផន ហើយជាសមាជិកស្ថាបនិកម្នាក់នៃក្រុមម៉ាក្សនិយម ក្នុងស្រទាប់និស្សិតខ្មែរ។

កថាខណ្ឌ៩៩៦៖ ក្រោយពីត្រឡប់មកដល់ទីក្រុងភ្នំពេញវិញ ក្នុងឆ្នាំ១៩៥៧ អៀង សារី បានចូលរួមជាមួយគណៈបក្សបដិវត្តន៍ប្រជាជនកម្ពុជា។

អៀង សារី គឺជាសាស្ត្រាចារ្យប្រវត្តិវិទ្យា និងភូមិវិទ្យានៅក្នុងអនុវិទ្យាល័យឯកជនមួយឈ្មោះកម្ពុជបុត្រ រហូតដល់គាត់លាក់ខ្លួនក្នុងឆ្នាំ១៩៦៣។

កថាខណ្ឌ៩៩៧៖ ក្នុងឆ្នាំ១៩៦០ អៀង សារី បានចូលរួមក្នុងសមាជលើកទីមួយរបស់បក្សពលករខ្មែរ ដែលជាឈ្មោះថ្មីរបស់បក្សប្រជាជនបដិវត្តន៍កម្ពុជា និងជាឈ្មោះមុនរបស់បក្សកុម្មុយនីស្តកម្ពុជា។ គាត់ត្រូវបានជ្រើសរើសជាសមាជិកគណៈមជ្ឈិម និងជាសមាជិកត្រៀមនៃគណៈមជ្ឈិម។ ដូច្នេះបានក្លាយជាមនុស្សលំដាប់ទីបួនរបស់បក្ស។

[០៩:៥៩:២៨]

ក្នុងអំឡុងសមាជលើកទីពីររបស់បក្សក្នុងឆ្នាំ១៩៦៣ អៀង សារី ត្រូវបានជ្រើសរើសជាសមាជិកពេញសិទ្ធិនៃគណៈអចិន្ត្រៃយ៍។

កថាខណ្ឌ៩៩៨៖ ក្នុងខែមេសា ឆ្នាំ១៩៦៣ ក្រោយពីលុប បានចាត់ទុកគាត់ជាអ្នកឆ្វេងនិយមម្នាក់ក្នុងចំណោមអ្នកឆ្វេងនិយមចំនួន៣៤នាក់ អៀង សារី បានភៀសខ្លួនទៅព្រំដែនវៀតណាម ដើម្បីចូលរួមជាមួយ សុន សេន និង ប៉ុល ពត។

ក្នុងឆ្នាំ១៩៦៦ អៀង សារី និងមេដឹកនាំបក្សកុម្មុយនីស្តកម្ពុជាផ្សេងទៀតបានប្ដូរទីតាំងនៅក្នុងខេត្តរតនគិរីភូមិភាគឦសានជាទីកន្លែងដែលទីស្នាក់ការថ្មីរបស់គណៈមជ្ឈិមបានតាំងនៅ។ ដូច្នេះ អៀង

សារី បានក្លាយជាលេខាភូមិភាគឦសាន។

កថាខណ្ឌ៩៩៩៖ ក្នុងឆ្នាំ១៩៧០ អៀង សារី បានធ្វើដំណើរទៅទីក្រុងហាណូយ ជាទីកន្លែងដែលគាត់បង្កើតស្ថានីយវិទ្យុសំឡេងរណសិរ្សបង្រួបបង្រួមជាតិកម្ពុជា ដែលគ្រប់គ្រងដោយ អៀង ធីរិទ្ធ។ អៀង សារី បានធ្វើដំណើរពីទីក្រុងហាណូយទៅទីក្រុងប៉េកាំង ដើម្បីចងសម្ព័ន្ធភាពបក្សកុម្មុយនីស្តចិន។ នៅឆ្នាំ១៩៧១ អៀង សារី បានតាំងមូលដ្ឋានជាអចិន្ត្រៃយ៍នៅទីក្រុងប៉េកាំង ស្របពេលជាមួយគ្នានោះគាត់បានធ្វើការជាបេសកជនពិសេសនៃអ្នកតស៊ូផ្ទៃក្នុងនៅប៉េកាំង និងទទួលបន្ទុកធ្វើទំនាក់ទំនងជាមួយ (លុប)។

[១០:០១:១០]

តួនាទី និងមុខងាររបស់ អៀង សារី ក្នុងអំឡុងពេលដែលគាត់ស្នាក់នៅប្រទេសចិននឹងត្រូវបាននិយាយលម្អិតនៅក្នុងផ្នែកដែលមានចំណងជើងថា “អ្នកធ្វើមាតុភូមិនិវត្តន៍”។ ក្នុងអំឡុងពេលនោះ អៀង សារី បានមកកម្ពុជាចំនួនពីរដង។ ម្តងនៅក្នុងឆ្នាំ១៩៧៣ នាពេលដែលគាត់អមដំណើរ (លុប) ទៅពិនិត្យមើលតំបន់រំដោះ និងម្តងទៀតក្នុងឆ្នាំ១៩៧៤។ គាត់ត្រឡប់មកកម្ពុជាជាអចិន្ត្រៃយ៍ក្នុងខែមេសា ឆ្នាំ១៩៧៥។

កថាខណ្ឌ១០០០៖ ក្នុងអំឡុងបក្សកុម្មុយនីស្តកម្ពុជា អៀង សារី បានប្រើឈ្មោះបដិវត្តន៍របស់គាត់គឺ វ៉ាន់។

កថាខណ្ឌ១០៩១៖ ក្នុងឆ្នាំ១៩៧០ បន្ទាប់ពីការទម្លាក់សម្តេច សីហនុ ពីប្រមុខរដ្ឋរបស់ប្រទេសកម្ពុជា ប្រជាជនកម្ពុជាជាច្រើនបានចូលរួមជាមួយសម្តេចក្នុងពេលដែលទ្រង់គង់និរទេសនៅទីក្រុងប៉េកាំង។ សម្តេច សីហនុ បានអំពាវនាវទៅកាន់ប្រជាជនកម្ពុជាឲ្យចូលរួមជាមួយទ្រង់ដើម្បីបង្កើតជារណសិរ្សរួបរួមជាតិកម្ពុជា ដើម្បីទប់ទល់នឹងរដ្ឋាភិបាលថ្មីនៅទីក្រុងភ្នំពេញ ដែលក្រោយមកបានក្លាយទៅជាសាធារណរដ្ឋខ្មែរដែលមាន លន់ នល់ ជាប្រធានាធិបតី។

[១០:០២:៣៤]

បក្សកុម្មុយនីស្តកម្ពុជាដែលនៅតែលាក់កំបាំងនៅឡើយ បានចូលរួម និងបង្កប់នៅក្នុងរណសិរ្សរួបរួមជាតិកម្ពុជា និងរាជរដ្ឋាភិបាលរួមរួបជាតិកម្ពុជា។ (លុប) និយាយថា “នៅឆ្នាំ១៩៧១ អៀង សារី បានប្រើប្រាស់មនោសញ្ចេតនាស្នេហាជាតិក្នុង--

**អ្នកបកប្រែ៖** សាន សុំឲ្យ *ស្លូដោន* បន្តិច សម្រាប់ឲ្យខាង *វីឌត* បាន *វីឌត* ទាន់ទាន!

[១០:០៣:០៧]

**ប្រធានអង្គជំនុំ៖**

យឺតៗតិច!

**ក្រឡាបញ្ជី៖**

សូមអនុញ្ញាតបន្តកថាខណ្ឌ១០៩១ ចាប់ពីកន្លែង “លុប”។ (លុប) និយាយថា “នៅឆ្នាំ១៩៧១ អៀង សារី បានប្រើប្រាស់មនោសញ្ចេតនាស្នេហាជាតិ--

**ប្រធានអង្គជំនុំ៖**

អត់ៗមានបកប្រែទេ!

មន្ត្រីតុលាការសម្របសម្រួល!

អញ្ជើញៗ ដាវ អានសាន! មើល!ៗ ភ្លើងផង មើលចុច--

**ក្រឡាបញ្ជី៖**

សូមអនុញ្ញាតបន្តកថាខណ្ឌ១០៩១៖ (លុប) និយាយថា “នៅឆ្នាំ១៩៧១ អៀង សារី បានប្រើប្រាស់មនោសញ្ចេតនាស្នេហាជាតិក្នុងការបំពាក់បំប៉នប្រជាជនកម្ពុជា ដែលបានចូលរួមជាមួយរណសិរ្សរួបរួមជាតិកម្ពុជា និងបានរៀបចំឲ្យពួកគេបានធ្វើដំណើរទៅទីក្រុងប៉េកាំង ដែលភាគច្រើនជនទាំងនោះ គឺជាបញ្ញាជនដែលមកពីទីក្រុងប៉ារីស។ បន្ទាប់មក អៀង សារី បានរកអ្នកស្ម័គ្រចិត្តជាច្រើនចេញពីក្រុមនេះ ដើម្បីចូលរួមរណសិរ្សនៅប្រទេសកម្ពុជា ដូច្នេះហើយចាប់ពីដើមទសវត្សរ៍ឆ្នាំ១៩៧០ មក ប្រជាជនកម្ពុជាដែលនៅបរទេស បានចាប់ផ្តើមវិលត្រឡប់មកប្រទេសកម្ពុជាវិញតាមទីក្រុងប៉េកាំង។

[១០:០៤:៥១]

កថាខណ្ឌ១៩៨៥៖ អៀង សារី ឈ្មោះដើមកំណើត គឹម ទ្រឹង កើតថ្ងៃទី២៤ ខែតុលា ឆ្នាំ១៩២៥ នៅភូមិលឿងវ៉ា ខេត្តត្រាវិញ វៀតណាមខាងត្បូង (កូសាំងស៊ីន)។ ក្នុងពេលបង្ហាញខ្លួនលើកដំបូង អៀង សារី បាននិយាយថា គាត់បានប្តូរស្ថានភាពអត្រានុកូលដ្ឋាន ដើម្បីទទួលបានសំបុត្រកំណើតខ្មែរ និងដើម្បីអាចប្រឡងចូលរៀនវិទ្យាព្រះស៊ីសុវត្ថិ។

ដូច្នេះជាផ្លូវការ អៀង សារី កើតនៅថ្ងៃទី០១ ខែមករា ឆ្នាំ១៩៣០ នៅភូមិបារាយណ៍ ខេត្តព្រៃវែង ប្រទេសកម្ពុជា។

[១០:០៥:៥២]

កថាខណ្ឌ១៥៨៦៖ ឪពុករបស់ អៀង សារី ឈ្មោះ គឹម រៀម ជាខ្មែរកម្ពុជាក្រោម និងម្ដាយឈ្មោះ ត្រាន់ ធិឡឺយ ជាកូនកាត់ចិន-វៀតណាម។ នៅពេលឪពុកគាត់ស្លាប់ ដែលពេលនោះគាត់នៅក្មេងនៅឡើយ អៀង សារី បានមករស់នៅជាមួយសាច់ញាតិក្នុងខេត្តព្រៃវែង ប្រទេសកម្ពុជា។ ដូច្នេះគាត់បានប្ដូរឈ្មោះពី គឹម ទ្រឹង ទៅជា អៀង សារី។

កថាខណ្ឌ១៥៨៧៖ នៅពេលមកដល់ភ្នំពេញនាដើមទសវត្សរ៍ឆ្នាំ១៩៤០ អៀង សារី បានបន្តការសិក្សានៅវិទ្យាព្រះស៊ីសុវត្ថិ ជាទីកន្លែងដែលគាត់បានស្គាល់អនាគតភរិយារបស់គាត់ឈ្មោះ អៀង ធីរិទ្ធ ដែលជាសិស្សក្នុងវិទ្យាល័យជាមួយគ្នា។

[១០:០៦:៥០]

មុនពេលចាកចេញទៅប្រទេសបារាំង គាត់ទទួលបានអាហារូបករណ៍ ដើម្បីទៅសិក្សានៅទីនោះ អៀង សារី បានភ្ជាប់ពាក្យជាមួយ អៀង ធីរិទ្ធ ហើយបានរៀបការជាមួយគ្នានៅទីក្រុងប៉ារីស ក្នុងឆ្នាំ១៩៥៣។ អ្នកទាំងពីរមានកូនបួននាក់ ស្រីបី ប្រុសមួយ។

កថាខណ្ឌ១៥៨៨៖ ក្រោយពេលត្រឡប់មកភ្នំពេញវិញ នៅឆ្នាំ១៩៥៧ អៀង សារី បានធ្វើជាសាស្ត្រាចារ្យប្រវត្តិវិទ្យា និងភូមិវិទ្យានៅអនុវិទ្យាឯកជនឈ្មោះ “កម្ពុជបុត្រ” រហូតដល់ពេលគាត់ចូលលាក់ខ្លួនក្នុងឆ្នាំ១៩៦៣។

ខៀវ សំផន សាវតារ៖

កថាខណ្ឌ១១២៦៖ ខៀវ សំផន ហៅ ហែម, ខាង ឬ ណន ជាសកម្មជនចាស់ទុំមួយរូបនៅក្នុងចលនាកុម្មុយនីស្តកម្ពុជា។ ខណៈដែលកំពុងសិក្សានៅប្រទេសបារាំងក្នុងទសវត្សរ៍ឆ្នាំ៥០ គាត់ចាប់ផ្ដើមចូលក្នុងឆាកនយោបាយ។ ខៀវ សំផន គាត់បានចូលរួមជាមួយក្រុមម៉ាក្ស-លេនីន និយម ដែលបានបង្កើតដោយ អៀង សារី។ ប៉ុល ពត, សុន សេន និង អៀង ធីរិទ្ធ ក៏ជាសមាជិកក្រុមនោះផងដែរ។ គាត់ក៏បានចូលជាសមាជិកបក្សកុម្មុយនីស្តបារាំងដែរ។

[១០:០៨:៣១]

កថាខណ្ឌ១១២៧៖ ពេលត្រឡប់មកប្រទេសកម្ពុជាវិញ ខៀវ សំផន មានមុខរបរជាគ្រូបង្រៀន។ នៅឆ្នាំ១៩៥៩ គាត់បង្កើតកាសែតជាភាសាបារាំងឈ្មោះ *ឡូបស៊ែវ៉ាទ័រ* (អ្នកសង្កេតការណ៍) ដែលគាំទ្រ និងផ្ដល់ថវិកាដល់សកម្មជនកុម្មុយនីស្តនៃប្រទេសកម្ពុជា។ ក្នុងឆ្នាំ១៩៦០ ខៀវ សំផន ត្រូវបានតាមដានយ៉ាងប្រកិតពីនគរបាល ហើយបានទទួលរងនូវការបំពារបំពាន ដែលក្នុងពេលនោះគាត់ត្រូវបានប្រមាថ

ជាសាធារណៈ ដោយសារបានបោះពុម្ពផ្សាយអត្ថបទរិះគន់រដ្ឋាភិបាលនៅលើទំព័រកាសែត ឡុបស៊ែវ៉ាទ័រ។ ក្នុងខែសីហា ឆ្នាំ១៩៦០ ខៀវ សំផន ត្រូវឃុំខ្លួនដោយគ្មានការជំនុំជម្រះអស់រយៈពេលពីរខែ។

កថាខណ្ឌ១១២៨៖ នៅឆ្នាំ១៩៦២ ខៀវ សំផន បានចូលរួមជាមួយចលនាសង្គមរាស្ត្រនិយម របស់សម្តេចនរោត្តម សីហនុ ហើយបានជាប់ឆ្នោតជាតំណាងរាស្ត្រប្រចាំស្រុកស្អាងខេត្តកណ្តាល និង ត្រូវបានតែងតាំងជារដ្ឋលេខាធិការក្រសួងពាណិជ្ជកម្ម។ ទោះបីយ៉ាងក៏ដោយ គាត់ត្រូវបានបង្ខំឲ្យលា លែងពីតំណែងនៅឆ្នាំ១៩៦៣។ ខៀវ សំផន បានជាប់ឆ្នោតជាតំណាងរាស្ត្រជាថ្មីម្តងទៀតនៅឆ្នាំ១៩៦៦ ប៉ុន្តែ តំណែងរបស់គាត់មិនបានស្ថិតស្ថិរទេ ដោយសារមានជម្លោះ និងអស្ថិរភាពនៅក្នុងបក្ស។ ដោយសារត្រូវបានចោទប្រកាន់ថា ជាអ្នកញុះញង់ឲ្យកសិករបះបោរនៅស្រុកសំឡូត។ នាឆ្នាំ១៩៦៦ ខៀវ សំផន ត្រូវបានកោះហៅឲ្យទៅបង្ហាញខ្លួននៅចំពោះមុខតុលាការយោធា។

[១០:១០:៤៧]

ខៀវ សំផន បានភៀសខ្លួនចេញពីទីក្រុងភ្នំពេញនៅថ្ងៃទី២២ ខែមេសា ឆ្នាំ១៩៦៧ ដោយការភ័យ ខ្លាចការគំរាមចាប់ខ្លួន គាត់បានទៅជ្រកកោន នៅភូមិជាងតុង ស្រុកសំរោងទង ខេត្តកំពង់ស្ពឺ ក្រោម ការការពាររបស់ តាម៉ុក។ ខៀវ សំផន បានរស់នៅទីនោះរហូតដល់ឆ្នាំ១៩៧០។

កថាខណ្ឌ១១២៩៖ ក្រោយពីការផ្តួលរំលំសម្តេចនរោត្តម សីហនុ នៅឆ្នាំ១៩៧០ ហើយនៅពេល រណសិរ្សរួបរួមជាតិកម្ពុជាត្រូវបានបង្កើត ខៀវ សំផន បានចូលរួមជាមួយ ប៉ុល ពត, នួន ជា និងមេដឹក នាំផ្សេងទៀតនៃបក្សកុម្មុយនីស្ត នៅនាទីស្នាក់ការកណ្តាលរបស់បក្សនេះ នៅតំបន់ចន្លោះខេត្តកំពង់ធំ និងខេត្តកំពង់ចាម។ ខៀវ សំផន ត្រូវបានតែងតាំងឲ្យកាន់តំណែងជាន់ខ្ពស់មួយចំនួន រួមមាន ជាអនុ ប្រធានរណសិរ្សរួបរួមជាតិកម្ពុជា និងជាអគ្គមេបញ្ជាការនៃកងទ័ពរំដោះប្រជាជនកម្ពុជា។ នៅថ្ងៃទី៥ ខែឧសភា ឆ្នាំ១៩៧០ ខៀវ សំផន ត្រូវបានតែងតាំងជាផ្លូវការឧបនាយករដ្ឋមន្ត្រី និងជារដ្ឋមន្ត្រីការពារ ជាតិរបស់រាជរដ្ឋាភិបាលរួបរួមជាតិកម្ពុជា ហើយក្នុងតួនាទីនេះ ខៀវ សំផន បានដឹកនាំគណៈប្រតិភូ នានាទៅបរទេស។ ខៀវ សំផន បានទទួលបន្ទុកផងដែរ ក្នុងការធ្វើទំនាក់ទំនងជាមួយសម្តេច នរោត្តម សីហនុ។

[១០:១២:៤១]

កថាខណ្ឌ១១៣០៖ នៅឆ្នាំ១៩៧១ ខៀវ សំផន បានក្លាយជាសមាជិក បេក្ខជននៃគណៈមជ្ឈិម បក្សកុម្មុយនីស្តកម្ពុជា។ នៅថ្ងៃទី៩ ខែកញ្ញា ឆ្នាំ១៩៧២ ខៀវ សំផន, ហ៊ូ យន់, ហ៊ូ នឹម បានអំពាវនាវឲ្យ

ព្រះសង្ឃ និងប្រជាជនទីក្រុងភ្នំពេញ ព្រមទាំងប្រជាជនតាមខេត្តផ្សេងទៀត ដែលស្ថិតនៅក្រោមការគ្រប់គ្រងរបស់ខ្មាំងលើបឡើងកម្ទេចខ្មាំង។ រវាងខែមករា និងខែមេសា ឆ្នាំ១៩៧៥ ខៀវ សំផន បានប្រកាសជាសាធារណៈជាច្រើនលើក អំពីជ័យជម្នះដ៏ធំសម្បើម និងបានអំពាវនាវឲ្យប្រជាជនទីក្រុងភ្នំពេញក្រោកឡើងតស៊ូ ដើម្បីរំដោះជាតិ និងបានប្រកាសថា "រណសិរ្សរួបរួមជាតិកម្ពុជា និងរាជរដ្ឋាភិបាលរួបរួមជាតិកម្ពុជា អាចនឹងកាន់កាប់ក្រុងភ្នំពេញនាពេលឆាប់ៗ"។ សូមអរគុណប្រធាន។

[១០:១៣:៤៩]

នៅមានកថាខណ្ឌចំនួន៣ទៀត។

កថាខណ្ឌ១៥៩៨៖ ខៀវ សំផន ហៅ ហែម ឬ ខាង ឬ ណន កើតថ្ងៃទី២៧ ខែកក្កដា ឆ្នាំ១៩៣១ នៅខេត្តស្វាយរៀង។ ឪពុករបស់គាត់ឈ្មោះ ខៀវ ឡុង និងម្តាយគាត់ឈ្មោះ លី គង់។ ឪពុករបស់ ខៀវ សំផន ជាមន្ត្រីរាជការ រីឯម្តាយដែលមានដើមជាជនជាតិចិន បានប្រកបរបរជាអ្នកលក់បន្លែ បន្ទាប់ពីមរណភាពរបស់ស្វាមីគាត់នៅឆ្នាំ១៩៤៧។

កថាខណ្ឌ១៥៩៩៖ នៅឆ្នាំ១៩៥៣ ខៀវ សំផន បានទៅបន្តការសិក្សាថ្នាក់ឧត្តមសិក្សានៅប្រទេសបារាំង។ នៅឆ្នាំ១៩៥៩ ខៀវ សំផន បានបញ្ចប់និក្ខេបបទថ្នាក់បណ្ឌិតក្រោមចំណងជើងថា "សេដ្ឋកិច្ចប្រទេសកម្ពុជា និងការអភិវឌ្ឍបែបឧស្សាហកម្ម"។ ពេលនៅទីក្រុងប៉ារីស ខៀវ សំផន បានចាប់ផ្តើមចូលរួមជាសកម្មជននយោបាយ។

[១០:១៥:១៤]

កថាខណ្ឌ១៦០០៖ នៅឆ្នាំ១៩៦២ បន្ទាប់ពីបានត្រឡប់មកកម្ពុជាវិញ ខៀវ សំផន បានជាប់ឆ្នោតជាតំណាងរាស្ត្រនៅខេត្តកណ្តាល ហើយត្រូវបានតាំងជារដ្ឋលេខាធិការ ទទួលបន្ទុកការងារពាណិជ្ជកម្ម។ បន្ទាប់ពីពេលរដ្ឋាភិបាលជួបអស្ថិរភាព ក្នុងខែមេសា ឆ្នាំ១៩៦៧ ខៀវ សំផន ត្រូវបានចោទប្រកាន់ដោយតុលាការយោធា និងប្រឈមមុខនឹងការចាប់ខ្លួន។ ហេតុការណ៍នេះបានជំរុញឲ្យគាត់គេចខ្លួនពីទីក្រុងភ្នំពេញ នៅថ្ងៃទី២២ ខែមេសា ឆ្នាំ១៩៦៧។ គាត់បានគេចខ្លួនទៅរស់នៅជាមួយ តាម៉ុក ក្នុងភូមិជាងតុង ខេត្តកំពង់ស្ពឺ ជាកន្លែងដែលគាត់រស់នៅរហូតដល់ឆ្នាំ១៩៧០។

សូមអរគុណលោកប្រធាន។

**ប្រធានអង្គជំនុំ៖**

អរគុណលោក ដាវ អានសាន។

ជាកិច្ចបន្តអង្គជំនុំជម្រះសូមសួរទៅសហព្រះរាជអាជ្ញា អំពីអង្គហេតុដែលបានព្រមព្រៀងគ្នា ឬ អង្គហេតុដែលមិនមានការជំទាស់តវ៉ា ដែលធ្វើឡើងរវាងសហព្រះរាជអាជ្ញា និងមេធាវីការពារជនជាប់ចោទ។ តើមានដែរឬទេ?

**លោក ឌេល លីសាក់៖**

អរុណសួស្តីលោកប្រធាន លោក លោកស្រីចៅក្រម។ តាមអ្វីដែលខ្ញុំដឹងនោះ គឺថាភាគីមិនមានការឯកភាពគ្នាទៅលើអង្គហេតុនោះទេ។ សូមអរគុណ។

[១០:១៦:៥៩]

**ប្រធានអង្គជំនុំ៖**

បាទ, អរគុណ សហព្រះរាជអាជ្ញារងអន្តរជាតិ។

សូមអញ្ជើញលោកស្រីចៅក្រម!

**ចៅក្រម ស៊ីលវៀ ខាតវ៉ាយថ៍៖**

សូមអរគុណលោកប្រធាន។ ខ្ញុំបានដឹងថា អង្គហេតុសង្ខេបមួយចំនួនត្រូវបានទទួលស្គាល់ គឺឯកសារ E99/21.3 ដែលបានដាក់ដោយជនជាប់ចោទ។ តើលោកមានឯកសារនោះដែរឬទេ?

**លោក ឌេល លីសាក់៖**

យើងអត់មានឯកសារនោះទេ ប៉ុន្តែយើងអាចយកឯកសារនោះបានភ្លាមៗ។

[១០:១៨:២០]

**ចៅក្រម ស៊ីលវៀ ខាតវ៉ាយថ៍៖**

ខ្ញុំសូមបញ្ជាក់ថា យើងបានចែកជូននូវអង្គហេតុដែលយើងស្នើសុំថាឲ្យមានការឯកភាពគ្នា ហើយខ្ញុំដឹងថា លោក អៀង សារី បានឆ្លើយតបទៅលើឯកសារនោះហើយ ក៏ប៉ុន្តែមិនមានការឯកភាពពីជនជាប់ចោទផ្សេងទៀតនោះទេ។ សូមអរគុណ។

**លោក ម៉ៃខល កាណាវាស៖**

អរុណសួស្តីលោក លោកស្រីចៅក្រម អស់លោក លោកស្រីជាទីគោរព។ យើងពិតជាបានដាក់នៅបញ្ជីនៃអង្គហេតុដែលបានព្រមព្រៀងគ្នា។ ខ្ញុំមិនបានត្រៀមខ្លួននៅក្នុងថ្ងៃនេះ ក្នុងការរៀបរាប់ទៅលើអង្គហេតុដែលបានព្រមព្រៀងគ្នានោះទេ។ ក៏ប៉ុន្តែវាមានការលើកឡើង យើងខ្ញុំបានលើកឡើងអំពីប្រវត្តិរបស់លោក អៀង សារី មួយចំនួនដែលពាក់ព័ន្ធទៅនឹងនីតិវិធីនេះ ហើយខ្ញុំគិតថាដោយសារតែយើង

មានពេលវេលានោះ គឺសហព្រះរាជអាជ្ញាអាចធ្វើការស្រាវជ្រាវរកឯកសារនោះបាន។

សូមអរគុណ។

[១០:១៩:២៣]

**ប្រធានអង្គជំនុំ៖**

អរគុណលោកមេធាវីដែលបានធ្វើការបង្ហាញលើចំណុចនេះ ហើយដោយសារបញ្ហានេះមិនទាន់មានការពិនិត្យជាក់លាក់ទៅលើឯកសារ ដែលលោកមេធាវីការពារក្តីលោក អៀង សារី បានដាក់។ ដូច្នេះបញ្ហានេះគឺអង្គជំនុំជម្រះនឹងលើកទៅឲ្យសហព្រះរាជអាជ្ញា ហើយនិងមេធាវីការពារក្តីលើកឡើងនៅក្នុងអំឡុងពេលមុននឹងចាប់ផ្តើមនៃការសួរដេញដោល ចំពោះជនជាប់ចោទ អៀង សារី ពីព្រោះបញ្ហានេះមានតែមួយទេ គឺមេធាវីការពារក្តីរបស់លោក អៀង សារី ដែលមានបានបង្ហាញនូវអង្គហេតុមិនមានការជំទាស់មួយចំនួន ប៉ុន្តែដោយសារខាង--ម្យ៉ាងខាងសហព្រះរាជអាជ្ញាមិនទាន់បានរៀបចំនូវបញ្ហានេះនៅឡើយ។ ដូច្នេះសហព្រះរាជអាជ្ញាជ្រាបថា បញ្ហានេះយើងនឹងលើកយកមកបង្ហាញភាគី បង្ហាញជូនដល់អង្គសវនាការមុនពេលចាប់ផ្តើមសួរដេញដោលចំពោះជនជាប់ចោទ អៀង សារី។

ជាកិច្ចបន្តអង្គជំនុំជម្រះអនុញ្ញាតឲ្យលោក អេនឌ្រូ អ៊ីនូហ្ស៊ី ឡើងមានមតិចាប់អារម្មណ៍ដែលលោកបានធ្វើសំណើសុំកាលពីព្រឹកមិញ តើលោកមានបំណងនិយាយពីបញ្ហាអីដែរ? ហើយចំណាយពេលវេលាប៉ុន្មានដែរ?

**លោក អេនឌ្រូ អ៊ីនូហ្ស៊ី៖**

សូមអរគុណលោកប្រធាន! ប្រហែលជាអាចដប់នាទី ឬដប់នាទីលើសបន្តិចតែប៉ុណ្ណោះទេ។

សូមអរគុណ។ ចំណុចទីមួយ គឺពាក់ព័ន្ធទៅនឹងការអាននៃដីកាចោទប្រកាន់ នៅពេលនេះ គឺខ្ញុំលើក អំពីអនុស្សរណៈពីមន្ត្រីជាន់ខ្ពស់របស់អង្គជំនុំជម្រះ គឺ E141 ខែវិច្ឆិកា ឆ្នាំ២០១១ ដែលក្នុងនោះគឺឯកសារដែលមាននៅក្នុងលេខជើងទំព័រនៅក្នុងកថាខណ្ឌនីមួយៗ ត្រូវចាត់ទុកថា បានដាក់នៅចំពោះមុខអង្គជំនុំជម្រះ។ នៅក្នុងចំណុចនេះ គឺយើងសូមជំទាស់ទៅលើការលើកឡើងដូច្នោះ ដែលវាពាក់ព័ន្ធទៅនឹងលេខយោងជើងទំព័រទៅនឹងកថាខណ្ឌ ដែលបានអាននៅក្នុងដីកាចោទប្រកាន់ ជាពិសេស ចម្លើយរបស់សាក្សី ដែលមិនមកបង្ហាញខ្លួននៅចំពោះមុខអង្គជំនុំជម្រះនោះទេ។

[១០:២២:០៨]

ហើយចំពោះ យថាភាពនៃឯកសារទាំងអស់នោះ គឺយើងនៅតែរក្សាជំហរជំទាស់របស់យើង

ដដែល ហើយយើងយោងទៅលើការលើកឡើងរបស់សហព្រះរាជអាជ្ញា ដែលជាឯកសារ ខ្ញុំចែកជូនជាការសម្តែងនូវការគួរសមនៅក្នុងនោះ គឺវាពាក់ព័ន្ធទៅនឹងចម្លើយតបរួមរបស់សហព្រះរាជអាជ្ញា។

[១០:២២:៣០]

សហព្រះរាជអាជ្ញាបានលើកឡើងថា ខ្លួននឹងដាក់ជូននូវសារណាក្នុងពេលសមស្រប ដែលវាពាក់ព័ន្ធទៅនឹងការជឿជាក់ទៅលើឯកសារទាំងអស់ ដែលវាមាននៅក្នុងបញ្ជីរបស់សហព្រះរាជអាជ្ញា។ យើងឯកភាពទៅនឹងសំណើ និងការលើកឡើងរបស់សហព្រះរាជអាជ្ញានៅក្នុងចម្លើយតបរួមនោះ។ ដូច្នេះហើយខ្ញុំសូមអញ្ជើញឲ្យអង្គជំនុំជម្រះ ធ្វើការបង្ហាញនូវឯកសារទាំងឡាយដែលអង្គជំនុំជម្រះបានទទួលបាន ហើយដូចដែលអង្គជំនុំជម្រះបានបង្ហាញកាលពីព្រឹកមិញនេះដែរ។ នេះជាចំណុចដែលខ្ញុំសូមលើកឡើង។

[១០:២៣:១១]

ចំណុចទីពីរ ខ្ញុំដកស្រង់នៅពេលនេះ ចេញពីអនុស្សរណៈរបស់មន្ត្រីច្បាប់ជាន់ខ្ពស់ ដែលអនុស្សរណៈនោះលើកឡើងអំពីចម្លើយមុនៗរបស់សាក្សីដែលនឹងមកបង្ហាញខ្លួន។ សំណើនោះ គឺលើកឡើងដោយសហព្រះរាជអាជ្ញានៅក្នុងខែវិច្ឆិកា។ យើងខ្ញុំបានជំទាស់ចំនួនពីរដងរួចមកហើយ ចំពោះសំណើសុំរបស់សហព្រះរាជអាជ្ញានោះ។

មន្ត្រីច្បាប់ជាន់ខ្ពស់បានលើកឡើងនៅក្នុងអនុស្សរណៈថា អង្គជំនុំជម្រះឯកភាពអំពីប្រសិទ្ធភាពនៃកិច្ចនីតិវិធី ជាពិសេសនៅក្នុងពេលដែលសាក្សីដែលគាត់នឹងផ្តល់សក្ខីកម្ម ហើយយើងអាចពិនិត្យទៅលើចម្លើយទាំងអស់នោះបាន។ យើងបានទទួលនូវសេចក្តីសម្រេចសំអាងហេតុរបស់អង្គជំនុំជម្រះរួចមកហើយ ក៏ប៉ុន្តែយ៉ាងណាក៏ដោយយើងខ្ញុំនឹងផ្តល់ជាសារណាឆ្លើយតបវិញក្នុងពេលរយៈពេលខាងមុខនេះ ហើយយើងខ្ញុំស្នើសុំឲ្យអង្គជំនុំជម្រះធ្វើការផ្អាកនីតិវិធីដែលក្នុងការបង្ហាញសាក្សីដែលមានចម្លើយរបស់គាត់ផ្តល់ចម្លើយការពីមុនៗ។

[១០:២៤:៣៨]

ចំណុចមួយទៀត គឺជាចំណុចចុងក្រោយ ខ្ញុំសូមអរគុណលោក ជីវ សុងហាក់ ដែលជាប្រធានគណៈមេធាវីដែលគាត់គាំទ្រជាសាធារណៈដល់ការងាររបស់យើងខ្ញុំ ជាពិសេសឲ្យយើងខ្ញុំនេះអនុញ្ញាតៗឲ្យខ្ញុំនេះធ្វើការអនុវត្ត ឬក៏បំពេញការងារជាមេធាវីនៅក្នុងព្រះរាជាណាចក្រកម្ពុជា។

សូមអរគុណ។

**ប្រធានអង្គជំនុំ៖**

អរគុណលោកមេធាវី។ សូមអញ្ជើញ!

**លោក អាង ឧត្តម៖**

សូមក្រាបថ្វាយបង្គំព្រះតេជគុណព្រះសង្ឃគ្រប់ព្រះអង្គ សូមគោរពលោកចៅក្រមប្រធាន សូមគោរពលោក លោកស្រីចៅក្រម សមាជិក នៃក្រុមប្រឹក្សាអង្គជំនុំជម្រះសាលាដំបូង សូមគោរពអង្គសវនាការទាំងមូល។

ខ្ញុំនៅពេលនេះមានចំណាប់អារម្មណ៍មួយ ក៏ដូចជាសំណើមួយសូមការពិចារណា ទាក់ទងនឹងសក្ខីកម្មរបស់សាក្សី និងដើមបណ្តឹងរដ្ឋប្បវេណី។ តាមការអនុវត្តនៅតុលាការជាតិក្នុងករណីមានសាក្សីលើសពីម្នាក់ ឬដើមបណ្តឹងរដ្ឋប្បវេណីលើសពីម្នាក់ តុលាការមិនអនុញ្ញាតឲ្យសាក្សី ឬដើមបណ្តឹងរដ្ឋប្បវេណីផ្សេងបានឃើញ និងបានស្តាប់ឮការថ្លែង ការនិយាយ ឬសក្ខីកម្មរបស់សាក្សី ឬដើមបណ្តឹងរដ្ឋប្បវេណីផ្សេងទៀតនៅក្នុងសវនាការ។

[១០:២៦:៣១]

ខ្ញុំបាទមានចំណាប់អារម្មណ៍បែបនេះ ពីព្រោះថា នៅសវនាការនៅតុលាការយើងមានសាក្សី និងដើមបណ្តឹងរដ្ឋប្បវេណីច្រើន ថាតើតុលាការនឹងចាត់វិធានការបែបនេះ ដូចដែលតុលាការជាតិអនុវត្តដែរឬអត់? ធ្វើយ៉ាងនេះ ដើម្បីកុំឲ្យសាក្សី ឬដើមបណ្តឹងរដ្ឋប្បវេណីដែលមិនទាន់បានឡើងមកថ្លែងផ្តល់សក្ខីកម្មនៅចំពោះតុលាការ បានស្តាប់ឮនូវអ្វីដែលសាក្សី ឬដើមបណ្តឹងរដ្ឋប្បវេណីទៀត បាននិងកំពុងថ្លែងសក្ខីកម្ម។

ម្យ៉ាងទៀត សាក្សី ឬដើមបណ្តឹងរដ្ឋប្បវេណី ដែលបានថ្លែងសក្ខីកម្មរួច ក៏មិនត្រូវបានអនុញ្ញាតឲ្យជួបប្រាស្រ័យទាក់ទងនឹងសាក្សី ឬដើមបណ្តឹងរដ្ឋប្បវេណីផ្សេងទៀត ដែលមិនទាន់បានថ្លែងសក្ខីកម្មនោះទេ។ ថាតើបញ្ហានេះ យើងនឹងដោះស្រាយយ៉ាងម៉េច? សូមតុលាការមេត្តាពិចារណាផង។ សូមអរគុណ។

**ប្រធានអង្គជំនុំ៖**

អរគុណការកត់សម្គាល់ សំណើសុំរបស់មេធាវីការពារក្តីលោក អៀង សារី ហើយអង្គជំនុំជម្រះនឹងយកបញ្ហានេះទៅពិចារណាសម្រេច ហើយអង្គជំនុំជម្រះក៏សូមជម្រាបផងដែរ ដោយសាររឿងនេះវាស្រដៀងគ្នានឹងរឿង០០១ ដែលអង្គជំនុំជម្រះសាលាដំបូងបានមានបទពិសោធន៍នៅក្នុងការរៀបចំរួច

ហើយ ដែលមានសាក្សីច្រើន ហើយនិងដើមបណ្តឹងរដ្ឋប្បវេណីច្រើន ហើយយើងទំនងជាឲ្យដូចគ្នាទៅនឹងតុលាការជាតិ ប្រហែលជាមិនដូចទេ ពីព្រោះនៅនេះវាយើងប្រើពាក្យថា "អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា"ដែលតាមពាក្យពេចន៍ធម្មតាគឺមានន័យថា ខុសគ្នា លក្ខណៈពិសេសដោយឡែកសម្រាប់ដំណើរការនៅទីនេះហើយ។ ហើយនៅតុលាការជាតិ ក៏កម្រនឹងផ្សាយតាមព័ត៌មានសាធារណៈដូច្នេះណាស់។

[១០:២៩:១៦]

អ៊ីចឹងគឺការផ្សាយសាធារណៈដូច្នេះនៅទីនេះ ដែលមធ្យោបាយផ្តល់ព័ត៌មានសព្វថ្ងៃនេះមានការរីកចម្រើន ដូច្នេះតើការយើងលាក់ព័ត៌មាន ដែលធ្វើសវនាការជាសាធារណៈយ៉ាងដូចម្តេចនោះ អង្គជំនុំជម្រះនឹងជម្រាបជូនដល់ភាគី ហើយនិងម្ចាស់សំណើ និងសាធារណជនបានជ្រាប។

សូមអញ្ជើញលោកមេធាវីតំណាងដើមបណ្តឹងរដ្ឋប្បវេណី!

**លោកស្រី អេលីហ្សាបេត ស៊ីម៉ុនណូហ្វត៖**

សូមអរគុណលោកប្រធាន។ ខ្ញុំគ្រាន់តែចង់បញ្ជាក់ជូនថា ខ្ញុំគិតថានៅក្នុងច្បាប់កម្ពុជា ក៏ដូចជាច្បាប់រ៉ូម៉ង់អាល្លឺម៉ង់ដែរ គឺយើងមានការបែងចែកខុសគ្នា ដែលលោកប្រធានបានលើកអម្បាញ់មិញនេះរវាងដើមបណ្តឹងរដ្ឋប្បវេណី និងសាក្សី ហើយដើមបណ្តឹងរដ្ឋប្បវេណី គឺគាត់ចូលរួមនៅក្នុងការជជែកដេញដោលទាំងអស់ ទោះបីជាគាត់ត្រៀមខ្លួនក្នុងការធ្វើសក្ខីកម្មនៅក្នុងតុលាការនេះក៏ដោយ។ ដូច្នេះយើងត្រូវតែបែងចែកឲ្យគ្នាដាច់ឲ្យច្បាស់រវាងឋានៈជាដើមបណ្តឹងរដ្ឋប្បវេណី ហើយនិងសាក្សី។ ហើយវាអត់មានការលំបាកអីទេនៅក្នុងការបង្ហាញពីសាក្សី។ ខ្ញុំគ្រាន់តែចង់បញ្ជាក់ជូននូវការកត់សម្គាល់នេះមុននឹងលោកប្រធានធ្វើការសម្រេចទៅលើចំណុចនេះ។ សូមអរគុណ។

**ប្រធានអង្គជំនុំ៖**

បាទ, អរគុណ។ ហើយដោយសារពេលវេលាសមល្មមនឹងឈប់សម្រាកហើយ អង្គជំនុំជម្រះប្រកាសសម្រាកម្ភៃនាទី នាទី ចាប់ពីពេលនេះទៅ រហូតដល់ម៉ោងដប់មួយ ខ្វះដប់នាទីសូមអញ្ជើញចូលវិញ ដើម្បីបន្តកិច្ចដំណើរការសវនាការរបស់យើង។

សម្រាកចុះ!

**ក្រឡាបញ្ជី៖**

សូមអញ្ជើញក្រោកឈរ!

*(សវនាការសម្រាកពីម៉ោង ១០:៣០ នាទី ដល់ម៉ោង ១០:៥៩ នាទី)*

[១០:៥៨:៥៧]

**ប្រធានអង្គជំនុំ៖**

សូមអញ្ជើញអង្គុយចុះ!

អង្គជំនុំជម្រះប្រកាសបន្តកិច្ចដំណើរការនីតិវិធីសវនាការ។ អនុរក្សមន្ទីរឃុំឃាំងឲ្យនាំខ្លួនជនជាប់ចោទ នួន ជា មកកាន់ឈើរាងវង់ក្រចកសេះ នៅចំពោះមុខអង្គជំនុំជម្រះនេះ។

សូមអញ្ជើញមេធាវី!

**លោក សុន អរុណ៖**

សូមអរគុណលោកប្រធាន។ ខ្ញុំមានចម្ងល់ពីរបីនៅក្នុងពេលដែលក្រឡាបញ្ជីបានឡើងថ្លែងពីរឿង នួន ជា ចាប់ពីជំពូកមួយ ការកត់សម្គាល់ឃើញអំពីអង្គហេតុផ្នែកទីមួយ ប្រវត្តិកម្ពុជា-- ប្រវត្តិបក្សកុម្មុយនីស្តកម្ពុជា ដូចជាមានខ្វះចន្លោះនៃការអាន បើសិនជាខ្ញុំយល់ខុស អាហ្នឹងសូមមេត្តាជួយកែ។ ត្រង់កថាខណ្ឌ២៥ ត្រង់បន្ទាត់ទីបួន មានពាក្យខ្មែរថា "រណសិរ្សរួបរួមជាតិកម្ពុជា" ហើយមានសរសេរជាអក្សរបារាំងឡាតាំងដាក់ "ហ្វុង" ហើយមកដល់ក្រោម "ហ្គ្រុង" ទៀត ហេតុអីបានជាក្រឡាបញ្ជីមិនព្រម អាន? អាហ្នឹងមួយ។ រឿងទីពីរ នៅកថាខណ្ឌ២៥ ដដែល មកដល់រដ្ឋាភិបាលនេះ ត្រូវបានប្រកាសជាផ្លូវការនៅថ្ងៃទី៥ ខែឧសភា ឆ្នាំ១៩៧០ សម្តេចនរោត្តម សីហនុ ជាអតីតប្រធានរណសិរ្សរួបរួមជាតិកម្ពុជា ត្រង់នេះ ក៏មិនបានអានដែរ។

[១១:០២:៥៩]

មួយទៀត នៅកថាខណ្ឌទី២៧ ត្រង់បន្ទាត់ទីបី បន្ទាប់មកនៅក្នុងខែមេសា ឆ្នាំ១៩៧១ គាត់បានធ្វើដំណើរទៅកាន់ទីក្រុងប៉េកាំង ដើម្បីស្នាក់នៅជាមួយសម្តេច សីហនុ និងធ្វើជាបេសកជនពិសេសនៃចលនាតស៊ូ មិនបានអានឈ្មោះសីហនុ-- សម្តេចសីហនុ។ ទាំងបីសំណួររបស់ខ្ញុំនេះ សូមឲ្យក្រឡាបញ្ជីមេត្តាពន្យល់ ហេតុអីបានជាមិនអាន?

[១១:០៣:៣៨]

**ប្រធានអង្គជំនុំ៖**

មិនបាច់ក្រឡាបញ្ជីទេ យើងអ្នកជម្រាបជូនលោកតែម្តង។ ទីមួយ គ្រុន ឬក៏ក្រាន់នេះ វាជាភាសាបរទេសដែលអ្នកដាក់នៅក្នុងវង់ក្រចកដែលមិនមានន័យថាអ្វីទេ ចំពោះជនជាតិខ្មែរ មិនយល់ថាពាក្យ

“គ្រុន” ឬក៏អានថា “ក្រាន់”ហ្នឹង មិនដឹងមានខ្លឹមសារថាម៉េចទេ គេដាក់ក្នុងវង់ក្រចកហ្នឹង គឺមិនមែនជាន័យសម្រាប់ហៅ “គ្រុន ឬក៏ក្រាន់” នោះទេ។ គ្រាន់តែពាក្យហ្នឹង បានបញ្ជាក់ជាភាសាខ្មែររួចច្បាស់លាស់រួចទៅហើយ។ អ៊ីចឹង យើងនៅក្នុងនេះ គឺយើងបានសម្រេចថាមិនបាច់អានទេ កុំឱ្យប្រជាពលរដ្ឋសាធារណជន យល់ច្រឡំនូវពាក្យទាំងអស់ហ្នឹង គ្រាន់តែស្ដាប់ពាក្យខ្មែរដែលពាក្យពេញលេញ និងវណសិរ្សបរួមជាតិអីហ្នឹង គឺច្បាស់លាស់រួចអស់ទៅហើយ។

[១១:០៤:៣៣]

ចំណែកឯបញ្ហាទីពីរ គឺអង្គជំនុំជម្រះបានបង្គាប់ឱ្យក្រឡាបញ្ជីអាននូវឯកសារដីកាដំណោះស្រាយសាធារណៈ។ ឯកសារដំណោះស្រាយសាធារណៈដែលអាននេះ គឺមានការកោសលុបដោយសហចៅក្រមស៊ើបអង្កេត។ អ៊ីចឹងហើយ គឺកន្លែងណាសហចៅក្រមស៊ើបអង្កេតលុប គឺមិនអាចអានបានទេ ដោយធានានៅក្នុងកិច្ចដំណើរការនីតិវិធី យើងបានប្រាប់រួចហើយអំពីមុននឹងឱ្យក្រឡាបញ្ជីអាន ថាឈ្មោះដែលលុបហ្នឹងគឺអាចជាសាក្សី ជាដើមបណ្ដឹងរដ្ឋប្បវេណី ឬជាបុគ្គលដែលប្រមើលមើល ថាថ្ងៃក្រោយអាចនឹងអញ្ជើញគាត់ឱ្យមកផ្ដល់សក្ខីកម្មនៅចំពោះមុខអង្គជំនុំជម្រះ ដោយយើងអនុវត្តនៅតុលាការនេះ គឺអនុវត្តតាមគោលការណ៍នៃការរក្សាការពារដល់សុវត្ថិភាពដល់សាក្សី ដល់ដើមបណ្ដឹងរដ្ឋប្បវេណី ឬអ្នកជំនាញដែលនឹងមកធ្វើសក្ខីកម្ម។ ដរាបណាតុលាការមិនទាន់ដល់ពេលសួរមុខគោលដៅទាំងអស់នោះទេ អង្គជំនុំជម្រះនៅតែរក្សាស្ថានភាពនៃការលាក់អត្តសញ្ញាណបុគ្គលនោះ ដោយអង្គជំនុំជម្រះបានបញ្ជាក់រួចហើយថា ប្រសិនបើជួបនឹងបញ្ហាដូចនេះត្រូវប្រើរហស្សនាម។

ព្រឹកមិញគឺ យើងបានអានច្បាស់លាស់ណាស់ ឱ្យអានលើកឡើងតែអំពីរហស្សនាមតែប៉ុណ្ណោះនូវបណ្ដាឈ្មោះអ្នកទាំងអស់នេះ។ ប្រហែលជាមេធាវីយល់ច្បាស់ណាស់ បញ្ហានេះ ពីព្រោះអាចមានការភ័ន្តច្រឡំយកឯកសារសម្ងាត់យកមកប្រើ។ ចំណែកឯ អង្គជំនុំជម្រះបង្គាប់ឱ្យអានជាឯកសារសាធារណៈ ដែលមូលហេតុគោរពនូវវិធានការការពារដែលអនុវត្តនៅទីនេះជាទូទៅ។ ជាពិសេសគឺកម្ពុជាក៏ជាភាគីហត្ថលេខីនៃអនុសញ្ញាអន្តរជាតិស្ដីពីវិធានការការពារសាក្សី ដើមបណ្ដឹងរដ្ឋប្បវេណី និងអ្នកជំនាញនៅក្នុងរឿងក្ដីដែរ។

[១១:០៦:៤៥]

**លោក សុន អរុណ៖**

ដោយខ្ញុំស្ដាប់នៅក្នុងការអានរបស់ក្រឡាបញ្ជីទាំងពីរនាក់ហ្នឹងទៅ ដល់អានមកក្រោយៗទៀត

មានចំណោះដែលជនត្រូវជាប់ជាសាក្សីហ្នឹង មានអានឈ្មោះហ្នឹងដដែល។

**ប្រធានអង្គជំនុំ៖**

ខ្ញុំសូមជម្រាបថា ដោយសារនៅក្នុងដីកាដំណោះស្រាយកន្លែងខ្លះគេលុប កន្លែងខ្លះគេមិនលុប យើងអានទៅតាមឯកសារដើមរបស់គេ។ គេលុបយើងអានលុប បើគេមិនលុប យើងអានតាមធម្មតា។ នេះឯកសារ សូមលោកអាចទៅស្រាវជ្រាវមើលឯកសារ សាធារណៈនៅអ៊ីនធឺណេត មានហើយ។

**លោក សុន អរុណ៖**

សូមអរគុណលោកប្រធាន។

[១១:០៧:៤៤]

**ការតាំងសំណួរដោយចៅក្រម**

**សួរដោយប្រធានអង្គជំនុំ៖**

**ស៖** សួស្តីលោក នួន ជា តើលោកឈ្មោះត្រឹមត្រូវ នួន ជា ពិតមែនដែរឬទេ?

**លោក នួន ជា៖**

**ឆ៖** សូមគោរពលោកប្រធាន ឈ្មោះកំណើត ហើយនិងឈ្មោះ បដិវត្តន៍។ ឈ្មោះកំណើតខ្ញុំ ឈ្មោះ ឡៅ គឹមរន ហើយឈ្មោះ បដិវត្តន៍ឈ្មោះ នួន ជា។ សូមជម្រាបលោកប្រធាន។

**ស៖** បាទ, អរគុណ ហើយសូមបញ្ជាក់ម្តងទៀត ឈ្មោះកំណើត ឡៅ គឹមរន អ៊ីចឹង?

**ឆ៖** ឡៅ គឹមរន។

**ស៖** អរគុណ។ លោក នួន ជា តើលោកកើតនៅថ្ងៃខែឆ្នាំណា?

**ឆ៖** កើតនៅថ្ងៃទី៧ ខែកក្កដា ឆ្នាំ១៩២៦។ ម្តាយខ្ញុំមិនមែនចិនទេ ខ្មែរ តែឪពុកខ្ញុំកូនចៅចិន។ ម្តាយខ្ញុំខ្មែរសុទ្ធ។

**ស៖** អរគុណបាទ។ ទីកន្លែងកំណើតរបស់លោកនៅកន្លែងណាដែរ?

**ឆ៖** របស់ខ្ញុំ សូមគោរពលោកប្រធាន នៅភូមិវត្តគរ ឃុំវត្តគរ មិនមែនវត្តកទេណ៎ា វត្តគរ ឃុំវត្តគរ ស្រុកសង្កែ ខេត្តបាត់ដំបង។

[១១:០៩:១៦]

**ស៖** អរគុណ។ ទីលំនៅមុនពេលចាប់ឃុំខ្លួនលោក តើលោករស់នៅទីកន្លែងណា?

**ឆ៖** លោកប្រធាន ពេលនោះ ខ្ញុំនៅផ្សារព្រហ្ម នែ៎ ឥឡូវគេប្រែពីខេត្តប៉ៃលិនហើយ ពីដើមនៅ

ស្រុកប៉ៃលិននៅឡើយទេ។

**ស៖** បាទ, អរគុណ។ ហើយម្ដាយបង្កើតរបស់លោកឈ្មោះអី?

**ឆ៖** ឈ្មោះ ដែង ពាញ។

**ស៖** ដែង ពាញ មិនមែន ដុស ពាញទេ?

**ឆ៖** ដុស ជួនណាប្រើឈ្មោះ ដែង ពីព្រោះជីតាឈ្មោះ ដែង ឪពុកជីតាខ្ញុំឈ្មោះ ដុស។ វាមិនទៀង ពីព្រោះខ្ញុំនៅក្មេង ខ្ញុំមិនចាំដែរ។

**ស៖** អរគុណ។ ហើយឪពុករបស់លោកឈ្មោះអី?

**ឆ៖** ឈ្មោះ ឡៅ លីវ។

**ស៖** ចុះប្រពន្ធរបស់លោកវិញឈ្មោះអីដែរ?

**ឆ៖** ប្រពន្ធរបស់ខ្ញុំបាទឈ្មោះ លី គឹមសេង។

**ស៖** លោកមានបងប្អូនប៉ុន្មាននាក់? ប្រុសប៉ុន្មាន ស្រីប៉ុន្មាន?

**ឆ៖** ខ្ញុំមានបងប្អូន និយាយរួមប្រាំបួននាក់ ប៉ុន្តែងាប់អស់ទៅ វានៅសល់ ឥឡូវវានៅសល់តែបីនាក់ទេ។ ប្រុសពីរ ស្រី១-- ប្រុសមួយ ស្រីពីរ។

[១១:១០:៥៩]

**ស៖** បាទ អរគុណ។ ហើយតើលោកជាកូនទីប៉ុន្មាននៃក្នុងចំណោមបងប្អូនបង្កើតរបស់លោក?

**ឆ៖** លោកប្រធាន ខ្ញុំបាទជាកូនទីបី។

**ស៖** លោក នួន ជា តើលោកអាចរៀបរាប់ដោយត្រួសៗអំពីប្រវត្តិនៃការសិក្សារៀនសូត្ររបស់លោកជូនដល់អង្គសវនាការបានស្ដាប់បានដែរឬទេ? សូមអញ្ជើញ!

**ឆ៖** សូមអនុញ្ញាតជម្រាបលោកប្រធាន! អាយុ១៣ឆ្នាំ-- អាយុ៧ឆ្នាំ កាលសម័យអាណានិគមនិយមបារាំង ខ្ញុំរៀននៅ *គួកអង់ហ្វង់តាំង* គេហៅ *គួកអង់ហ្វង់តាំង* ប្រែជាខ្មែរហៅថាបន្ទប់លេខប្រាំ។ ហើយបានមកដល់ក្រោយទៀតបាន *គួកប៉ារ៉េប្រាហ្វា* បន្ទប់លេខបួន ហើយបាន *គួកអេលេម៉ង់ទែរ* បន្ទប់លេខបី ហើយបានបន្ទប់លេខពីរជាន់ទាប *គួកមីយៀងអង* បន្ទប់លេខពីរជាន់ខ្ពស់ *គួកមីយៀងឌឺ* ហើយបន្ទប់លេខមួយ *គួកស្យេយ័រ* រួចទៅប្រលង *សឺទីវីកា អេទីត ព្រីមែរ កុំផ្លេម៉ង់ទែរ អាំងដូស៊ីន្រ័រ* នៅភ្នំពេញ។ ខ្ញុំរៀននៅ លីសេ បាត់ដំបង *ប្រឹមីញ៉េអាន់ណេ* ។ រួចទៅឆ្នាំ១៩៤១ហ្នឹង ន៎ែ! បារាំងប្រគល់បាត់ដំបងឲ្យៗថៃ។ ខ្ញុំទៅរៀនតនៅស្រុកថៃ។

[១១:១២:៤៨]

**ស៖** លោករៀននៅស្រុកថៃហ្នឹង រៀននូវមុខវិជ្ជាអ្វីដែរ? ហើយរយៈពេលប៉ុន្មាននៅវិទ្យាល័យ ឬមហាវិទ្យាល័យណា?

**ឆ៖** ខ្ញុំរៀន ដំបូងឡើយរៀននៅមធ្យមសិក្សាថ្នាក់ទីប្រាំ ទីប្រាំមួយ។ ចប់ថ្នាក់ទីប្រាំមួយ រៀនត្រៀមនៅមហាវិទ្យាល័យធម្មសាធ ហៅថាបើភាសាអង់គ្លេសកាលណោះគេហៅថា *យូនីវឺស៊ីធី អហ្វ ម៉ូរ៉ាល អេន ប៉ូលីទីខលសាយអេន* រៀនត្រៀមពីរឆ្នាំ។ ចប់ពីរឆ្នាំហើយ ខ្ញុំចូលជាអ្នកសិក្សាពេញសិទ្ធិមួយឆ្នាំទៀត។ រួចទៅ ក្នុងពេលរៀនហ្នឹង ខ្ញុំក៏ធ្វើការផង ធ្វើការរាជការថៃ។ មុនដំបូងធ្វើនៅក្រសួងឃ្លាំង ក្រសួងហិរញ្ញវត្ថុ តមកទៀតធ្វើការនៅក្រសួងការបរទេស បានប្រហែលមួយខែ ហើយខ្ញុំឃើញសេចក្តីរាយការណ៍ផ្សេងៗពីទូតថៃនៅភ្នំពេញអំពីបារាំងបាញ់ប្រជាជនខ្មែរ ខ្ញុំក៏កើតសេចក្តីឈឺចាប់សុំឈប់ធ្វើការ ចេញមកធ្វើការតស៊ូរំដោះជាតិ រំដោះប្រជាជន ឆ្នាំ១៩៥០-៥១ តែប៉ុណ្ណឹង។

[១១:១៤:៤០]

**ប្រធានអង្គជំនុំ៖**

បាទ, អរគុណ។ ហើយជាកិច្ចបន្តនេះ លោក នួន ជា ក្នុងនាមលោកជាជនជាប់ចោទនៅចំពោះមុខអង្គជំនុំជម្រះសាលាដំបូងនេះ ចាប់ពីពេលនេះតទៅ និងនៅក្នុងសវនាការជាបន្តបន្ទាប់រហូតដល់ចប់កិច្ចដំណើរការពិភាក្សាដេញដោលនៅក្នុងសំណុំរឿង០០២ លោកមានសិទ្ធិដូចខាងក្រោម៖

សិទ្ធិមានមេធាវីការពារក្តីតាមការជ្រើសរើសរបស់លោក ឬតាមការចាត់តាំងនៅក្នុងគ្រប់ដំណាក់កាលនៃកិច្ចដំណើរការនៅនីតិវិធីរបស់តុលាការ។ អំពីសិទ្ធិនេះ អង្គជំនុំជម្រះកត់សម្គាល់ឃើញថា៖ ចាប់តាំងពីដំណាក់កាលស៊ើបអង្កេត រហូតមកដល់ពេលនេះ លោកមានមេធាវីការពារក្តីចំនួនបួនរូប មានមេធាវីការពារក្តីជាតិចំនួនមួយរូប និងមេធាវីការពារក្តីអន្តរជាតិចំនួនបីរូប។

នៅក្នុងគ្រប់ដំណាក់កាលនៃកិច្ចដំណើរការនីតិវិធីពិភាក្សាដេញដោលរបស់តុលាការ លោកមានសិទ្ធិនៅស្ងៀមមិនឆ្លើយតប មានសិទ្ធិមិនធ្វើសក្ខីកម្មប្រឆាំងនឹងខ្លួនឯង មានសិទ្ធិទទួលដំណឹងពីបទល្មើសដែលចោទប្រកាន់ចំពោះលោក។

[១១:១៥:៥៥]

តើលោក នួន ជា លោកបានទទួលដំណឹងអំពីបទចោទប្រកាន់ចំពោះលោក រួបលោកហើយឬនៅ?

**លោក នួន ជា៖**

ខ្ញុំសូមជម្រាបលោកប្រធាន ខ្ញុំបានអានឯកសារខ្លះ។

**ប្រធានអង្គជំនុំ៖**

អ៊ីចឹង លោកដឹងទេ ដឹងជាក់លាក់ទេថា លោកជាប់ចោទពីបទអ្វីទេ? ហើយដោយសារនីតិវិធីនេះឆ្លងកាត់ច្រើនដំណាក់កាលហើយ?

**លោក នួន ជា៖**

សូមជម្រាបលោកប្រធាន រឿងឧក្រិដ្ឋកម្មសង្គ្រាម សង្គ្រាមប្រល័យពូជសាសន៍ សង្គ្រាមអីមួយប៉ុន្មានទៀតទេ ខ្ញុំមិនចាំទេ។ សូមជម្រាបឧក្រិដ្ឋកម្មសង្គ្រាម សង្គ្រាមប្រល័យពូជសាសន៍ សង្គ្រាមប្រល័យ សង្គ្រាមមនុស្សជាតិយ៉ាងម៉េចទេ។

**ប្រធានអង្គជំនុំ៖**

ឥឡូវនេះ យើងប្រាប់បញ្ជាក់អំពីបញ្ហាបទចោទប្រកាន់ចំពោះលោកសាជាថ្មី។ ផ្អែកតាមដីកាដំណោះស្រាយចុះថ្ងៃទី១៥ ខែកញ្ញា ឆ្នាំ២០១០ របស់សហចៅក្រមស៊ើបអង្កេត ឯកសារ D427 ចោទប្រកាន់នៅរូបលោកពីបទឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិ នៅក្នុងបទឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិហ្នឹងមានបទល្មើសតូចៗជាច្រើន ក្នុងនោះមាន៖

[១១:១៧:២៨]

ក) ការមនុស្សឃាត

ខ) ការសម្លាប់រង្គាល

គ) ការធ្វើឲ្យទៅជាទាសករ

ឃ) ការនិរទេស

ង) ការដាក់ក្នុងមន្ទីរឃុំឃាំង

ច) ការធ្វើទារុណកម្ម

ឆ) ការរំលោភលើផ្លូវភេទ

ជ) ការធ្វើទុក្ខបុកម្នេញដោយមូលហេតុនយោបាយ ពូជសាសន៍ ឬសាសនា

ឈ) អំពើអមនុស្សធម៌ផ្សេងៗទៀត។

បទល្មើសទីពីរ គឺបទល្មើសឧក្រិដ្ឋកម្មប្រល័យពូជសាសន៍ តាមរយៈការសម្លាប់សមាជិកក្រុមចាម និងវៀតណាម៖

៣) អំពើបំពារបំពានយ៉ាងធ្ងន់ធ្ងរលើអនុសញ្ញាទីក្រុងហ្សឺណែវចុះថ្ងៃទី១២ ខែសីហា ឆ្នាំ១៩៤៩។ បទល្មើសនេះក៏មានបទល្មើសតូចៗជាច្រើនដូចខាងក្រោម៖

ក) ការធ្វើមនុស្សឃាតដោយចេតនា

ខ)ការធ្វើទារុណកម្ម ឬការធ្វើបាបដោយអមនុស្សធម៌

គ) ការបង្កដោយចេតនាឲ្យមានរបួសធ្ងន់ធ្ងរ ឬឲ្យមានការឈឺចាប់ដល់រាងកាយ ឬសុខភាព

ឃ) ការដកហូតដោយចេតនាពីឈ្លើយសឹក ឬជនស៊ីវិលនូវសិទ្ធិទទួលបានការកាត់ទោសដោយយុត្តិធម៌

ង) ការនិរទេស និងការឃុំខ្លួនជនស៊ីវិលដោយខុសច្បាប់។

[១១:១៨:៥៣]

ហើយតាមរយៈអំពើសកម្ម ឬអកម្មបានប្រព្រឹត្តដោយ បានចូលរួមក្នុងសហឧក្រិដ្ឋកម្មរួមរៀបចំក្នុងផែនការ ញុះញង់ឲ្យប្រព្រឹត្ត បញ្ជាឲ្យមាននូវការប្រព្រឹត្ត បានជួយនិងជំរុញដល់ចារី ឬទទួលខុសត្រូវក្នុងនាមជាថ្នាក់លើប្រព្រឹត្តនៅទីក្រុងភ្នំពេញ នៅលើដីនៃប្រទេសកម្ពុជា នៅលើទឹកដីនៃប្រទេសកម្ពុជា និងនៅក្នុងអំឡុងពេលនៃការចូលលុកលុយទឹកដីវៀតណាម ក្នុងចន្លោះថ្ងៃទី១៧ ខែមេសា ឆ្នាំ១៩៧៥ ដល់ថ្ងៃទី៦ ខែមករា ឆ្នាំ១៩៧៩។

[១១:១៩:៣២]

បទល្មើសមានចែងនិងផ្តន្ទាទោសមាត្រា៥ មាត្រា៦ មាត្រា៤ មាត្រា២៩(ថ្មី) មាត្រា៣៩(ថ្មី) នៃច្បាប់ស្តីពីការបង្កើតឲ្យមានអង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា។ ហើយក្រៅពីនេះក៏ផ្អែកទៅលើតាមសាលដីកាដែលបានចេញដោយអង្គបុរេកាលពីថ្ងៃទី១៣ ខែមករា ឆ្នាំ២០១១ លើបញ្ហាបណ្តឹងឧទ្ធរណ៍ប្រឆាំងនឹងដីកាដំណោះស្រាយរបស់លោក មានឯកសារជាច្រើន ដែលពាក់ព័ន្ធនឹងបញ្ហានេះ។ ប៉ុន្តែទោះបីយ៉ាងណាក៏ដោយ នៅក្នុងឯកសារនៃសាលដីការបស់អង្គបុរេហ្នឹង មានការកែសម្រួលបន្តិចបន្តួចចំពោះបទល្មើសតូចៗមួយចំនួនតិចប៉ុណ្ណោះ ដោយផ្លាស់ប្តូរ ដូចជា បទល្មើសប្រឆាំងមនុស្សជាតិហ្នឹង គឺត្រង់ចំណុចរំលោភលើផ្លូវភេទហ្នឹង គឺមានការប្តូរថាមិនមានអាហ្នឹងទេ គឺចាត់ទុកថាជាអំពើនិង

អមនុស្សធម៌ផ្សេងៗ។ ហើយនេះជាបទចោទប្រកាន់ ហើយចំពោះរូបលោកនៅចំពោះមុខអង្គជំនុំជម្រះនេះ។ ក្រៅពីនេះអង្គជំនុំជម្រះក៏សូមជម្រាបដែរថាបញ្ហានេះគឺ លោកបានដឹងដំណឹងអំពីបញ្ហានេះជាច្រើន តាមរយៈនៃការផ្ដល់ជូនដំណឹង អំពីដីកាចោទប្រកាន់ ដោយសហចៅក្រមស៊ើបអង្កេតតាំងពីក្រោយពេលចេញដីកាដំណោះស្រាយ របស់សហចៅក្រមស៊ើបអង្កេត។

[១១:២១:០៧]

អ៊ីចឹងហើយបានជាលោកមានឱកាសនៅក្នុងការប្ដឹងឧទ្ធរណ៍ ប្រឆាំងនឹងដីកាដំណោះស្រាយរបស់សហចៅក្រមស៊ើបអង្កេត ដែលអង្គបុរេបានវិនិច្ឆ័យ និងចេញសាលដីកាលើបញ្ហាទាំងអស់នេះកាលពីថ្ងៃ១៣ ខែមករា ឆ្នាំ២០១១។ ហើយបន្ថែមពីទៅលើនោះទៀត គឺលោកមានប្ដឹងអំពីបញ្ហាអញ្ញត្រកម្មដែលនៅចំពោះមុខអង្គជំនុំជម្រះកន្លងមក។ នេះគឺបញ្ជាក់ថា តាមរយៈមេធាវីការពារក្ដីរបស់លោក ៗបានដឹងអំពីបទល្មើស ដែលបានចោទប្រកាន់ចំពោះរូបលោកយ៉ាងជាក់ច្បាស់។

ហើយនិងកត់សម្គាល់មួយទៀត គឺកាលពីថ្ងៃទី២១ ខែវិច្ឆិកា ឆ្នាំ២០១១ ក្រឡាបញ្ជីសវនាការក៏បានអាននូវបទចោទប្រកាន់ប្រឆាំងនឹងរូបលោក និងជនជាប់ចោទពីររូបផ្សេងទៀតដែរ។

[១១:២១:៥៨]

នេះគឺជាការសង្ខេបនៃការដែលបានដឹងចាត់ទុកថាបានដឹងអំពីបទចោទប្រកាន់ប្រឆាំងនឹងលោក។

ជាកិច្ចបន្តអង្គជំនុំជម្រះសូមប្រគល់ភារៈក្នុងការតាំងសំណួរនានា ចំពោះជនជាប់ចោទ នួន ជា ជូនទៅលោកចៅក្រម ស៊ីលវៀ ខាតវ៉ាយថ៍។

សូមអញ្ជើញលោកស្រីចៅក្រម!

**លោក នួន ជា៖**

អំពីប្រវត្តិនៃការតស៊ូរបស់ខ្ញុំ តើវាចូលក្នុងបទដែលចោទទាំងប៉ុន្មានដែរនោះទេឬទេ? ដើម្បីអង្គប្រជុំបានជ្រាប។ ខ្ញុំសូម-- ពីព្រោះខ្ញុំចាត់ទុកថា តុលាការជាស្ថាប័ន ដែលមានកិត្តិយសខ្ពស់បំផុតភ្នាក់ងារ ឬក៏ប្រធាន ព្រះរាជអាជ្ញាជាបូជនីយបុគ្គល ដែលរក្សាទុកនូវសេចក្ដីយុត្តិធម៌ ត្រឹមត្រូវ មានប្រយោជន៍។

[១១:២៣:៣២]

ដូច្នោះបើលោកប្រធានមិនយល់ទាស់ទេ ខ្ញុំសូមអនុញ្ញាតរៀបរាប់អំពីប្រវត្តិនៃការតស៊ូរបស់ខ្ញុំមុនដំបូងជាមុនដំបូងសិន ហើយចាំឲ្យសួរចុះ។

**ប្រធានអង្គជំនុំ៖**

បាទ, សូមអញ្ជើញ! អង្គជំនុំជម្រះអនុញ្ញាត។

សូមអញ្ជើញ! លោក បាទ។

**លោក នួន ជា៖**

សូមអរគុណលោកប្រធាន។

[១១:២៤:០៧]

ប្រវត្តិសង្ខេបនៃការតស៊ូរបស់ខ្ញុំមានដូចតទៅនេះ៖

មុនដំបូងអ្វីធ្វើឲ្យខ្ញុំមានគំនិតតស៊ូ គឺកាលពីខ្ញុំនៅក្មេង ខ្ញុំរស់នៅក្នុងរបបអាណានិគមនិយមបារាំង។ ខ្ញុំឃើញច្បាស់នឹងភ្នែកនូវបារាំងធ្វើបាបប្រជាជនខ្មែរ វាយដំច្រំធាក់ ដាក់គុក ដាក់ច្រវាក់ ហើយឃើញអ្នកមានធ្វើបាបអ្នកទាសករ ដែលនៅជាមួយវាយដំ ច្រំធាក់។ ទាំងអស់នេះធ្វើឲ្យខ្ញុំកាលនោះមិនទាន់មានគំនិតជាស្នេហាជាតិអីប៉ុន្មានទេ ប៉ុន្តែគ្រាន់តែគិតមានសេចក្តីអាណិតអាសូរ កើតសេចក្តីស្រឡាញ់នូវយុត្តិធម៌ដុះក្នុងខ្លួនខ្ញុំ។ ដូច្នោះហើយបានជាខ្ញុំស្អប់ខ្ពើមនូវការជិះជាន់សង្កត់សង្កិនរបស់អាណានិគមនិយមបារាំង និងរបស់ពួកម្ចាស់ដី អ្នកមានអំណាចជាខ្មែរដូចគ្នា។ ដល់ខ្ញុំកាន់តែធំឡើងបានរៀនសូត្រចេះដឹងម្តងបន្តិចៗ។ រៀនជាប់នៅលីសេបាត់ដំបងហើយ ឆ្នាំ១៩៤១ បារាំងប្រគល់ខេត្តបាត់ដំបង សៀមរាបមួយចំនួន ស៊ីសុផុន ទៅឲ្យថៃ។ ខ្ញុំចង់ដឹង ថាតើប្រទេសដែលថាឯករាជ្យនោះវាយ៉ាងម៉េច? ដូច្នោះ បានជាខ្ញុំ ទៅរៀននៅស្រុកថៃដោយនៅវត្ត អាស្រ័យនៅវត្ត ពីព្រោះឪពុកម្តាយខ្ញុំក៏ក្រលំបាកដែរ គាត់ធ្វើស្រែធ្វើចម្ការ ឪពុកខ្ញុំក៏គាត់រកស៊ីខាត ម្តាយខ្ញុំរកទទួលទានកាន់ដេរខោអាវ ហើយធ្វើនំលក់ ហើយខ្ញុំពេលថ្ងៃព្រហស្បតិ៍ ថ្ងៃអាទិត្យអីក៏លក់នំលក់អីអ៊ីចឹងដែរ។

[១១:២៧:៤០]

ដល់គិតថា ខ្ញុំស្មានថាថៃឯករាជ្យ ដល់ទៅខ្ញុំឃើញថា អ្ហែថៃមិនមែនឯករាជ្យទើយ ពីព្រោះអ្នកកាន់អំណាចមួយចំនួនសុទ្ធតែជិះជាន់សង្កត់សង្កិន ហើយភាគច្រើនថៃចិន សុទ្ធតែចិននៅថៃ ឯពួកថៃលំបាកវេទនាដូចខ្មែរដែរ។ ដល់អ៊ីចឹង ខ្ញុំកើតគំនិតថានៅឯណាក៏វាអយុត្តិធម៌ៗ។ ពេលនោះខ្ញុំចាប់ផ្តើមអានកាសែតថៃដែលគេហៅថា “កាសែតចម្រើន” មានកាសែតគេហៅថា “មហាជន” ជារបស់បក្សកុម្មុយនីស្តថៃ។ ដល់អានកាសែតនេះទៅខ្ញុំឃើញថាលិទ្ធិកុម្មុយនីស្ត ឬក៏របបកុម្មុយនីស្តជួយដោះស្រាយជួយប្រទេសអាណានិគមនិយម ដែលត្រូវគេជិះជាន់សង្កត់សង្កិនឲ្យបានឯករាជ្យ។ ខ្ញុំក៏ចាប់អារម្មណ៍

លើបញ្ហានេះ។ ប៉ុន្តែខ្ញុំមិនទាន់យល់ថា កុម្មុយនីស្តហ្នឹងយ៉ាងម៉េចទេ? អត់យល់ទេ។ ក៏ប៉ុន្តែមានមិត្តភក្តិមួយចំនួន ដែលជាថៃដែររៀន កាលហ្នឹងចូលរៀនមហាវិទ្យាល័យធម្មសាធហើយ។ មហាវិទ្យាល័យធម្មសាធភាគច្រើនសាស្ត្រាចារ្យ គេចាត់ទុកថាជាអ្នកចម្រើន ពីព្រោះសុទ្ធតែចាងហ្វាង សុទ្ធតែអីៗអស់នេះមកធ្វើសាស្ត្រាចារ្យ មកបង្ហាញគេហៅថា *"ឡិចឆើ"* ឲ្យពួកអ្នកសិក្សាស្តាប់។

[១១:២៩:៥៦]

ខ្ញុំក៏កាន់តែយល់ម្តងបន្តិចៗ ដល់អ៊ីចឹងអ្ហេ៎! នៅថៃ មានអង្គការមួយ គេហៅថាអង្គការយុវជនប្រជាធិបតេយ្យថៃ។ ខ្ញុំសូមចូលក្នុងអង្គការនេះ ដើម្បីធ្វើសកម្មភាព មានការប្រជុំ ការអីៗ ហើយគេដឹងថាខ្ញុំខ្មែរ ឲ្យខ្ញុំនិយាយអំពីការជិះជាន់របស់អាណានិគមនិយមបារាំងនៅស្រុកខ្មែរយ៉ាងម៉េចៗ។ ខ្ញុំនិយាយឲ្យស្តាប់។ ខ្ញុំធ្វើសកម្មភាពប្រឆាំងនឹងអ្នកកាន់អំណាចថៃ ដែលជិះជាន់ប្រជាជន រួមជាមួយពួកអ្នកចម្រើនមួយចំនួន។ ដល់ក្រោយមក គេឃើញខ្ញុំសកម្ម ឆ្នាំ១៩៥០ ខ្ញុំចូលបក្សកុម្មុយនីស្តថៃ។ ចូលបក្សកុម្មុយនីស្តថៃ ដល់ថ្ងៃទី៧ ខែកក្កដា ខ្ញុំសូមអនុញ្ញាតបក្សកុម្មុយនីស្តថៃ មកធ្វើការតស៊ូនៅកម្ពុជា។ ដោយខ្ញុំឃើញបារាំង ជិះជាន់សង្កត់សង្កិនប្រជាជនខ្ញុំ។

ដូច្នេះ បក្សកុម្មុយនីស្តថៃ បានអនុញ្ញាតទាក់ទាញ-- គេអនុញ្ញាតនឹងសាខាបក្សវៀតណាម បក្សកុម្មុយនីស្តឥណ្ឌូចិន ប៉ុន្តែគេមានសាខាបក្សគេនៅស្រុកថៃ ឧទ្ទេសនាមឲ្យខ្ញុំមកធ្វើសកម្មភាពនៅកម្ពុជា។ ខ្ញុំមកធ្វើសកម្មភាពនៅកម្ពុជា ធ្វើខាងអី? ខ្ញុំធ្វើខាងការឃោសនាអប់រំ សរសេរកាសែត ផ្សាយកាសែត ហើយដើរអប់រំប្រជាជនឲ្យភ្ញាក់រឭកពីរឿងប្រទេសជាតិ ឲ្យមានស្មារតីស្នេហាជាតិ ប្រឆាំងអាណានិគមនិយមបារាំង។ កាលនោះ មានចលនាឥស្សរៈហើយ តាំងពីឆ្នាំ១៩៤៦ ដូចជាខ្ញុំអាចនិយាយឲ្យល្អិតបន្តិចមានឥស្សរៈ ដាប ឈួន ពួកនេះសុទ្ធឥស្សរៈក្លែងក្លាយ។ ប៉ុន្តែក៏មានឥស្សរៈ គេស្នេហាជាតិដែរ ដូចជាឥស្សរៈ លាវ កែវមុន្នី, ឥស្សរៈ សឺង ង៉ុកមិញ ប៉ុនពួកឥស្សរៈអស់នេះ អ្នកណាបង្កើត? គឺវៀតណាមបង្កើត។ វៀតណាម យកលទ្ធិកុម្មុយនីស្តចូលមកក្នុងប្រទេសកម្ពុជា ហើយបង្កើតឲ្យជាមានបក្សកុម្មុយនីស្តនៅកម្ពុជា។ ប៉ុន្តែពេលនោះប្រជាជនកម្ពុជាស្អប់វៀតណាម ស្អប់វៀតណាមណាស់ ហើយមិនចូលចិត្តបក្សកុម្មុយនីស្តទេ។ ដូច្នោះ មិនមានអ្នកណាចូល។ ដល់អ៊ីចឹង វៀតណាមនេះរកបានមនុស្សដែលនៅខាងកូសាំងស៊ីន មានបីបួននាក់។ ឧទាហរណ៍ដូចជា សឺង ង៉ុកមិញ ពីដើមឈ្មោះអាចារ្យមាន ប៉ុនទៅបួសនៅភ្នំពេញ វៀតណាមទាក់ទងបាន បួសនៅវត្តសឿងភឿក ខ្ញុំចាំ។ ទាក់ទងបាន ស៊ីវ ហេង សុទ្ធតែខ្មែរក្រោម។ ទាក់ទងបាន ឡាំ ផៃ ខ្មែរក្រោម។

[១១:៣៤:២១]

ដូច្នេះ ចាត់តាំងជាគណៈជាតិ "មុតគាហា"។ ដូច្នោះបក្សកុម្មុយនីស្តខ្មែរ បក្សកុម្មុយនីស្តកម្ពុជា មិនមែនប្រសូតចេញអំពីចលនាតស៊ូរបស់ប្រជាជនកម្ពុជាទេ គឺវៀតណាមយកមកដាក់។ នេះខ្ញុំនិយាយពិតតែម្តង។ ដូច្នោះបក្សនេះ វាកើតឡើងក្នុងចលនាមានអាវុធហើយ គឺឆ្នាំ១៩៤៦ មានចលនាឥស្សរៈកាន់អាវុធប្រឆាំងបារាំងហើយ។ ដូច្នោះ បក្ខជនខ្មែរដែលជាជនកុម្មុយនីស្ត អត់មានបានការតស៊ូអីដូចបក្សគេទៀតទេ មិនមែនតស៊ូសម្ងាត់ទេ មិនមែនកកើតឡើងពីតូចទៅធំ ពីតិចទៅច្រើនទេ នេះជាការលក្ខណៈពិសេសរបស់បក្សកុម្មុយនីស្តកម្ពុជា។

មានលក្ខណៈពិសេសអីចឹង លោកតា ទូ សាមុត ដែលជាលេខាបក្សគាត់និយាយថា បក្សយើងបក្សកុម្មុយនីស្តខ្មែរ វាមិនមែនសម្រាលចេញខ្លួនវាទេ វាសម្រាលចេញតាមឆ្អឹងជំនីរ បានសេចក្តីថា វាមិនមែនធម្មជាតិទេ គេនាំមកទេ គេនាំពីក្រៅចូលមកទេ។ វាមិនមែនកើតនៅក្នុងស្រុកឯងទេ នេះ ដល់អីចឹងបក្សនេះអត់ចម្រើន។ ព្រោះនៅក្រោមការដឹកនាំរបស់ដឹកនាំវៀតណាមទាំងអស់។

គណៈជាតិ "មុតគាហា" ដែលមាន សឺង ង៉ុកមិញ ជាប្រធាន ក៏នៅក្រោមការដឹកនាំរបស់បក្សកុម្មុយនីស្តឥណ្ឌូចិន ដែលមាន ង្វៀង ថាញ់សឺន ជាអគ្គលេខាបក្សនៅកូសាំង ស៊ីន នៅវៀតណាខាងត្បូង។ ដូច្នោះអ្វីៗទាំងអស់ ង្វៀង ថាញ់សឺន ជាអ្នកសម្រេច។ ឯបក្សកុម្មុយនីស្ត ឯគណៈជាតិ "មុតគាហា" ដែលខ្មែរនៅ ជាអាយ៉ង។ ខ្ញុំជម្រាបឲ្យត្រង់តែម្តងទៅ ជាអាយ៉ងរបស់វៀតណាម។ ស្អីៗទាំងអស់ សម្រេចវៀតណាមសម្រេច។ បញ្ហានេះ ខ្ញុំសូមជម្រាបតទៅទៀត គឺថាវៀតណាមនេះទុកចិត្តខ្ញុំ។ ដូច្នោះមានបានចាត់តាំងឲ្យខ្ញុំទៅរៀននៅភាគខាងជើងវៀតណាម។ ទៅភាគខាងជើងវៀតណាម ខ្ញុំឃើញឯកសារលក្ខន្តិកៈបក្ស អំពីរឿងចាត់តាំងសហព័ន្ធឥណ្ឌូចិន និយាយថា ពេលណាប្រទេសកម្ពុជា វៀតណាម លាវ បានឯករាជ្យហើយ ត្រូវចាត់តាំងសហព័ន្ធឥណ្ឌូចិនក្រោមការត្រួតត្រារបស់វៀតណាម។

[១១:៣៧:៥០]

ខ្ញុំស្រងាកចិត្ត ខំតស៊ូជាមួយបារាំងត្រូវយកឯករាជ្យ ចុះបើឯករាជ្យហើយមកធ្វើខ្ញុំគេទៀតនោះវាតស៊ូធ្វើអី?

ក៏ប៉ុន្តែអ្នកដែលនៅនិយមវៀតណាមក៏មាន មិនមានគ្មានទេ។ ដល់អីចឹង មានកិច្ចព្រមព្រៀងហ្សឺណែវឆ្នាំ១៩៥៤ ខ្ញុំត្រឡប់មកប្រទេសវិញ។ ត្រឡប់មកប្រទេសវិញអស់រលីង ពួកខ្មែរដែលតស៊ូតាមកិច្ចព្រមព្រៀងហ្សឺណែវ ត្រូវរំសាយចូលទៅរស់នៅក្នុងសង្គមជាតិ ក្រោមការដឹកនាំ ក្រោមការ

ត្រួតត្រារបស់រាជរដ្ឋាភិបាលកម្ពុជា។ ក៏ប៉ុន្តែទោយ៉ាងម៉េច ត្រូវចាប់ ត្រូវចង ត្រូវដាក់គុក ដាក់ច្រវាក់ កាលនោះសម័យគូរុនផង សម័យ លន់ នល់ផង សុទ្ធតែពួកឃោរឃៅ។

[១១:៣៩:០៩]

អស់កសិករ អស់ស្រែ អស់ភ្លឺ លក់បញ្ចាំដើម្បីលោះប្តី លោះប្រពន្ធ ដល់ការតស៊ូនេះវាអស់ហើយ ផុតអស់ពូជតស៊ូហើយ សរុបទៅនៅសល់តែពីរសាខាបក្ស គឺសាខាបក្សមួយនៅត្រាំកក់ ខាងនិរតី សាខាមួយទៀតនៅកំពង់ឆ្នាំង គឺសាលាបក្សឃុំពាម។ មានតែបីៗនាក់។ តើធ្វើយ៉ាងម៉េច? គ្មានអ្នកណាស្តាររួចទេ ហើយវៀតណាមអត់អនុវត្តតាមកិច្ចព្រមព្រៀងហ្សឺណែវទេ។

ខ្ញុំសូម ជម្រាប វៀតណាមលាក់កម្លាំងទុកនៅកម្ពុជាដើម្បីបន្តធ្វើសកម្មភាព សម្រាប់តស៊ូនៅវៀតណាមខាងត្បូង។ ដូច្នោះ ឡេ យន់ នេះ ហៃ សូ នេះ ហើយពួកដឹកនាំវៀតណាមប៉ុន្មាននាក់ទៀតទៅនៅស្រុកខ្មែរ ទាំងអស់ ពីព្រោះនៅព្រៃនគរមិនបានទេ បារាំងបង្ក្រាបចាប់ចង។ ហើយកាលនោះអាមេរិកចូលហើយ នៅមិនបាន ទៅពឹងពាក់ប្រទេសកម្ពុជានៅ។ នេះដែលខ្ញុំចង់និយាយថា ហើយទៅនេះ ទៅដឹកនាំពួកឥស្សរៈមួយចំនួន ដូចជាឥស្សរៈ កៅ តក់ ឥស្សរៈ ពុត ឆាយ ឲ្យចូលក្នុងកងទ័ព។ ពួកអស់នេះ សុទ្ធតែពួកចោរព្រៃ ពួកឃោរឃៅ ពួកធ្វើផលប្រយោជន៍ផ្ទាល់ខ្លួន តែយកនាមជាឥស្សរៈជាអ្នកស្នេហាជាតិ ដើម្បីរកផលប្រយោជន៍ផ្ទាល់ខ្លួន។ ខ្ញុំពេលនោះ ខ្ញុំនៅរៀន-- ខ្ញុំទៅធ្វើការនៅថៃ ខ្ញុំចាំសង្កេតមើល តើសភាពការណ៍យ៉ាងម៉េច? ខ្ញុំឃើញមិនស្រួលទេ ប្រទេសខ្មែរយើង បើថាអ្នកដឹកនាំយ៉ាងនេះ មិនកើតទេ។

[១១:៤២:០១]

ដល់អ៊ីចឹង តមកទៀត ខ្ញុំសូមជម្រាបថា ខ្ញុំបានទាក់ទងជាមួយបក្សថៃដែលខ្ញុំចូលហើយនោះសុំមកធ្វើការនៅកម្ពុជា ដូចជាខ្ញុំបានជម្រាបហើយ។ ដល់មកនេះ ខ្ញុំឃើញច្បាស់តែម្តង ស៊ីទាំងអស់នៅក្រោមការដឹកនាំរបស់វៀតណាម។ តាំងពីដាំបាយទៅក៏វៀតណាមដាំបាយ ខ្មែរអត់ឲ្យធ្វើអី ខ្មែរគ្រាន់តែរត់សំបុត្រ ខ្មែរគ្រាន់តែធ្វើនីរសារ ខ្មែរគ្រាន់តែកូនទាហាន។ មាន មានមេបញ្ជាការជាខ្មែរ ខ្ញុំលើកឧទាហរណ៍ខ្លះ ដូចជានៅភូមិភាគពាយព្យ មេបញ្ជាការជាខ្មែរ ក៏ប៉ុន្តែបញ្ជាការមែនទែនទៅ វៀតណាមបញ្ជាការ មិនមែនខ្មែរទេ។ ឯខ្មែរគ្រាន់តែមានឈ្មោះ ដើម្បីបញ្ឆោតប្រជាជន នេះ ដល់មានកិច្ចព្រមព្រៀងហ្សឺណែវ ដូចខ្ញុំបានជម្រាបនិយាយអ៊ីចឹង មួយចំនួន វៀតណាមមួយចំនួនទៅត្រឡប់ទៅស្រុកគេវិញ ក៏ប៉ុន្តែគេទុកប្រហែលជាយកខ្មែរទៅអប់រំនៅវៀតណាម នៅហាណូយ ខ្លះថា១៥០០នាក់ ខ្លះថា

២០០០ ប៉ុន្តែចំនួនប្រហែលជា២០០០ វៀតណាមយកទៅអប់រំ ដើម្បីកសាងជាកម្មាភិបាលរបស់គេទុកមកធ្វើសកម្មភាពនៅប្រទេសកម្ពុជាវិញ។ នេះ រឿងនេះវាអ៊ីចឹង។

[១១:៤៤:០២]

ដូច្នោះ គ្មានបក្សកុម្មុយនីស្តខ្មែរទេ។ ខ្ញុំសូមជម្រាបអ៊ីចេះ មានតែបក្សកុម្មុយនីស្តឥណ្ឌូចិន ឯបក្សកុម្មុយនីស្តខ្មែរ វានៅក្រោមបក្សកុម្មុយនីស្តឥណ្ឌូចិនទេ ហើយនៅក្រោមការដឹកនាំរបស់វៀតណាមទាំងអស់ ខ្មែរអត់ចេះធ្វើអី ចេះតែរត់សំបុត្រ។ នេះ ខ្ញុំសូមជម្រាបឲ្យអស់ អំពីរឿងនេះ ហើយខ្ញុំមិនមែនខ្ញុំវាយប្រហារវៀតណាមទេ នេះជាការពិតៗ។

ខ្ញុំឃើញថាកាលពី-- ដល់មកក្រោយទៀត មានការកិច្ចព្រមព្រៀងហ្សឺណែវហើយ ឆ្នាំ១៩៦០ៗ មានបញ្ញាជនបក្សពីស្រុកបារាំងទៅមួយចំនួន ដូចជា សាឡុត ស, អៀង សារី អីអស់នេះទៅ។ ហើយបក្សខ្មែរដែលចូលបក្សថៃមួយចំនួនក៏ត្រឡប់មកប្រទេសវិញ បីបួននាក់។ ហើយបក្សដែលវៀតណាមចាត់តាំង គេហៅថា “ខ្មែរវៀតមិញ” នោះ! ក៏មានមួយចំនួនដែរ។ ដូច្នោះបក្សកុម្មុយនីស្តខ្មែរហ្នឹង វាកើតមកវាៗបីផ្នែក។ មានចម្រុះស្រុកបារាំង បក្សកុម្មុយនីស្តឥណ្ឌូ-- នែ៎! វៀតមិញ ហើយបក្សមកពីថៃ។

ទ្រឹស្តីម៉ាក្សលេនីនវាតែមួយ ក៏ប៉ុន្តែវិធីដំណើរការវាខុសគ្នា។ សតិអារម្មណ៍វាខុសគ្នា ការរស់នៅវាខុសគ្នា ដល់ទៅអ៊ីចឹងបក្សនេះទៅរឹងមិនបានទេ។

[១១:៤៦:៣២]

កើតការបែកបាក់ៗគ្នា កើតការគុំកួន ការចោទប្រកាន់ ការអីៗគ្រប់យ៉ាងទាំងអស់។ នេះហើយដែលខ្ញុំសូមជម្រាបថា កុំយល់ថាបក្សកុម្មុយនីស្តខ្មែរ ដែលកើតចេញពីចលនាខ្មែរ មិនមែនទេ។ វាកើតពីវៀតណាម គេបង្កើតឡើង។ នេះខ្ញុំសូមជម្រាបឲ្យយល់ អំពីបញ្ហានេះ។ ដល់អ៊ីចឹងកើតរដ្ឋប្រហារ លន់ នល់ ទម្លាក់ព្រះករុណា។ ពេល លន់ នល់ ទម្លាក់ព្រះករុណាហើយ ព្រះករុណាបានអំពាវនាវឲ្យប្រជាជនខ្មែរចូលព្រៃម៉ាគី ពួកមួយចំនួនក៏ល្អ ឯពួកមួយចំនួនក៏មិនល្អ។ ពួកអ្នកលេងកាប់ចាក់ ពួកឥស្សរៈចាស់ ពួក ដាប ឈួន ពួក ហ៊ុល វង្សអានុភាព ពួកអីៗអស់នេះ គេហៅសុទ្ធតែពួកធ្លាប់ចោរព្រៃ។ ចូលទៅព្រៃម៉ាគី ចូលទៅធ្វើឥស្សរៈដែរ។ ពួកនេះហើយ ដែលកាប់សម្លាប់ប្រជាជន ដើរប្លន់ប្រជាជន ហើយទម្លាក់មកលើបក្សកុម្មុយនីស្តខ្មែរ ទម្លាក់មកលើកម្ពុជាប្រជាធិបតេយ្យ។ ខ្លះតែងខ្លួនស្លៀកឈុតខ្មៅពាក់ខ្មៅធ្វើជាកងទ័ពឥស្សរៈ-- ធ្វើជាកងទ័ពរំដោះជាតិ ក៏ប៉ុន្តែចាប់ប្រជាជនយកលុយ យកកាត់។ នេះខ្ញុំ

សូមជម្រាប។ ស្មុគស្មាញមហាស្មុគស្មាញ ហើយច្របូកច្របល់ មិនដឹងជាអីៗទេ។

រហូតដល់ លន់ នល់ ក៏មាន ក្នុងជួរ លន់ នល់ ហ្នឹងក៏មានពួកក្បត់ដែរ ហើយក៏ក្នុងកងទ័ពខាងខ្មែរក្រហមនេះ ក៏មានពួកក្បត់ដែរ។ ដូច្នោះយ៉ាងម៉េច? សហការគ្នា ហៅកប៉ាល់ហោះអាមេរិកមកទម្លាក់គ្រាប់បែក។ អាមេរិកចាប់ផ្ដើមទម្លាក់គ្រាប់បែកនៅកម្ពុជាតាមខ្ញុំចាំ ថ្ងៃទី១៧ ខែឧសភា រហូតមក រហូតដល់-- នេះហើយ នេះជាប្រវត្តិ-- ដូចនេះជាប្រវត្តិនៃបក្សដែលហៅថា "បក្សកុម្មុយនីស្តខ្មែរ" នោះ វាអ៊ីចឹង។ ដូច្នេះវាមិនមែនចេញមកពីចលនាប្រជាជនខ្មែរទេ ខ្ញុំសូមជម្រាបយ៉ាងនេះឲ្យៗស្មោះត្រង់ទៅចុះ។

[១១:៥០:៣១]

ដើម្បីកុំយល់ច្រឡំថា ប្រជាជនខ្មែរនេះ"និយមយួន" ថាប្រជាជនខ្មែរនេះ"ជាឧក្រិដ្ឋកម្មសង្គ្រាម" ជាអីៗដូចជាសេចក្ដីចោទអម្បាញ់មិញនេះ។ ខ្ញុំថាមិនមែនខ្មែរទេ គឺនៅក្រោមការបញ្ជាដឹកនាំរបស់យួនទាំងអស់ពីហាណូយមកទាំងអស់ ពីហូជីមិញមកទាំងអស់។ ដូច្នោះ ទម្លាក់ឧក្រិដ្ឋកម្មសង្គ្រាម សង្គ្រាមប្រល័យពូជសាសន៍ សង្គ្រាមអីៗអស់នេះ វាមិនមែនខ្មែរនិងខ្មែរទេ។ យួននិងខ្មែរ យួនសម្លាប់ខ្មែរ។ នេះខ្ញុំសូមជម្រាបសង្ខេបនូវប្រវត្តិដើម្បីឲ្យយល់ កុំច្រឡំ ដើម្បីយុវជនជំនាន់ក្រោយយល់ប្រវត្តិសាស្ត្រឲ្យល្អិតនេះ ខ្ញុំនិយាយមិនលម្អិតទេ។ កុំយល់ថាខ្មែរក្រហមវាអាក្រក់ ខ្មែរក្រហមប្រល័យពូជសាសន៍ ខ្មែរក្រហមជាឧក្រិដ្ឋកម្មសង្គ្រាម ខ្មែរក្រហមទៅស្អីៗទាំងអស់ វាអត់សោះ។ ពីព្រោះអី? ពីព្រោះប្រជាជនខ្មែរជាពុទ្ធសាសនិកជន កាន់ព្រះពុទ្ធសាសនា។ ទោះបីជាបក្សកុម្មុយនីស្តហើយក៏ដោយ យ៉ាងម៉េចក៏សំពះព្រះ អុជធូបសំពះព្រះដែរយប់ៗ ខ្ញុំសូមជម្រាបឲ្យត្រង់ខ្លួនខ្ញុំក៏ដោយ។ បេ៥២មកហើយ គុណឪពុក គុណម្ដាយអើយជួយ! យកដីរោយក្បាលហើយ។

[១១:៥២:៣០]

ដូច្នោះ វាមិនមែនកុម្មុយនីស្តសាកលទេ មានធាតុជាតិជាកុម្មុយនីស្តស្នេហាជាតិ ស្នេហាប្រជាជន ស្នេហាពូជសាសន៍ ការពារជាតិ។ ដូច្នោះ ហើយបានជាមិនសុខចិត្តនៅក្រោមការដឹកនាំរបស់យួនបានជាយួនបង្កើតឲ្យមានសង្គ្រាមថ្ងៃ១៧ មករា ឆ្នាំ១៩៨០ រហូតមកដល់សព្វថ្ងៃនេះយ៉ាងម៉េច? យួនប៉ុន្មានលាននៅប្រទេសកម្ពុជា? នេះអាណិកជនយួនស្របច្បាប់ និងមិនស្របច្បាប់មានប៉ុន្មានលាន តើប្រទេសខ្មែរអនាគតទៅជាស្អី? ខ្ញុំសូមជម្រាបអ៊ីចឹង។ អនាគតប្រទេសកម្ពុជា បើមិនខំទេណា ខ្ញុំថារលាយហើយ និយាយយ៉ាងនេះ។

[១១:៥៣:៤០]

បញ្ចប់នេះ ខ្ញុំសូមជម្រាបលោកប្រធាន! ការដែលសម្តេចព្រះ សីហនុ ថ្ងៃខែ ទ្រង់យាងទៅទត ប្រទេសកម្ពុជាកាលពីសម័យសង្គ្រាមឆ្នាំ១៩៧៣ ទៅដល់កំពង់ធំ-- ទៅដល់កំពង់គ្រំ ប៉ុល ពត ប្រគល់ភារកិច្ចឲ្យខ្ញុំរៀបចំតាមផ្លូវពីកំពង់គ្រំទៅសៀមរាប ដើម្បីការពារសម្តេច។

ខ្ញុំឮក្មេងឃ្វាលក្របីវាច្រៀង ដែលខ្ញុំសូមសូត្របញ្ចប់ចុះ៖

“អនិច្ចាខ្មែរយើង យើងនេះអើយៗ
ជាតិនឹងសូន្យហើយ កុំព្រងើយត្រូវខំប្រឹងឡើង។”

ខ្ញុំស្រក់ទឹកភ្នែក ឱ!ជាតិយើងហើយ នេះកូនក្មេងឃ្វាលក្របី វាច្រៀង។ ដូច្នោះ ការប្រល័យពូជសាសន៍អីៗដែលចោទទាំងប៉ុន្មាននេះ ខ្ញុំយល់ឃើញថា ជាការចោទដែលខុសទទេ។ ច្រឡំមិត្ត ច្រឡំសត្រូវ មើលសត្រូវជាមិត្ត។ សព្វថ្ងៃនេះ គេកំពុងរឹតរួតឆ្អឹងដូចជាពោះថ្លាន់រួតកូនឈ្លូសឲ្យទន់ឆ្អឹង ដើម្បីលេប។ ថ្ងៃណាមួយគង់គេលេបទេ នេះខ្ញុំសូមជម្រាបឲ្យត្រង់តែម្តង។ ហើយថា ខ្ញុំយ៉ាងម៉េចថាទៅ។ ប៉ុន្តែទោះជាយ៉ាងនេះក៏ដោយ ជំហរខ្ញុំនៅតែរក្សាសាមគ្គី ចង់ស្រុះស្រួលគ្នារស់នៅជាប្រទេសជិតខាងគ្នាដោយសុខសន្តិភាព។ ជាមួយយួន ជាមួយវៀតណាមក៏ដោយ ជាមួយថៃក៏ដោយ ក៏ប៉ុន្តែប្រយ័ត្នដូចជាក្មេងឃ្វាលក្របីវាឆ្លៀតច្រៀងអីចឹង “អនិច្ចាខ្មែរយើង យើងនេះអើយៗ ជាតិហ្នឹងសូន្យហើយ កុំព្រងើយត្រូវខំប្រឹងឡើងៗ”។

[១១:៥៦:១៨]

នេះខ្ញុំសូមជម្រាបប្រវត្តិដែលចោទថា ខ្ញុំយ៉ាងនេះ ខ្ញុំយ៉ាងនោះ។ វាគ្មានៗសោះ ស្មោះត្រង់នឹងជាតិអស់ពីចិត្តពីថ្លើម លះបង់គ្រួសារ លះបង់ឲ្យនិយាយអីចឹងមិនមែនអួតខ្លួនឯងទេ គេឯទៀត គេលះបង់ដែរ។ ប៉ុន្តែសូមជម្រាប លោកប្រធានឲ្យជ្រាបឲ្យច្បាស់ ជម្រាបតុលាការ ហើយមានព្រះសង្ឃ ជាសាក្សី។

នេះខ្ញុំសូមបញ្ចប់ដោយសង្ខេបតែប៉ុណ្ណឹង។ សូមអរគុណលោកប្រធាន ដែលអនុញ្ញាតឲ្យខ្ញុំបាននិយាយដោយសង្ខេប ប៉ុន្តែបើឲ្យខ្ញុំអានសៀវភៅ លើសនេះទៀត នេះខ្ញុំនិយាយមាត់ទទេ។ សូម ខ្ញុំសូមចប់។ សូមអរគុណលោកប្រធាន។

**ប្រធានអង្គជំនុំ៖**

បាទ, អរគុណលោក នួន ជា ដែលបានធ្វើការបង្ហាញដល់អង្គសវនាការអំពីប្រវត្តិសង្ខេបនៃបក្ស

កុម្មុយនីស្តកម្ពុជា នៃប្រវត្តិនៃការតស៊ូរបស់លោកតាំងពីកុមារភាពរហូតមកនៅក្នុងកិច្ចប្រឹងប្រែងនេះ។ ហើយដោយសារបញ្ហាពេលវេលាបានដល់ទី ដែលត្រូវសម្រាកពិសាអាហារថ្ងៃត្រង់ហើយ អ៊ីចឹងអង្គជំនុំជម្រះប្រកាសសម្រាកពិសាអាហារថ្ងៃត្រង់ចាប់ពីពេលនេះតទៅ រហូតដល់ម៉ោងដប់បី និងសាមសិបនាទីរសៀលនេះ សូមអញ្ជើញចូលវិញ ដើម្បីបន្តកិច្ចដំណើរការសវនាការ។ ហើយភាគី និងសាធារណជនសូមអញ្ជើញមកកាន់ទីកន្លែងរៀងៗខ្លួនឲ្យបានមុនម៉ោងដប់បីនិងសាមសិបនាទី គឺម៉ោងមួយកន្លះរសៀលនេះ។ ហើយអនុរក្សមន្ទីរឃុំឃាំងឲ្យនាំជនជាប់ចោទទាំងបីរូបទៅកាន់បន្ទប់រង់ចាំខាងក្រោម ហើយនិងឲ្យនាំគាត់ឡើងមកសាលសវនាការនេះវិញនៅរសៀលនេះ ឲ្យបានមុនម៉ោងមួយ និងសាមសិបនាទីជាកំណត់។ សូមសម្រាកចុះ!

[១១:៥៨:២៧]

**ក្រឡាបញ្ជី៖**

សូមអញ្ជើញក្រោកឈរ!

*(សវនាការសម្រាកពីម៉ោង ១១:៥៩ នាទី ដល់ម៉ោង ១៣:៣២ នាទី)*

[១៣:៣២:៥៨]

**ប្រធានអង្គជំនុំ៖**

សូមអញ្ជើញអង្គុយចុះ!

អង្គជំនុំជម្រះប្រកាសបន្តកិច្ចដំណើរការនីតិវិធីសវនាការ។

**ក្រឡាបញ្ជី៖**

សូមជម្រាបលោកប្រធាន! នៅក្នុងសវនាការថ្ងៃនេះក្រឡាបញ្ជីនៃអង្គជំនុំជម្រះកត់សម្គាល់ឃើញនូវវត្តមានរបស់លោកមេធាវី វែកគែន អាកទួរ (*Arthur VERCKEN)* ដែលជាមេធាវីក្នុងក្រុមរបស់មេធាវីការពារជនជាប់ចោទ ខៀវ សំផន។

[១៣:៣៣:៣៧]

លោកមេធាវី វែកគែន អាកទួរ ត្រូវបានទទួលស្គាល់ដោយគណៈមេធាវីនៃព្រះរាជាណាចក្រកម្ពុជា ព្រមទាំងបានធ្វើសម្បថនៅសាលាឧទ្ធរណ៍រួចហើយ ដោយមានភ្ជាប់មកជាមួយនូវកំណត់ហេតុនៃការធ្វើសច្ចាប្រណិធាន ចុះថ្ងៃទី០៥ ខែធ្នូ ឆ្នាំ២០១១។ សូមអរគុណ។

**ប្រធានអង្គជំនុំ៖**

អរគុណលោក ផារី។

ជាបន្តសូមអញ្ជើញមេធាវីជាតិការពារក្ដីឲ្យលោក ខៀវ សំផន គឺលោក គង់ សំអុន ឡើងធ្វើសេចក្ដីសូមទទួលស្គាល់មេធាវីអន្តរជាតិការពារក្ដីឲ្យលោក ខៀវ សំផន។

សូមអញ្ជើញ!

[១៣:៣៤:៣០]

**លោក គង់ សំអុន៖**

សូមអរគុណប្រធាន។ សូមគោរពក្រុមប្រឹក្សាជំនុំជម្រះ អង្គសវនាការទាំងមូល។ ខ្ញុំបាទមេធាវីជាតិការពារលោក ខៀវ សំផន សូមប្រកាសទទួលស្គាល់លោកមេធាវី អាកទួរ វែកគែន ជាមេធាវីជាសហមេធាវីអន្តរជាតិនៅក្នុងការការពារលោក ខៀវ សំផន នៅក្នុងសំណុំរឿង០០២ នេះ។ ហើយលោកមេធាវី វែកគែន ក៏ធ្លាប់មានបទពិសោធន៍ការពារក្នុងវិស័យតុលាការព្រហ្មទណ្ឌអន្តរជាតិផងដែរ។ ដូច្នេះសូមលោកប្រធានមេត្តាទទួលស្គាល់នៅក្នុងនីតិវិធីដូចតទៅ។ សូមអរគុណ។

**ប្រធានអង្គជំនុំ៖**

សូមអញ្ជើញក្រោកឈរលោក អាកទួរ វែកគែន ។ លោក អាកទួរ វែកគែន លោកត្រូវបានអង្គជំនុំជម្រះសាលាដំបូងទទួលស្គាល់ លោកជាមេធាវីការពារក្ដីឲ្យលោក ខៀវ សំផន សម្រាប់គោលបំណងនៃកិច្ចដំណើរការនីតិវិធីនៅចំពោះមុខអង្គជំនុំជម្រះសាលាដំបូងនេះ។ អនុលោមតាមការទទួលស្គាល់នេះលោកមានសិទ្ធិ និងបុព្វសិទ្ធិដូចគ្នានឹងមេធាវីជាតិការពារក្ដីឲ្យលោក ខៀវ សំផន ដែរ។

សូមអង្គុយចុះ!

សូមអញ្ជើញសហព្រះរាជអាជ្ញារង!

[១៣:៣៦:០០]

**លោក ឆេល លីសាក់៖**

ខ្ញុំសុំលើកបញ្ហាបឋមមួយ នៅកិច្ចប្រជុំក្រៅផ្លូវការកាលពីថ្ងៃសុក្រ បញ្ហាបានលើកឡើងពីក្រុមមេធាវីការពារក្ដីរបស់ នួន ជា។ ថាតើគាត់អាចប្រើប្រាស់ម៉ែលដែរឬទេ? យើងទទួលដំណឹងថា មិនអីទេ។ កំណត់សម្គាល់ហ្នឹងគឺវាមិនបញ្ហាទេ ក៏ប៉ុន្តែកំណត់សម្គាល់នោះត្រូវតែផ្ដល់ជូនទៅដល់អង្គជំនុំជម្រះនិងភាគីផងដែរ។ ខ្ញុំកត់សម្គាល់ឃើញថា លោក នួន ជា មានសំណុំឯកសារមួយបាច់កាលពី

ព្រឹកមិញនៅពេលដែលគាត់ធ្វើសេចក្ដីប្រកាស។ ដូច្នេះហើយខាងសហព្រះរាជអាជ្ញាស្នើសុំថា នៅពេលណាមួយនោះក្នុងកិច្ចដំណើរការនីតិវិធី ឯកសារដែលធ្វើសេចក្ដីប្រកាសនៅក្នុងសំណុំឯកសាររបស់លោក នួន ជា ហ្នឹង គួរតែដាក់បញ្ចូលក្នុងសំណុំរឿងផងដែរ។ យើងមិនចាំបាច់ដាក់សំណុំឯកសារទាំងអស់នោះនៅពេលនេះទេ ប៉ុន្តែអាចស្នើសុំអង្គជំនុំជម្រះឲ្យដាក់ឯកសារនោះនៅពេលណាមួយ ដើម្បីចូលជាសំណុំរឿង។ សូមអរគុណ។

[១៣:៣៧:១១]

**ប្រធានអង្គជំនុំ៖**

អរគុណបាទ។ សូមអញ្ជើញមេធាវី!

**លោក ម៉ៃខល ផេសមិន៖**

ឯកសារភាគច្រើននៅក្នុងសំណុំឯកសារពណ៌ខៀវនេះ គឺមាននៅក្នុងសំណុំរឿងរួចហើយ កូនក្ដីរបស់ខ្ញុំបានធ្វើកំណត់សម្គាល់ ប៉ុន្តែកំណត់សម្គាល់របស់គាត់នោះវាទាក់ទងទៅនឹងកាលបរិច្ឆេទតែប៉ុណ្ណោះ ហើយយើងខ្ញុំនឹងធ្វើការផ្ដល់ជូននូវឯកសារនោះ ជាពិសេសឯកសារដែលកត់ត្រាអំពីកាលបរិច្ឆេទតែប៉ុណ្ណោះ។ សូមអរគុណ។

[១៣:៣៧:៤៩]

**ប្រធានអង្គជំនុំ៖**

បាទអរគុណ។ ហើយមុននឹងចាប់ផ្ដើមកិច្ចដំណើរការតទៀត អង្គជំនុំជម្រះសូមធ្វើការឆ្លើយតប និងជម្រាបជូនទៅម្ចាស់សំណើកាលពីព្រឹកមិញ។ ទីមួយ គឺសំណើសុំរបស់មេធាវី អាង ឧត្ដម មេធាវីការពារក្ដីឲ្យលោក អៀង សារី ដែលមានការពាក់ព័ន្ធទៅនឹងការបំបែកចេញពីគ្នាដាច់ដោយឡែកដើមបណ្ដឹងរដ្ឋប្បវេណី ឬក៏សាក្សី ដែលមានលើសពីចំនួនពីរនាក់ ដើម្បីកុំឲ្យគាត់បានទទួលព័ត៌មានផ្សេងៗដែល ឬក៏ស្ដាប់នូវការផ្ដល់សក្ខីកម្ម ឬក៏ធ្វើសេចក្ដីថ្លែងការណ៍ពីពេលមុនរបស់សាក្សី ដែលបានធ្វើ ឬក៏ដើមបណ្ដឹងរដ្ឋប្បវេណី ដែលបានធ្វើរួច។ អង្គជំនុំជម្រះសូមជម្រាបថា ដោយផ្អែកតាមចរិតលក្ខណៈនៃតុលាការនេះ ដូចអង្គជំនុំជម្រះបានជម្រាបជូនមេធាវីកាលពីព្រឹកមិញហើយថា តុលាការនេះជាតុលាការព្រហ្មទណ្ឌវិសាមញ្ញក្នុងតុលាការកម្ពុជា ដែលមានចរិតលក្ខណៈដោយឡែកពីតុលាការជាតិ ហើយលក្ខណៈនេះគឺមានភាពខុសគ្នាឆ្ងាយមែនទែន។ ដូច្នេះ បទប្បញ្ញត្តិនៅក្នុងកម្រិតជាតិ ទំនងជាមិនអាចយកមកអនុវត្តទាំងស្រុងនៅតុលាការនេះបានទេ។

[១៣:៣៩:១២]

ទីពីរ ពិតមែនហើយដោយសារពាក់ព័ន្ធនឹងបញ្ហានេះវាជាតុលាការជាតិដែរនោះ វិធាន៨៨ ក៏បានបង្ហាញច្បាស់អំពីបញ្ហានេះមួយចំនួនគឺ ៨៨(២) បានបង្ហាញថា ជនជាប់ចោទមិនត្រូវប្រាស្រ័យទាក់ទងគ្នាទេ ប្រសិនបើគេអាចធ្វើទៅបានអ្នកជំនាញ និងសាក្សី ត្រូវស្ថិតនៅក្នុងបន្ទប់ផ្សេងដែលមិនអាចមើលឃើញ ឬឮពីអ្វីដែលប្រព្រឹត្តនៅក្នុងបន្ទប់សវនាការទេ នៅពេលស្ថិតនៅក្នុងបន្ទប់នោះ សាក្សីមិនត្រូវប្រាស្រ័យទាក់ទងគ្នានឹងគ្នាទេ។ បញ្ហានេះខ្ញុំសូមជម្រាបជូនដល់ម្ចាស់សំណើថា យើងប្រឹងប្រែងនៅក្នុងការអនុវត្តជាអតិបរមា នូវបទប្បញ្ញត្តិដែលមានចែងនៅក្នុងវិធាន៨៨ អនុវិធាន២នេះ នៅក្នុងការប្រាស្រ័យទាក់ទងគ្នារវាងសាក្សីនិងអ្នកជំនាញ។ ហើយអង្គជំនុំជម្រះបាន និងបញ្ជាក់បន្ថែមទៀតទៅដល់អង្គភាពគាំពារសាក្សី និងអ្នកជំនាញ ដើម្បីឲ្យរិះរកមធ្យោបាយណាដែលល្អបំផុតដែលជាអតិបរមាដើម្បីអនុវត្តនូវបទប្បញ្ញត្តិនេះឲ្យបានល្អប្រសើរតាមដែលអាចធ្វើទៅបាន។ ពីព្រោះបទប្បញ្ញត្តិនេះដោយសារអង្គជំនុំវិសាមញ្ញក្នុងតុលាការកម្ពុជាប្រមើលមើលនូវបញ្ហាដែលមិនអាចគ្រប់គ្រងបានទាំងស្រុង ទើបបានវិសោធនកម្មនូវវិធាននេះឡើង គឺកម្រិតត្រឹមតែប្រសិនបើអាចធ្វើទៅបានប៉ុណ្ណោះ។

អ៊ីចឹងយើងគឺយើងនឹងអនុវត្តតាមអ្វីដែលយើងមានបទពិសោធន៍នៅក្នុងការដំណើរការរឿងក្តី ០០១ កន្លងមក។

[១៣:៤១:០០]

បញ្ហាទីពីរ គឺចំពោះដើមបណ្តឹងរដ្ឋប្បវេណី១ជាគូភាគីនៅក្នុងរឿងក្តី ដូច្នេះវិធាននេះមិនគ្របដណ្តប់ទៅនឹងការកំហិតសិទ្ធិ ការចូលរួមរបស់ដើមបណ្តឹងរដ្ឋប្បវេណីទេ។ ដើមបណ្តឹងរដ្ឋប្បវេណីអាចចូលរួមទៅតាមក្របខ័ណ្ឌនៃទីកន្លែងដែលបានរៀបចំជូនគាត់នៅពីក្រោយមេធាវីនាំមុខតំណាងដើមបណ្តឹងរដ្ឋប្បវេណី។ ចំពោះអ្នកដែលចូលរួមផ្សេងទៀត គឺគាត់អាចចូលរួមបាននៅកន្លែង ជាមួយនឹងកន្លែងសាធារណជន។ នេះគឺជាការរៀបចំនូវពាក់ព័ន្ធនឹងបញ្ហាសាក្សី និងអ្នកជំនាញដែលត្រូវឆ្លើយ ផ្តល់សក្ខីកម្មនៅចំពោះមុខអង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា។

ហើយជាកិច្ចបន្ត អង្គជំនុំជម្រះសូម ខ្ញុំសូមប្រគល់វេទិកានេះទៅលោកស្រីចៅក្រម ស៊ីលវៀ ខាតវ៉ាយថ៍ ដើម្បីអាចឆ្លើយបំភ្លឺទៅនឹងសំណើសុំរបស់មេធាវីការពារក្តី នួន ជា ដែលបានធ្វើសំណើកាលពីព្រឹកមិញ។

[១៣:៤២:០៩]

**ចៅក្រម ស៊ីលវៀ ខាតវ៉ាយថ៍៖**

សូមអរគុណលោកប្រធាន កាលពីព្រឹកមិញមេធាវីខាងលោក នួន ជា បានលើកឡើងនូវបញ្ហាចំនួនពីរ។ បញ្ហាទីមួយ គឺឯកសារដែលបានលើកឡើងនៅក្នុងកថាខណ្ឌនីមួយៗដូចដែលបានអាននៅក្នុងដីកាចោទប្រកាន់ ហើយនិងលេខយោងទៅលើកថាខណ្ឌទាំងអស់នោះ។ នៅពេលដែលស្នើសុំ មេធាវីការពារក្តីបានយោងទៅលើឯកសារចុះថ្ងៃ១៧ ខែវិច្ឆិកា ឯកសារលេខ១៤១ ដែលក្នុងនោះ អង្គជំនុំជម្រះបានលើកឡើងថា "ឯកសារទាំងឡាយដែលបានយោងនៅក្នុងកថាខណ្ឌនីមួយៗ ដូចដែលបានអាន រួមទាំងលេខយោងជើងទំព័រ គឺចាត់ទុកថាបានដាក់នៅចំពោះមុខអង្គជំនុំជម្រះ"។ ឯកសារទាំងអស់នោះមិនថានៅក្នុងកថាខណ្ឌ ឬក៏នៅក្នុងលេខយោងជើងទំព័រ គឺចាត់ទុកថាបានដាក់នៅចំពោះអង្គជំនុំជម្រះលើកលែងតែមានការតវ៉ាពីភាគីណាមួយ។

[១៣:៤៣:១២]

ប្រសិនបើមានការតវ៉ាណាមួយទៅលើឯកសារយោង ឬលេខយោងជើងទំព័រនោះ ពេលវេលានឹងត្រូវបានកំណត់ដោយអង្គជំនុំជម្រះដើម្បីបើកឲ្យភាគីធ្វើការជំទាស់។

ចំណុចទីពីរ ដែលបានលើកឡើង គឺការបង្ហាញនូវឯកសារមុនៗរបស់សាក្សី ដែលគ្រោងនឹងកោះហៅមកផ្តល់សក្ខីកម្មក្នុងសវនាការក្នុងតុលាការ។ អង្គជំនុំជម្រះបានបញ្ជាក់រួចមកហើយ ថាអង្គជំនុំជម្រះនឹងប្រើប្រាស់អង្គភាពគាំទ្រសាក្សី និងអ្នកជំនាញ ហើយយើងនឹងប្រើឯកសារដែលសាក្សីបានផ្តល់ជូននៅក្នុងដំណាក់កាលស៊ើបសួរមកដេញដោល។

[១៣:៤៣:៥៧]

យើង អង្គជំនុំជម្រះកត់សម្គាល់ឃើញថា ការអនុវត្តនៅក្នុងដំណាក់កាលស៊ើបសួរ ដែលថាសាក្សីត្រូវបានផ្តល់ជូននូវឯកសាររបស់ខ្លួនមួយច្បាប់។ ការធ្វើដូច្នេះដើម្បីធានាធ្វើយ៉ាងណាឲ្យសាក្សីគាត់អាចចងចាំឡើងវិញនូវអ្វីដែលគាត់បានលើកឡើងកាលពីប៉ុន្មានខែមុន។ ចម្លើយទាំងអស់នោះ គឺមិនអាចប្រើប្រាស់យកមកដាក់នៅក្នុងតុលាការនោះទេ គឺយើងនឹងដកហូតមកវិញនៅពេលដែលសាក្សី ឬអង្គភាពគាំពារសាក្សី អ្នកជំនាញបានប្រើប្រាស់រួចរាល់ហើយ។

ការដែលយើងធ្វើដូច្នេះ គឺដើម្បីគ្រាន់តែចង់ឲ្យសាក្សីចងចាំនូវការឆ្លើយរបស់គាត់តែប៉ុណ្ណោះកាលពីលើកមុន។ សេចក្តីសម្រេចពីរនេះគឺឆ្លើយតបទៅនឹងសំណើចំនួនពីរ ដែលបាន ដែលមេធាវីការពារក្តី នួន ជា បានលើកឡើងកាលពីព្រឹកមិញ។ សូមអរគុណ។

[១៣:៤៤:៥៣]

**ប្រធានអង្គជំនុំ៖**

សូមអញ្ជើញមេធាវី!

[១៣:៤៥:០៧]

**លោក អាកទួរ វែកកែន៖**

អភ័យទោស បើខ្ញុំស្តាប់ការបកប្រែជាភាសាបារាំង។ ចម្លើយទាក់ទងទៅនឹងសំណើរបស់មេធាវី នួន ជា កាលពីព្រឹកមិញនេះ ហើយខ្ញុំមិនយល់ថាលោកអនុញ្ញាតឲ្យសាក្សីមកចូលរួមនៅក្នុងសវនាការ មុននឹងបង្ហាញខ្លួននៅនឹងក្នុងសាលជំនុំជម្រះហ្នឹង។ តើអ៊ីចឹង ឬក៏មិនមែនអ៊ីចឹង?

**ប្រធានអង្គជំនុំ៖**

បាទ, មិនអ៊ីចឹងទេ។ សាក្សី ដែលនិង ជំនាញដែលនឹងអញ្ជើញមកផ្តល់សក្ខីកម្មនៅចំពោះមុខអង្គជំនុំជម្រះ អង្គជំនុំជម្រះនឹងធ្វើទំនាក់ទំនងជាមួយនឹងខាងអង្គភាពគាំពារនិងសាក្សី អ្នកជំនាញដើម្បីឲ្យរិះរកលទ្ធភាពនិងមធ្យោបាយណាល្អដែលបំផុត ដើម្បីអនុវត្តនូវបទប្បញ្ញត្តិនៃវិធាន៨៨(២) ឲ្យបានជាអតិបរមា។ លើកលែងតែការដែលហួសពីលទ្ធភាពមិនអាចធ្វើទៅបាន ដោយស្ថានភាពនៃការផ្សាយព័ត៌មានជាសាធារណៈដូចដែលយើងបានធ្វើសវនាការនេះ ដែលគេអាចស្តាប់ឮទៅឯផ្ទះរបស់គេ នៅតាមមធ្យោបាយផ្តល់សារព័ត៌មានផ្សេងៗ នោះ គឺវាហួសពីវិសាលភាព និងលទ្ធភាពដែលអង្គជំនុំជម្រះអាចគ្រប់គ្រងបាន។ ហើយបញ្ហានេះ យើងមានបទពិសោធន៍នៅក្នុងសំណុំរឿង០០១ ដែលមានស្ថានភាពស្រដៀងនេះ យើងបានប្រឹងប្រែងអនុវត្តដោះស្រាយបញ្ហានេះ គិតទៅនៅក្នុងសំណុំរឿង០០១ មិនមានបញ្ហាអ្វីប្រឈមកើតឡើងអំពីការអនុវត្តនូវវិធាន៨៨(២) នេះឡើយ។

[១៣:៤៦:៥៥]

ដើម្បីច្បាស់លាស់លោក ហ្សង់ម៉ាក ដែលប្រើភាសាបារាំង សូមអញ្ជើញជម្រាបគាត់ឲ្យបានច្បាស់លាស់បន្ថែម។ សូមអញ្ជើញ!

**ចៅក្រម ហ្សង់ម៉ាក ឡាវែន៍៖**

ខ្ញុំគិតហើយថាការពន្យល់របស់លោកហ្នឹង គឺថាបំភ្លឺស្ថានភាពនេះហើយ ក៏ប៉ុន្តែដើម្បីឲ្យយល់ទាំងអស់គ្នា ខ្ញុំសូមទាក់អារម្មណ៍របស់មេធាវីលើការដែលថា មានមនុស្សជាង៥០០នាក់ដែលអាចចូលរួមក្នុងសវនាការនេះបាន។ ដូច្នេះ យើងមិនអាចផ្ទៀងផ្ទាត់អត្តសញ្ញាណរបស់មនុស្សទាំងអស់គ្នាបាន

នោះទេ ថាដើម្បីដឹងថាតើពុំមានសាក្សី ឬក៏មានអ្នកជំនាញការណាមួយមានវត្តមាននោះទេ? អ៊ីចឹងវិធានផ្ទៃក្នុងត្រូវបានធ្វើវិសោធនកម្ម អ៊ីចឹងគឺថាគ្រាន់តែមានចែងថាបើសិនជាអាចធ្វើទៅបាន យើងនឹងធ្វើយ៉ាងណាដើម្បីកុំឲ្យមានសាក្សី ឬក៏អ្នកជំនាញការមានវត្តមាននៅក្នុងសាលសវនាការ។ ដូច្នេះ ពុំមានវិធានណាមួយជាកាតព្វកិច្ចនោះទេ គ្រាន់តែជាការផ្តល់ដំបូន្មាន ក៏ប៉ុន្តែដែលថាយើងត្រូវអនុវត្ត ដែលថាជួយដោយអង្គភាពគាំពារសាក្សី ហើយនិងអ្នកជំនាញ។

[១៣:៤៨:២១]

**ប្រធានអង្គជំនុំ៖**

បាទ, ជាកិច្ចបន្តនេះ អង្គជំនុំជម្រះសូមប្រគល់ភារៈជូនទៅលោកស្រី ស៊ីលវៀ ខាតវ៉ាយថ៍ ដើម្បីសួរសំណួរចំពោះជនជាប់ចោទ។ សូមអញ្ជើញលោកស្រីចៅក្រម!

**សួរដោយចៅក្រម ស៊ីលវៀ ខាតវ៉ាយថ៍៖**

សូមអរគុណលោកប្រធាន។

**ស៖** លោក នួន ជា កាលពីសប្តាហ៍មុនលោកបានបង្ហាញសេចក្តីប្រកាសយ៉ាងលម្អិត និងជាក់លាក់មួយជូនតុលាការ។ ហើយកាលពីព្រឹកមិញលោកបានបន្ថែមព័ត៌មានលម្អិតមួយចំនួនថែមទៀត។ នៅក្នុងសេចក្តីប្រកាសរបស់លោកក្នុងពេលឆ្លើយតបទៅនឹងសេចក្តីសន្និដ្ឋានបើកការចោទប្រកាន់ លោកបានសន្យាថានឹងជួយទៅដល់ប្រជាជនកម្ពុជាទាំងអស់ដែលលោកមានការគោរពស្រឡាញ់នោះ ឲ្យយល់អំពីប្រវត្តិសាស្ត្ររបស់កម្ពុជា។ ខ្ញុំសូមថ្លែងអំណរគុណចំពោះសេចក្តីប្រកាស និងព័ត៌មានលម្អិតដែលលោកបានបន្ថែមលើកឡើងបន្ថែមកាលពីព្រឹកមិញនេះ។

[១៣:៤៩:៣៤]

សេចក្តីប្រកាសនោះ វាមានប្រយោជន៍ និងវាមានលក្ខណៈស៊ីសង្វាក់គ្នាទៅនឹងអ្វីដែលលោកបានលើកឡើង។ ខ្ញុំចង់ចូលទៅដល់ចំណុចមួយ ឬក៏ពីរចំណុច។ កាលពីព្រឹកមិញ លោកបានជម្រាបអង្គសវនាការថា លោកបានចូលរួមចលនាកុម្មុយនីស្តដំបូងនៅប្រទេសថៃ ក្រោយមកនៅក្នុងប្រទេសកម្ពុជាដោយសារតែលោកមានការអាណិតអាសូរទៅដល់ប្រជាជនកម្ពុជា ដែលលោកបានលើកឡើងថា ត្រូវបានរងការគាបសង្កត់ និងធ្វើបាបដោយអាណានិគមបារាំងនៅពេលនោះ។ នៅពេលដែលលោកបានមកដល់ប្រទេសកម្ពុជាប្រហែលជានៅក្នុងឆ្នាំ១៩៥១ តើលោកបានចូលរួមជាមួយនឹងបក្សកុម្មុយនីស្តឥណ្ឌូចិនដែរឬទេ?

តើលោក នួន ជា ឮសំណួររបស់ខ្ញុំដែរឬទេ? តើលោកបានចូលរួមជាមួយនឹងបក្សកុម្មុយនីស្តឥណ្ឌូចិនដែរឬទេ នៅពេលដែលលោកមកដល់ប្រទេសកម្ពុជានៅក្នុងឆ្នាំ១៩៥១ នោះ?

**លោក នួន ជា៖**

**ឆ៖** សូមគោរពលោកប្រធាន! ខ្ញុំសូមអនុញ្ញាតឆ្លើយ។ ពេលដែលខ្ញុំមកដល់ប្រទេសកម្ពុជា កាលឆ្នាំ១៩៥១ មានវៀតណាមម្នាក់គេឧទ្ទេសនាមខ្ញុំឲ្យចូលក្នុងបក្សកុម្មុយនីស្តឥណ្ឌូចិន ពីព្រោះគេថាជាគោលការណ៍អ្នកឯងមកពីណា បក្សណាក៏ដោយ បើមកធ្វើសកម្មភាពនៅកន្លែងប្រទេសនេះ គឺវៀតណាមក្តី ឡាវក្តី កម្ពុជាក្តី អ្នកឯងត្រូវចូល ត្រូវផ្លាស់មកចូលក្នុងបក្សកុម្មុយនីស្តឥណ្ឌូចិន។ ខ្ញុំបាទខ្ញុំក៏យល់ព្រមតាមគោលការណ៍នេះ ព្រោះគោលការណ៍បក្សអ្នកឯងទៅកន្លែងណាត្រូវទៅធ្វើសកម្មភាពនៅក្រោមការដឹកនាំរបស់បក្សនោះ។ នេះខ្ញុំសូមឆ្លើយប៉ុណ្ណឹង។

[១៣:៥២:០៧]

**ស៖** សូមអរគុណ។ នៅពេលនោះ ដូចដែលលោកបានប្រាប់កាលពីព្រឹកមិញបក្សកុម្មុយនីស្តឥណ្ឌូចិន ជាការពិតត្រូវបានរៀបចំបង្កើតឡើង និងគ្រប់គ្រងដោយវៀតណាម។ តើត្រឹមត្រូវដែរឬទេ?

**ឆ៖** ត្រឹមត្រូវ។ បក្សកុម្មុយនីស្តឥណ្ឌូចិន កកើតឡើងដោយបក្ស ដោយវៀតណាមជាអ្នកចាត់តាំងបញ្ហា ហើយគេពង្រីក គេផ្សាយបក្សនេះទៅលាវ និងទៅកម្ពុជាទៀត។ សូមជម្រាបលោកប្រធាន។

**ស៖** ក្រោយមកមានការប្រកាសឯករាជ្យនៅក្នុងឆ្នាំ១៩៥៣ គឺពីរឆ្នាំក្រោយពីលោកមកពីប្រទេសថៃ ហើយមានសន្និសីទទីក្រុងហ្សឺណែវ ឆ្នាំ១៩៥៤ នៅពេលនោះដែលគេទទួលស្គាល់ឯករាជ្យភាពរបស់ប្រទេសកម្ពុជា។ ថាតើនៅពេលនោះបក្សប្រជាជនបក្សបដិវត្តន៍កម្ពុជាហ្នឹងបានបង្កើតឡើងនៅពេលនោះ ឬក៏យ៉ាងម៉េច?

[១៣:៥៣:៤២]

**ឆ៖** តាមខ្ញុំចាំបក្សកុម្មុយនីស្តឥណ្ឌូចិនកើតមកយូរហើយ មិនមែនកើតក្នុងពេលនោះទេ ពីព្រោះបក្សកុម្មុយនីស្តឥណ្ឌូចិន វៀតណាមជាអ្នកបង្កើត។ តាមខ្ញុំចាំតាំងពីឆ្នាំ១៩៣០ មកម្ល៉េះ។

**ស៖** មានបក្សកុម្មុយនីស្តថ្មីមួយបានបង្កើតឡើងនៅក្នុងឆ្នាំ១៩៥១ គឺបក្សបដិវត្តន៍ប្រជាជនកម្ពុជា តើបក្សនោះបង្កើតនៅក្នុងឆ្នាំនោះមែនដែរឬទេ?

**ឆ៖** គោរពលោកប្រធាន! ខ្ញុំសូមជម្រាបថាការដែលមានបក្ស វៀតណាមគេមានទស្សនៈឃើញថា បើប្រើបក្សកុម្មុយនីស្តឥណ្ឌូចិនរួមអ៊ីចឹង ប្រជាជនខ្មែរ ជាពិសេសប្រជាជនខ្មែរ មិនទទួលហើយមិន

ចូលចិត្តវៀតណាមទៀត។ ដូច្នោះ វៀតណាមគេមានយុទ្ធវិធីចែកបក្សកុម្មុយនីស្តឥណ្ឌូចិនជាបីបក្ស។ អានេះជាយុទ្ធវិធីទេ មិនមែនជាបញ្ហាគោលការណ៍អីទេ ក៏ប៉ុន្តែបក្ស នោះបីចែកបក្សកុម្មុយនីស្តឥណ្ឌូចិនជាបីអីចឹងហើយក៏ដោយ។ ទីមួយនៅ លាវ ហៅថាបក្សប្រជាជនបដិវត្តន៍ឡាវ។ នៅកម្ពុជាគេឲ្យឈ្មោះហៅថា "បក្សកុម្មុយនីស្ត-- បក្សប្រជាជនបដិវត្តន៍កម្ពុជា"។ ឯនៅវៀតណាមគេហៅថា "បក្សពលករបក្សឡៅដុង"។ ប៉ុន្តែទោះបី ដូចខ្ញុំបានជម្រាបហើយ ចែកជាបីបក្សយ៉ាងនេះក៏ដោយ ក៏ប៉ុន្តែបក្សលាវក្តី បក្សខ្មែរក្តី មិនឯករាជ្យ មិនមានអធិបតេយ្យភាព មិនមានគំនិតផ្តើមអីខ្លួនឯងទេ គឺនៅក្រោមការដឹកនាំបញ្ជារបស់បក្សឡៅដុង គឺបក្សពលករវៀតណាមនេះឯង។ នេះខ្ញុំសូមជម្រាប។

**ស៖** សូមអរគុណ។លោកបានជម្រាបអង្គសវនាការថាបក្សប្រជាជនបដិវត្តន៍កម្ពុជា គឺត្រូវបានគ្រប់គ្រងដោយវៀតណាម។ ក្រោយពេលឯករាជ្យ និងសន្និសីទទីក្រុងហ្សឺណែវ ថាតើបញ្ញវន្តដែលជាសមាជិករបស់ចលនាកុម្មុយនីស្ត ជាពិសេសនៅប្រទេសបារាំងនោះ តើពួកគាត់ហ្នឹងវិលត្រឡប់មកប្រទេសកម្ពុជាវិញដែរឬទេ ក្រោយពីសន្និសីទទីក្រុងហ្សឺណែវនោះ?

[១៣:៥៨:៤៧]

**ឆ៖** បញ្ហានេះ ខ្ញុំក្តាប់មិនបានទេ ពីព្រោះខ្ញុំមិនបានទាក់ទងខាងផ្នែកបញ្ញាជននោះទេ។ ខ្ញុំមិនដែលស្គាល់ទេខ្មែរដែលទៅរៀនស្រុកបារាំងនោះ។ ដូច្នោះគេចូលបក្សបារាំង ឬមិនចូលបក្សអីនោះ ខ្ញុំមិនបានដឹងទេ។ សូមជម្រាបប៉ុណ្ណឹង។

**ស៖** ក្រោយមកនៅក្នុងឆ្នាំ១៩៦០ តើមានបក្សកុម្មុយនីស្តថ្មីមួយបង្កើតឡើងដែរឬទេ ដែលគេហៅថាបក្សពលករខ្មែរនោះ ហើយថាតើបក្សពលករខ្មែរនោះគឺជាបក្សកុម្មុយនីស្តមួយសុទ្ធសាធ ឬក៏មិនមែនទេ?

**ឆ៖** ដូចជាខ្ញុំជម្រាបអីចឹង គឺថាខ្មែរនេះ ក្នុងឆ្នាំ១៩៦០ ខ្ញុំសូមជម្រាបអីចេះ ចង់រំដោះខ្លួនឲ្យផុតពីការត្រួតត្រាដឹកនាំរបស់វៀតណាម។ ដូច្នោះបក្ខជនមួយចំនួនក្នុងនោះមានលោកតា ទូ សាមុត មួយដែរ មាន សាឡុត ស មួយ ហើយនិងខ្ញុំមួយដែរ គិតគ្នាថា "បើកាលណាយើងមិនមានបក្សមួយដែលមានមាគ៌ានយោបាយ យុទ្ធសាស្ត្រ យុទ្ធវិធីឯករាជ្យ ដោយឡែកពីបក្សវៀតណាមទេ ប្រទេសយើង បក្សយើងនៅតែរណបវៀតណាមដដែល នៅតែទទួលការដឹកនាំបញ្ជាពីវៀតណាមដដែល។ ដូច្នោះ ត្រូវតែរៀបចំបក្សនេះឲ្យមានមាគ៌ា យុទ្ធសាស្ត្រ យុទ្ធវិធី និងលក្ខន្តិកៈរបស់បក្សខ្លួនដោយឡែកពីបក្សវៀតណាមឲ្យដាច់ស្រឡះពីគ្នា"។ សូមជម្រាបប៉ុណ្ណឹង។

**ស៖** ថាតើវៀតណាម គេដឹងអំពីការបង្កើតបក្សពលករខ្មែរដែរឬទេ? ហើយប្រសិនបើវៀតណាមបានដឹងថាមានបក្សពលករខ្មែរបង្កើតឡើងនោះ តើវៀតណាមមានគាំទ្របក្សនេះដែរឬទេ?

**ឆ៖** តាមខ្ញុំដឹង វៀតណាមគេដឹងដែរ មិនមែនតែគេមិនគាំទ្រទេ គេថែមទាំងបំផ្លាញបក្សនេះទៀតផង បក្សខ្មែរទៀតផង ដោយវិធីណាគឺ៖

ទី១) បំបែកបំបាក់ផ្ទៃក្នុងបក្ស ដែលហៅថាកាលណោះហៅថា “បក្សពលករកម្ពុជា” គេចាត់តាំងឲ្យបក្ខជន-- ឲ្យមានបក្ខជនសម្ងាត់ ដើម្បីស៊ើបការណ៍ បំផ្លាញមាគ៌ានយោបាយរបស់បក្ស។ ជាពិសេស វៀតណាមខ្លួនឯង គេមិនសប្បាយចិត្តទេ ពីព្រោះក្នុងការចាត់តាំង ធ្វើមាគ៌ានយោបាយ យុទ្ធសាស្ត្រក្តី មាគ៌ាយុទ្ធវិធីក្តី បក្សខ្មែរ បក្សយើងមិនបានពិគ្រោះ ពិភាក្សាជាមួយ ឬសុំសេចក្តីយល់ព្រមពីបក្សវៀតណាមទាល់តែសោះ។ ដូច្នោះ គេមានការមិនសប្បាយចិត្តបានជាគេមានវិធានការបំផ្លាញទាំងខាងក្នុងបក្ស ទាំងក្រៅបក្ស ទាំងលើឆាកអន្តរជាតិ។

[១៤:០៥:០១]

ជាក់ស្តែងដោយខ្ញុំចង់និយាយគឺ គេចង់ក្តាប់ក្តោបបក្សខ្មែររហូត។ ទ្រឿង ជីង កាលណោះធ្វើជាអគ្គលេខាបក្សពលករវៀតណាម ឬក៏ហៅថា “បក្សឡៅដុងវៀតណាម” ឬ “បក្សកុម្មុយនីស្តវៀតណាម” ចុះ គាត់និយាយថា វៀតណាម កម្ពុជា លាវ ប្រៀបដូចជាផ្ទះមានបន្ទប់បី តែមានដំបូលផ្ទះតែមួយទេ មានមេដំបូល (អត់ទោស) តែមានមេដំបូលតែមួយទេ។ បានសេចក្តីថា ទោះបីអ្នកឯងមានបីបក្សហើយក៏ដោយ ក៏ប៉ុន្តែក៏នៅក្រោមការត្រួតត្រារបស់វៀតណាមដែរ ពីព្រោះមានមេដំបូលតែមួយនេះ ទ្រឿង ជីង និយាយហើយនិយាយទៀតៗ។ ឯក្រៅពីនេះកម្មាភិបាលវៀតណាមខ្លះ ជាច្រើន ជាពិសេស កម្មាភិបាលដឹកនាំសំខាន់ៗរបស់វៀតណាម គេច្រើននិយាយថា “ទោះបីវៀតណាមរំដោះវៀតណាមខាងត្បូងបានហើយក៏ដោយ តែបើមិនបានកម្ពុជាទេ វាឥតប្រយោជន៍ទេ យើងខាតទុនធំណាស់ បើសិនណាយើងក្តាប់ក្តោបកម្ពុជាមិនបាន”។ នេះខ្ញុំសូមជម្រាប។ នេះគ្រាន់តែ គេសប្បាយចិត្តឬមិនសប្បាយចិត្ត ប៉ុន្តែសម្តីគេនិយាយមកអ៊ីចឹងដែរ។ ឯខាង តាមខ្ញុំចាំអ្នា ផាំ វ៉ាន់ដុង និយាយថាយ៉ាងម៉េច? ផាំ វ៉ាន់ដុង គាត់និយាយថា អ្នា ទេ!-- ផាំ វ៉ាន់ដុង គាត់និយាយថា ពេលដែលយើងរំដោះហ្នឹងពេលដែលខ្មែរកម្ពុជារំដោះហ្នឹង គាត់ថា *“សែត្រែ មីស្ទ័ររីយើ”* (ភាសាបារាំង)។ គាត់អត់និយាយសរសើរពីបក្ស អត់និយាយសរសើរពីប្រជាជនកម្ពុជាទេ។ គាត់និយាយថា វាអស្ចារ្យណាស់។ បានសេចក្តីថា កាលកម្ពុជារំដោះនេះ ដូចជាទេវតាមកជួយអ៊ីចឹង មិនមែនប្រជាជនខ្មែរ មិនមែនបក្ស

ខ្មែរដឹកនាំ។

[១៤:០៧:២២]

ឯ វ៉ី ង្វៀនយ៉ាប គាត់និយាយថាម៉េច? ដូចជាខ្ញុំបានដូចធ្លាប់និយាយហើយ គាត់សួរ ប៉ុល ពត ថា តើកម្ពុជាមានដីប៉ុន្មាន? ដីបង្កបង្កើនផលប៉ុន្មានហិកតា? ប៉ុល ពត ឆ្លើយថា កាលនោះ សាមសិបឆ្នាំកន្លងមកហើយណ៎ា មានប៉ែតសិបលានហិកតាៗ។ ប៉ុន្តែដីដែលល្អណ៎ា ដែលបង្កើនផលបានល្អប្រហែលជា ៣០លាន។ ដល់ថាអ៊ីចឹង វ៉ី ង្វៀនយ៉ាប ថា "ង៉នក្វា" និយាយជាភាសាវៀតណាម បានន័យថា "ឆ្ងាញ់ណាស់"។ ខ្ញុំនឹកក្នុងចិត្ត ឆ្ងាញ់យ៉ាងម៉េចហ្នឹងហ៎? ដល់ឥឡូវឆ្ងាញ់មែន ឥឡូវឆ្ងាញ់មែន ៩០ កុងត្រាឱ្យគេ៩៩ឆ្នាំ ឆ្ងាញ់មែនឥឡូវហើយណ៎ា ហើយសុទ្ធតែដីនៅជាយដែនទៀត។

[១៤:០៨:៤៨]

នេះខ្ញុំសូមនិយាយការជាក់ស្តែងពិត ពីព្រោះតុលាការនេះត្រូវការពិត ត្រូវការយុត្តិធម៌ ត្រូវការមានប្រយោជន៍។ ការដែលមានប្រយោជន៍សម្រាប់យុវជនជំនាន់ក្រោយ ចាំឱ្យច្បាស់! "ពីណាមិត្ត ពីណាសត្រូវ"។ តាំងពីពេលនោះមក អ្នកដឹកនាំជាច្រើន គេមិនចង់ឱ្យយើងរំដោះភ្នំពេញទេ គេនិយាយថា "ពួកមិត្តមិនបាច់រំដោះភ្នំពេញទេ ចាំកាលណាខ្ញុំរំដោះព្រៃនគរហើយ ខ្ញុំទៅវាយភ្នំពេញតែម្ភៃបួនម៉ោងទេ។ ពួកមិត្តចាំរកតែអ្នកនាំផ្លូវទៅបានហើយ មិនបាច់ទៅវាយទេ"។ ពាក្យនេះ គេផ្សាយទូទៅ ក្នុងប្រជាជនខ្មែរ ក្នុងកងទ័ពខ្មែរ។ ប៉ុល ពត អប់រំថា "អ្នកណាគេធ្វើ អ្នកណាគេចាត់ចែង អ្នកនោះគេយកផលប្រយោជន៍" បានសេចក្តីថា បើគេវ៉ៃយកភ្នំពេញហើយនោះ មុខតែគេយកភ្នំពេញហើយកុំទៅជឿ។ នេះខ្ញុំសូមជម្រាបថាការ កិច្ចការអស់នេះបង្ហាញឱ្យឃើញនូវធាតុពិតល្លានពាន វាតទី លេបទឹកដី បំបាត់ពូជសាសន៍របស់អ្នកដឹកនាំវៀតណាម។ សូមលោកប្រធានជ្រាប។

**ស៖** ក្រោយមកមានបក្សមួយទៀត ដែលត្រូវបានបង្កើតឡើងហៅថា "កុម្មុយនីស្តកម្ពុជា" ហើយនោះគឺជាឈ្មោះថ្មីជំនួសឱ្យបក្សពលករខ្មែរ ដែលលោកទើបជម្រាបយើងថា ត្រូវបានបង្កើតឡើងដោយវៀតណាម តើវាជាការត្រឹមត្រូវដែរឬទេ?

[១៤:១១:៣៣]

**ឆ៖** ហេតុផលដែលប្រែមកពីមកពីបក្សពីឈ្មោះ "បក្សពលករកម្ពុជា" មក "បក្សកុម្មុយនីស្តកម្ពុជា"។ ខទីមួយ ពីព្រោះបក្សបើដាក់ "បក្សពលករកម្ពុជា" វាទៅត្រួត វាទៅជាន់លើ "បក្សពលករវៀតណាម" ដូច្នោះវាមិនសមរម្យ។ ដូច្នោះបានជាគណៈដឹកនាំបក្សកម្ពុជានេះ ប្រែឈ្មោះ "បក្សពលករ

កម្ពុជា” ទៅជា “បក្សកុម្មុយនីស្តកម្ពុជា” ក៏ប៉ុន្តែខ្ញុំសូមជម្រាបឲ្យច្បាស់ថា មិនមែនយកលទ្ធិកុម្មុយនីស្តនោះមកដាក់នៅប្រទេសខ្មែរឲ្យសម្រេចបានភ្លាមៗនោះទេ មិនមែនងាយទេ ពីព្រោះពេលនោះនៅក្រោមការត្រួតត្រា ពីព្រោះពេលនោះសង្គមកម្ពុជា មិនមែនទាន់ជាសង្គម សង្គមនិយមអីទេ។ ដូច្នោះឈានទៅកុម្មុនីស្តម៉្យាងម៉េចកើត។ ក៏ប៉ុន្តែដាក់ឈ្មោះបក្សកុម្មុយនីស្តនេះ ដើម្បីកុំឲ្យវាត្រួតទៅលើបក្ស ឬក៏យើងយកតាមឈ្មោះបក្សពលករវៀតណាម។ កុំឲ្យវាត្រូវគ្នា ឲ្យផ្សេងគ្នាទៅ ពីព្រោះហេតុដូចយ៉ាងម៉េចបានអ៊ីចឹង? កុំឲ្យវៀតណាមក៏បក្សពលករវៀតណាម ខ្មែរក៏បក្សពលករខ្មែរ។ ដូច្នោះវាដូចតែគ្នា អ្នកណាគេស្តាប់មកថាអូ! វាតែបក្សវៀតណាមតែដូចតែគ្នាហ្នឹង។ ដូច្នោះហើយ ដោយហេតុផលយ៉ាងនេះ បានជាសម្រេចថា យើងប្រែឈ្មោះទៅ។ ក៏ប៉ុន្តែគ្រាន់តែប្រែតែឈ្មោះទេ ក៏ប៉ុន្តែមាគ៌ានយោបាយ មាគ៌ាយុទ្ធសាស្ត្រ មាគ៌ាយុទ្ធវិធីរបស់កម្ពុជានៅតែជាបដិវត្តន៍ប្រជាជាតិ ប្រជាធិបតេយ្យដដែល។ មិនប្រែទេ ប្រែតែឈ្មោះទេ ប្រែឈ្មោះនេះគឺប្រែជារូបភាពទេ។ ខ្ញុំសូមជម្រាប។

[១៤:១៤:២៨]

**ស៖** ហើយដោយសារតែបក្សកុម្មុយនីស្តកម្ពុជា និងថ្នាក់ដឹកនាំបានសម្រេច ដើម្បីបង្ហាញទុកពិភពលោកថា គឺជាបក្សមួយ ជាចលនាឯករាជ្យមួយ ចេញពីប្រទេសវៀតណាម។ តើបក្សកុម្មុយនីស្តកម្ពុជា ដែលពេលខ្លះនិយាយថា ជាចលនាកុម្មុយនីស្តដែលទើបតែចាប់ផ្តើមនៅក្នុងឆ្នាំ១៩៦០ នៅពេលដែលបក្សពលករកម្ពុជាត្រូវបានបង្កើតឡើងនោះ?

**ឆ៖** អត់ទោសសូម ខ្ញុំសូមស្តាប់សំណួរមិនទាន់យល់ទេ។

**ស៖** សូមអធ្យាស្រ័យដោយសារតែខ្ញុំសួរវែងបន្តិច។ ក្រោយមកបក្សកុម្មុយនីស្តកម្ពុជា បាននិយាយថា ចលនាកុម្មុយនីស្តនៅក្នុងប្រទេសកម្ពុជាបានចាប់ផ្តើមឡើងនៅក្នុងឆ្នាំ១៩៦០ ថាតើនេះគឺជាគោលបំណងដើម្បីបង្ហាញឲ្យឃើញ នូវចលនាកុម្មុយនីស្តឯករាជ្យនៅក្នុងប្រទេសកម្ពុជា ឬយ៉ាងម៉េច? ដើម្បីបង្ហាញឲ្យឃើញថាមិនចង់ឲ្យមានការពាក់ព័ន្ធជាមួយនឹងចលនាកុម្មុយនីស្តរបស់វៀតណាម ដែលចាប់ផ្តើម ដោយមានបក្សកុម្មុយនីស្តវៀតណាមនៅដើមដំបូងនោះ។

**ឆ៖** ត្រូវហើយ។

[១៤:១៥:២៥]

**ស៖** សូមអធ្យាស្រ័យ ពាក់ព័ន្ធទៅនឹងការចូលរួមក្នុងចលនាកុម្មុយនីស្តរបស់លោក នៅពេលលោកត្រឡប់មកពីប្រទេសថៃវិញ លោកត្រូវបានទទួលបានការបណ្តុះបណ្តាល ពីសំណាក់វៀតណាម

ពេញមួយអំឡុងពេលនោះ តើជាការត្រឹមត្រូវដែរឬទេ?

**ឆ៖** តាមខ្ញុំគិត មិនមែនតែខ្ញុំម្នាក់ឯងទេ ដែលវៀតណាមខំអូសទាញ ខំអប់រំយកខ្មែរនេះ ដើម្បីធ្វើជាកម្លាំង។ គឺថាគេប្រមូលយកជនជាតិខ្មែរណាទាំងអស់ ដែលមិនទាន់យល់ មិនទាន់ឃើញពីអត្ត-ចរិតឈ្លានពាន វាតទី លេបទឹកដី បំបាត់ពូជសាសន៍របស់វៀតណាមច្បាស់ គេប្រមូលយកទាំងអស់ គេទាញយកទាំងអស់ ដើម្បីជាកម្លាំងរបស់គេ ហើយដើម្បីគេត្រួតត្រាតាមកម្ពុជាតទៅទៀត។ នេះជាការពិតណាស់ ការពិត។

[១៤:១៧:៥៨]

**ស៖** នៅពេលដែលបក្សកុម្មុយនីស្តកម្ពុជាត្រូវបានបង្កើតឡើងក្នុងឆ្នាំ១៩៦០ លោកគឺជាមនុស្សម្នាក់នៅក្នុងប្រទេសកម្ពុជា ដែលបានសិក្សាទ្រឹស្តីកុម្មុយនីស្ត លទ្ធិកុម្មុយនីស្ត ហើយលោកគឺជាមេដឹកនាំម្នាក់របស់បក្សនោះ គឺជាការត្រឹមត្រូវដែរឬទេ?

**ឆ៖** ខ្ញុំសូមជម្រាប គោលការណ៍ដឹកនាំរបស់បក្សកុម្មុយនីស្តកម្ពុជា មិនមែនឯកជនដឹកនាំទេ គឺសមូហភាពដឹកនាំ ដឹកនាំរួម បុគ្គលទទួលខុសត្រូវដោយឡែក។ ដូច្នោះ គ្មាន-- ត្រង់ណេះ ខ្ញុំសូមនិយាយបន្ថែមបន្តិចចុះ។ ប៉ុន្តែវាមានអ៊ីចេះ ពួកខ្មែរដែលវៀតណាមប្រមូលយកទៅភាគខាងជើង ក្រោយកិច្ចព្រមព្រៀងហ្សឺណែវ ឆ្នាំ១៩៥៤ ទៅយកវប្បធម៌វៀតណាម ហៅថាបងធំ បងតូច នៅក្នុងបក្ស។ នៅក្នុងបក្សយើងខ្ញុំគ្មានបុគ្គលណាម្នាក់ជាអ្នកធំ ជាអ្នកតូចទេ ស្មើគ្នាទាំងអស់ ខុសគ្នាតែភារកិច្ច។ បញ្ហានេះ ខ្ញុំសូមជ្រាបឲ្យច្បាស់ថា ប៉ុល ពត មានគេស្នើឲ្យហៅថា អគ្គលេខាធិកាបក្សកុម្មុយនីស្តកម្ពុជា។ ប៉ុល ពត មិនទទួលទេ គាត់ថា "ខ្ញុំមិនសុំនឹងទទួលយកឋានៈជាអគ្គលេខាទេ។ យកត្រឹមលេខាបានហើយ ពីព្រោះបក្សយើងវាតូច។ បក្សយើងវាប្រជាជនតិច ហើយយើងនៅមិនទាន់មានពិសោធក្នុងការតស៊ូប៉ុន្មានទេ។ ដូច្នោះ យើងកុំតម្លើងខ្លួនយើងខ្លាំងពេក យើងត្រូវសុភាពរាបសារ"។ នេះខ្ញុំសូមជម្រាបឲ្យច្បាស់អំពីពាក្យថា បងធំបងតូចនៅក្នុងនេះ ឬក៏ដូចជាលោកនេះសួរខ្ញុំអំមិញអ៊ីចឹង។

[១៤:២១:០៩]

**ស៖** លោកត្រូវបានបោះឆ្នោតជាអនុលេខាបក្សរបស់បក្សប្រជាជនបដិវត្តន៍កម្ពុជានៅក្នុងឆ្នាំ ១៩៦០ ហើយបន្ទាប់មកឈ្មោះនេះក៏បានផ្លាស់ប្តូរទៅជា "បក្សពលករកម្ពុជា" ហើយលោកនៅតែទទួលឋានៈជាអនុប្រធានរបស់បក្សនេះដដែល។ តើនេះជាការត្រឹមត្រូវដែរឬទេ?

**ឆ៖** ខ្ញុំមិនមែនអនុប្រធានទេ អនុលេខា។ អនុប្រធានវាផ្សេង អនុប្រធាន គឺខាងរដ្ឋបាល។ អនុលេខាវាខាងបក្ស។ នេះសូមជម្រាបសម្រួលពាក្យពេចន៍ឲ្យបានត្រឹមត្រូវកុំឲ្យមានការភ័ន្តច្រឡំ ព្រោះបើមិនអ៊ីចឹងវាច្របូកច្របល់រវាងបក្ស រវាងអំណាចនីតិបញ្ញត្តិ នីតិប្រតិបត្តិ អំណាចតុលាការ។ ដូច្នោះមិនមែនដូចជាថាអំមិញនោះទេ។

**ស៖** សូមបញ្ជាក់បន្តិចថា សុំប្រើពាក្យអនុលេខាបក្ស។ ខ្ញុំចង់ឲ្យលោកបញ្ជាក់ថា លោក គឺជាអនុលេខាបក្សនៃបក្សកុម្មុយនីស្តកម្ពុជាក្នុងឆ្នាំ១៩៦០ ហើយក្រោយមកក៏ដោយជាបក្សពលករកម្ពុជា គឺថាលោកនៅតែជាអនុលេខាបក្សនៃបក្សនេះដដែល។ តើត្រឹមត្រូវដែរឬទេលោក?

**ឆ៖** កាលណោះមានបញ្ហាយ៉ាងនេះ ខ្ញុំ អានេះខ្ញុំសូមនិយាយឲ្យនេះបន្តិច ឲ្យវាល្អិតបន្តិចដើម្បីជម្រាប។ ខ្ញុំជាអនុលេខាបក្សកុម្មុយនីស្ត ឬក៏ហៅពាក្យមុនហៅថា “បក្សពលករ” ប៉ុន្តែក្រោយមកនេះវាមានរឿងផ្ទៃក្នុងបក្ស គឺក្នុងឆ្នាំ១៩៥៤, ៥៥, ៥៦ អីៗអស់នេះ ក្រោយពីកិច្ចព្រមព្រៀងហ្សឺណែវ ស៊ីវ ហេង ត្រូវជាមាថ្លៃរបស់ខ្ញុំ គាត់ថា ក្បត់បក្សចុះ លាចេញ ចាកចេញពីបក្សទៅចូលបម្រើពួក លន់ នល់ ដល់អ៊ីចឹងអ្ហែ! ខ្ញុំសូមជម្រាបថា វាប៉ះពាល់ដល់ឥទ្ធិពលរបស់ខ្ញុំដែរ។ ព្រោះកាលណោះ វាមានពីរ ខ្ញុំសូមជម្រាបឲ្យលោកយល់។ មួយបក្សសម្ងាត់ ពីរបក្សចំហ។ បក្សចំហ គឺបក្ស-- គឺក្រុម មិនមែនហៅថាបក្សទេ ហៅថាក្រុម ក្រុមប្រជាជនៗនេះមានភារកិច្ចចេញមុខចំហដើម្បីធ្វើកាសែត ដើម្បីឃោសនាអប់រំប្រជាជន។ នេះចំហ។ មិនទាក់ទងអ្វីនឹងបក្សសម្ងាត់ទេ។ កាលណោះវាមានបក្សសម្ងាត់ មានបក្សចំហ ខ្ញុំសូមជម្រាបឲ្យច្បាស់យ៉ាងនេះ។

**ស៖** ហើយនៅពេលដែលលោកជាអនុលេខាបក្សពលករកម្ពុជា ថាតើលោក ទូ សាមុត នៅពេលនោះជាលេខាបក្ស ឬក៏យ៉ាងម៉េច?

**ឆ៖** ខ្ញុំសួរបញ្ជាក់ទៅវិញ ឆ្នាំណា? លោកចង់សួរខ្ញុំ ឆ្នាំណា?

**ស៖** ខ្ញុំចង់សួរថា នៅពេលដែលមុនគាត់បាត់ខ្លួន គឺដែលជាចលនាបក្សកុម្មុយនីស្តកម្ពុជា គឺនៅមុនពេលគាត់បាត់ខ្លួននោះ តើត្រឹមត្រូវទេ?

**ឆ៖** គាត់បានខ្លួនក្នុងឆ្នាំ១៩៦២។ ប៉ុន្តែមុននឹងនេះ ស៊ីវ ហេង ទេ ដែលយួនចាត់តាំងឲ្យធ្វើលេខាបក្ស។ ឯលោកតា ទូ សាមុត ពេលនោះ គាត់មកភ្នំពេញ គាត់ទទួលជាអនុលេខា-- មិនមែនអនុលេខាទេ គាត់ទទួលជាសមាជិកម្នាក់ក្នុងបក្ស ឯ ស៊ីវ ហេង ទេ ជាលេខាបក្ស។ ឯខ្ញុំ ហើយនិង សាឡុត ស ជាអ្នកជំនួយការលោកតា ទូ សាមុត ព្រោះមានតែគាត់ម្នាក់ឯង។ ដល់ក្រោយមក ពេលដែល ស៊ីវ ហេង

វត់ចោលជួរទៅ បានធ្វើមហាសន្និបាតបក្សលើកទីមួយឆ្នាំ១៩៦០ ហើយបានជាចាត់តាំងលោកតា ទូ សាមុត នេះ ជាលេខាបក្សទៅវិញ ឯខ្ញុំនៅតែអនុលេខាបក្សដដែល។ ឯក្រៅពីនេះ មានគណៈអចិន្ត្រៃយ៍អីផ្សេងៗតទៅទៀត ដូចជា ប៉ុល ពត, អៀង សារី អី។

[១៤:២៧:៥៤]

**ស៖** នៅពេលនោះ លោកមានការទទួលខុសត្រូវទៅលើមន្ទីរមួយ គឺមន្ទីររបស់បក្សពលករកម្ពុជា ដែលនៅពេលនោះ សាឡុត ស ឈ្មោះបដិវត្តន៍ហៅថា ប៉ុល ពត ឬក៏ អៀង សារី នេះ តើនេះជាការត្រឹមត្រូវដែរឬទេ?

**ឆ៖** ខ្ញុំសូមជម្រាបបញ្ជាក់ ថាខ្ញុំទទួល-- ខ្ញុំទទួលអនុ ហើយខ្ញុំទទួលខាងអប់រំប៉ុណ្ណឹងទេ ទទួលខាងការងារអប់រំ ខ្ញុំមិនបានទទួលទៅធ្វើជាប្រធានមន្ទីរអីឯណាទៀតទេ អត់មានទេ។

**ស៖** នៅពេលណាដែល សាឡុត ស ក្លាយទៅជាលេខាបក្សពលករកម្ពុជា?

**ឆ៖** ខ្ញុំចង់សួរថា បក្សកុម្មុយនីស្ត ឬបក្សពលករ?

**ស៖** គឺបក្សពលករកម្ពុជា។ នៅក្នុងកថាខណ្ឌ២២ នៃដីកាបញ្ជូនរឿងទៅជំនុំជម្រះ គឺថា ក្រោយពេល ទូ សាមុត បាត់ខ្លួនទៅ សាឡុត ស ក៏ក្លាយខ្លួនទៅជាលេខាបក្សពលករកម្ពុជា ឯលោកវិញនៅតែជាអនុលេខបក្សដដែល។ តើនេះត្រឹមត្រូវដែរឬទេ?

**ឆ៖** ក្រោយពីបាត់ខ្លួនលោកតា ទូ សាមុត ឆ្នាំ១៩៦២ទៅ បានមានធ្វើមហាសន្និបាតមួយរបស់បក្សក្នុងឆ្នាំ១៩៦៣ ហើយបានជ្រើសរើស ប៉ុល ពត ឬ សាឡុត ស នេះ ជាលេខាបក្ស។ ខ្ញុំនៅជាអនុលេខាបក្សដដែល។ ខ្ញុំសូមលាឈប់ហើយ ក៏ប៉ុន្តែទីប្រជុំមិនអនុម័តឲ្យខ្ញុំឈប់ធ្វើអនុលេខាទេ។ ខ្ញុំសូមធ្វើបក្ខជនធម្មតាទៅចុះ ព្រោះកុំឲ្យជំពាក់ជំពិនអីជាមួយ ស៊ីវ ហេង ដែលត្រូវជាក្រុមគ្រួសាររបស់ខ្ញុំនោះ។ មានប៉ុណ្ណឹង។

**ស៖** ហើយមូលហេតុដែលលោកចង់បង្ហាញឲ្យ-- កុំឲ្យមានការសង្ស័យ ការជាប់ទាក់ទងទៅនឹងលោក ស៊ីវ ហេង ដែលជាឪពុកមាថ្លៃរបស់លោក ដោយសារតែគាត់បានបោះបង់ចោលចលនាកុម្មុយនីស្ត ហើយគាត់បានចូលរួមជាមួយនឹងចលនារបស់ សីហនុ។ តើនេះជាការត្រឹមត្រូវដែរឬទេ?

[១៤:៣១:៥៣]

**ឆ៖** តាមខ្ញុំចាំ បញ្ហាវាមានច្រើន មូលហេតុដែលគាត់បោះបង់ចោលបក្សកុម្មុយនីស្តពេលនោះ គឺមួយ ដោយសារជីវភាពក្រុមគ្រួសារគាត់វាលំបាក។ កូនចៅរៀនសូត្រច្រើនគ្មានលុយគ្មានកាក់ ហើយ

បក្សមិនមានលទ្ធភាពអ្វីឧបត្ថម្ភ នេះខទីមួយ។ ខទីពីរ គាត់បែកការសម្ងាត់ ពីព្រោះទាក់ទងជាមួយក្រុមគ្រួសារខាងប្រពន្ធ ដូច្នោះគិញតាមគាត់ជាប់ នេះជាខទីពីរ។ ដូច្នោះដើម្បីឲ្យរួចខ្លួន ស៊ីវ ហេង នេះមិនមែនទៅចូលសារភាពសម្តេចទេ គឺទៅតាម-- តាមខ្ញុំដឹងទៅទាក់ទងសារភាពជាមួយលោក លន់ នល់។ ដូច្នោះ គាត់បានទទួលការការពារពី លន់ នល់។ សូមជ្រាប។

**ស៖** នៅពេលដែល ទូ សាមុត នៅជាលេខាបក្សពលករកម្ពុជា គាត់បានបាត់ខ្លួន ហើយនៅក្នុងចម្លើយរបស់លោក នៅក្នុងថ្ងៃទី២២ ខែវិច្ឆិកា នេះថាតើលោកបានដឹងការបាត់ខ្លួន ឬក៏ការស្លាប់របស់គាត់ទេ?

[១៤:៣៣:៥៨]

**ឆ៖** ឲ្យខ្ញុំដឹងផ្ទាល់ខ្លួនខ្ញុំមិនដឹងទេ ប៉ុន្តែខ្ញុំឮ ពីព្រោះពេលដែលលោកតា ទូ សាមុត បាត់ខ្លួនពេលនោះខ្ញុំមិនទាន់ដឹងទេ។ ក៏ប៉ុន្តែថ្ងៃរសៀល ថ្ងៃមួយខ្ញុំបានយកឯកសារទៅជូនផ្ទះគាត់-- ទៅជូនគាត់នៅផ្ទះដល់ទៅ ខ្ញុំសួរប្រពន្ធគាត់ កាលណោះគាត់មានកូនមួយហើយ ប្រហែលជាអាយុបីឆ្នាំ ឬពីរឆ្នាំជាង។ ខ្ញុំសួរតាថា តើលោកតាអញ្ជើញទៅណា? ថាគាត់ទៅផ្សារតាំងពីព្រឹកម្ល៉េះ។ ខ្ញុំសួរគាត់ទៀតថា ទៅផ្សារណា? ទៅផ្សារទួលទំពូង។ ទួលទំពូងហ្នឹងនៅជិតហ្នឹង ពីព្រោះកាលណោះគាត់ផ្លាស់ទៅនៅហ្នឹង។ ខ្ញុំនឹកភ្ញាក់ក្នុងចិត្តហ្នឹង។ មួយអាចគ្រោះថ្នាក់ចរាចរណ៍ ពីរអាចត្រូវចាប់។ ដូច្នោះខ្ញុំទៅរាយការណ៍ប្រាប់សាឡុត ស ថាបាត់លោកតា។ ខ្ញុំទៅរាយការណ៍តាមដំណើររឿងដែលខ្ញុំដឹងមកពីប្រពន្ធគាត់។ សាឡុត ស គេមានខ្សែចាត់តាំងនៅខាងពេទ្យ ហើយនិងខាងយោធា។ ដូច្នោះ សាឡុត ស ស៊ើបសួរតាមខ្សែចាត់តាំងនេះ សួរខាងពេទ្យថាមិនឃើញមានទេអ្នករបួស ប៉ុន្តែខាងខ្សែយោធា ខ្ញុំប្រាប់ឈ្មោះទៅចុះ គាត់ខូចទៅហើយ ឈ្មោះ នុត ប៉ាណារ៉ា គេមានខ្សែពួកម៉ាកស៊ីផឹកខាងយោធា គេប្រាប់ថាមានទាហានខាងលន់នល់ ថាម៉្ងៃណោះចាប់បានមេខ្សែតស្សូរៈធំមួយ ហើយគេយកទៅឃុំនៅផ្ទះ លន់ នល់ ធ្វើទារុណកម្មជាច្រើន។ គាត់អត់ឆ្លើយ។ រួចទៅទាហានសម្ងាត់របស់ លន់ នល់ យកលោកតា ទូ សាមុត នេះទៅសម្លាប់ទៅវត្តតាព្រហ្មមានជ័យ ឬហៅថាវត្តស្ទឹងមានជ័យ។ នេះខ្ញុំសូមជម្រាបប៉ុណ្ណឹង ស្ងាត់ទៅរឿងហ្នឹង រឿហ្នឹងស្ងាត់។

[១៤:៣៧:២០]

**ប្រធានអង្គជំនុំ៖**

អរគុណលោក នួន ជា។ ឥឡូវនេះដល់ម៉ោងសមល្មមហ្នឹងសម្រាកហើយ អង្គជំនុំជម្រះប្រកាស

សម្រាកម្ភៃនាទីចាប់ពីពេលនេះតទៅ រហូតដល់ម៉ោងបី សូមអញ្ជើញចូលវិញ ដើម្បីបន្តកិច្ចដំណើរសវនាការអនុរក្សមន្ទីរឃុំឃាំងនាំគាត់ទៅកាន់កៅអីនៅពីក្រោយមេធាវីរបស់គាត់ ហើយនឹងនាំឲ្យគាត់មកកាន់ទីនេះវិញ ឲ្យបានមុនពេលអង្គជំនុំជម្រះចូលមកកាន់អាសនៈ។

**ក្រឡាបញ្ជី៖**

សូមអញ្ជើញក្រោកឈរ!

*(សវនាការសម្រាកពីម៉ោង ១៤:៣៨ នាទី ដល់ម៉ោង ១៥:០០ នាទី)*

[១៥:00:00]

**ប្រធានអង្គជំនុំ៖**

អញ្ជើញអង្គុយចុះ! អង្គជំនុំជម្រះសូមប្រកាសបន្តកិច្ចដំណើរការនីតិវិធី។

សូមអញ្ជើញលោក នួន ជា!

**លោក នួន ជា៖**

លោកប្រធាន ខ្ញុំសូមកែតម្រូវពាក្យពីរម៉ាត់មួយពាក្យថា ប៉ែតសិបលានហិចតានោះ គឺខ្ញុំសូមកែថាប្រាំបីលានវិញ មិនមែនប៉ែតសិបលានទេ អានេះ (ខ) ទីមួយណ៎ា។ (ខ) ទីពីរគឺថា វៀតណាមចូល ១៧ មករា ១៩៨០ សូមកែ ៧ មករា ១៩៧៩ វិញ។ សូមអរគុណលោកប្រធាន។

**ប្រធានអង្គជំនុំ៖**

អរគុណ។ សូមអញ្ជើញបាទ!

**លោក នួន ជា៖**

ព្រោះបេះដូងរបស់ខ្ញុំមិនសូវស្រួល សូមបន្តទៅថ្ងៃស្អែកចុះ!

**ប្រធានអង្គជំនុំ៖**

អំមិញសម្រាកម្ភៃមីនុតហើយ ឥឡូវអាចដំណើរការខ្លះទៀត។ ឥឡូវកុំប្រញាប់ពេក អាចមួយៗដើម្បីឲ្យសមនឹងកម្លាំងដែលអាចទៅរួច។

បាទ?

**លោក នួន ជា៖**

មេត្តាសុំសម្រាក។

[១៥:០១:៥២]

*(ចៅក្រមពិភាក្សាគ្នា)*

[១៥:០២:៣២]

**ប្រធានអង្គជំនុំ៖**

បាទ, ឥឡូវនេះអង្គជំនុំជម្រះនឹងបន្តនៃកិច្ចសួរចម្លើយរបស់ជាមួយ-- ចំពោះលោកនេះគឺចំណាយពេលប្រហែលជាកន្លះម៉ោងទៀត ហើយនៅថ្ងៃស្អែក អង្គជំនុំជម្រះនឹងគិតឡើងវិញអំពីរយៈពេលនៃការឈប់សម្រាកនេះ។

[១៥:០២:៥២]

សូមប្រគល់វេទិកាទៅលោកស្រីចៅក្រម ខាតវ៉ាយថ៍ ដើម្បីបន្តសំណួរសួរចំពោះជនជាប់ចោទ នួន ជា។ សូមអញ្ជើញ!

**សួរចៅក្រម ស៊ីលវៀ ខាតវ៉ាយថ៍៖**

សូមអរគុណលោកប្រធាន!

**ស៖** លោក នួន ជា ខ្ញុំសូមត្រឡប់ទៅក្រោយខ្លីបន្តិចទេ ពាក់ព័ន្ធទៅនឹងការពិភាក្សាអំពីការបាត់ខ្លួនរបស់លោក ទូ សាមុត។ លោកបានជម្រាបជូនតុលាការថា លោកបានអញ្ជើញទៅផ្ទះលោក ទូ សាមុត ហើយភ្លាមនោះលោកមានការសង្ស័យថា គាត់អាចនឹងត្រូវមានគេចាប់-- បានគេចាប់ខ្លួន។ តើលោកមានរៀបចំទៅឲ្យក្រុមគ្រួសាររបស់គាត់ភៀសខ្លួនចេញពីទីក្រុងភ្នំពេញដែរឬទេ? ដើម្បីធ្វើដំណើរទៅកាន់តំបន់លាក់ខ្លួនរបស់បក្សពលករកម្ពុជានាពេលនោះ ដើម្បីឲ្យក្រុមគ្រួសាររបស់គាត់មានសុវត្ថិភាព តើលោកមានធ្វើដូច្នេះទេ?

**លោក នួន ជា៖**

**ឆ៖** ខ្ញុំសូមជម្រាបថា ពេលនោះ ខ្ញុំមិនទាន់វិនិច្ឆ័យថា គាត់ត្រូវចាប់ ឬក៏គាត់ត្រូវ ដូចជាខ្ញុំជម្រាបអ៊ីចឹង ឬក៏ត្រូវគ្រោះថ្នាក់ចរាចរ ខ្ញុំនៅស្ទៀមសិន ខ្ញុំមិនទាន់ប៉ាននសម្រេចទេ ហើយខ្ញុំក៏មិនទាន់មានមតិអីជាមួយគ្រួសារគាត់។ ខ្ញុំរហ័សត្រឡប់មកវិញ ត្រឡប់មកផ្ទះខ្ញុំវិញ បានខ្ញុំទៅរាយការណ៍ឲ្យ សាឡុត ស ដឹងថា លោកតាបាត់ខ្លួនហើយ លោកតាបាត់។ ខ្ញុំសួរ លោកតាបាត់មិនដឹងទៅណា។ ខ្ញុំសួរប្រពន្ធគាត់ៗថាទៅផ្សារទូលទំពូងតាំងពីព្រឹកម្ល៉េះ មិនទាន់ឃើញមកវិញទេ។ ដូច្នោះ ក៏បានពិភាក្សាគ្នាបន្តិចជាមួយ សាឡុត ស ថាតើគិតដោះស្រាយយ៉ាងម៉េច? ព្រោះតាមគោលការណ៍ បើគាត់ត្រូវចាប់

ខ្លួនហ៎ ផ្ទះបក្សជនដែលគាត់ស្គាល់ត្រូវផ្លាស់ហើយ។ ប៉ុន្តែពេលនោះ សាឡុត ស ក៏មិនទាន់ប៉ាន សម្រេចថាម៉េច (ខ្ញុំហាត់បន្តិច) ថាចាំសួរមើលសិនមើល ព្រោះគាត់មានខ្សែខាងពេទ្យ ហើយមានខ្សែ ខាងយោធាដែរ ដែលគេមានមនោសញ្ចេតនាជាមួយយើង។ សួរដូច្នោះសួរខាងៗខ្សែពេទ្យ។ សួរខាង ខ្សែខាងពេទ្យឲ្យគេស្រាវជ្រាវឲ្យ។ រកមិនឃើញ ប៉ុន្មានថ្ងៃក្រោយមកទៀតបានទាក់ទងខាងខ្សែយោធា ខ្សែខាងទាហាន ដែលគេមានពួកម៉ាកជិតស្និទ្ធជាមួយ លន់ នល់។ ខាងខ្សែខាងទាហាន គេប្រាប់ថា ម៉្វៃ ណោះមានចាប់បានមេខ្មែរក្រហមម្នាក់សំខាន់ គេយកទៅទុកផ្ទះលោក លន់ នល់ គេធ្វើទារុណកម្ម។ បើអ៊ីចឹងប្រហែលហើយ ប្រហែលជាលោកតាហើយ។

[១៥:០៧:០១]

ហើយដល់ក្រោយមកទៀត គេរាយការណ៍ប្រាប់មកថា ធ្វើទារុណកម្មគាត់ច្រើន ប៉ុន្តែគាត់មិន ឆ្លើយ។ ដូច្នោះ គេយកគាត់ទៅកម្មេចសម្លាប់នៅវត្តតាព្រហ្មមានជ័យ គឺវត្តទួលទំពូង អ៎ នៅវត្តនៃ ស្ទឹង មានជ័យ ដូចជាខ្ញុំបានជម្រាបហើយ។ ខ្ញុំសូមជ្រាបប៉ុណ្ណឹង ជម្រាបថែមទៀត។

**ស៖** សូមអរគុណលោក។ តើក្រុមគ្រួសាររបស់គាត់ត្រូវជម្លៀសខ្លួនចេញទីក្រុងភ្នំពេញដែរឬ ទេ? ដើម្បីធានាដល់សុវត្ថិភាពរបស់ក្រុមគ្រួសារគាត់?

**ឆ៖** ពេលនោះតាមខ្ញុំចាំមិនទាន់ជម្លៀសចេញទេ ប៉ុន្តែមិនទាន់ឃើញមានបញ្ហាអី។ ហើយដល់ ក្រោយមកទៀតបានជម្លៀសចេញទៅ។ នេះជម្លៀសទៅពេលណា ខ្ញុំមិនដឹងទេ ពីព្រោះខ្ញុំឈប់ទាក់ទង ហើយ ខ្ញុំមិនប៉ានទាក់ទងទៀតទេ។

[១៥:០៨:២៨]

**ស៖** សូមអរគុណលោក។ មុននេះលោកបានមានប្រសាសន៍ បានឆ្លើយទៅនឹងសំណួររបស់ខ្ញុំ ថា លោកបានទៅប្រទេសវៀតណាមជាមួយនឹងមនុស្សមួយចំនួនទៀត។ តើការធ្វើដំណើរនោះសម្រាប់ ការបណ្តុះបណ្តាលនយោបាយ ឬក៏ការបណ្តុះបណ្តាលផ្នែកយោធា?

**ឆ៖** តាមខ្ញុំចាំទៅរៀនខាងបក្ស គឺខាងនយោបាយ មិនមែនខាងយោធាទេ។

**ស៖** នៅពេលដែលលោកស្នាក់នៅវៀតណាមរយៈពេលពីរឆ្នាំ ពីឆ្នាំ១៩៥១ ដល់១៩៥៣ ជា មួយមនុស្សមួយចំនួនទៀត។

**ឆ៖** បាទ, មិនមែនពី៥១ ទេ ខ្ញុំទៅ៥៣ហើយ ចុង៥៣ហើយ។ ៥១, ៥២ ខ្ញុំធ្វើដំណើរទៅ ហើយ អ៎! ៥១, ៥២ ធ្វើដំណើរទៅនៅហើយ ប៉ុន្តែដល់៥៣ បានរៀនអីហ្នឹង។

[១៥:១០:០០]

**ស៖** តើលោកបានរស់នៅប្រទេសវៀតណាមអស់រយៈពេលប៉ុន្មាន សម្រាប់ការបណ្តុះបណ្តាលផ្នែកនយោបាយនេះ?

**ឆ៖** តាមខ្ញុំចាំ ប្រហែលមួយឆ្នាំជាង។ ប៉ុន្តែ រៀនផងឈប់ផង ហើយពេលនោះនៅវៀតណាម គេកំពុងធ្វើចលនាបដិរូបដីស្រែ។ ហេតុដូច្នោះ រៀនផងហើយទៅមើលគេធ្វើបដិរូបដីស្រែផង។ គេធ្វើយ៉ាងម៉េចតែប៉ុណ្ណឹងទេ ហើយទៅទស្សនកិច្ចមើល រៀនផងឈប់ផង។ ទៅទស្សនៈ មើលសម្រាកផងអីផង មិនមែនរៀនជាប់ទេ។

[១៥:១១:១២]

**ស៖** លោកបានទទួលការបណ្តុះបណ្តាលផ្នែកយោធាក្នុងដំណាក់កាលខ្លះ ដោយសារថាលោកក្លាយទៅជាថ្នាក់ដឹកនាំជាន់ខ្ពស់ក្នុងបក្សកុម្មុយនីស្តកម្ពុជា ទទួលបន្ទុកទៅលើផ្នែកយោធា តើលោកបានទទួលការបណ្តុះបណ្តាលផ្នែកយោធានេះនៅពេលណាដែរ?

**ឆ៖** ខ្ញុំសូមជម្រាបថា សេចក្តីរាយការណ៍នេះខុសទេ។ ខ្ញុំមិនដែលរៀនខាងយោធាទេ ប៉ុន្តែខ្ញុំឃើញក្នុងសេចក្តីដែលលោកព្រះរាជអាជ្ញានិយាយណ៎ា ថាខ្ញុំខាងយោធា អត់ទេ ខ្ញុំមិនដែលរៀនយោធាទេ ហើយខ្ញុំក៏មិនសូមយល់ខាងយោធាផង។

**ស៖** ក្រោយពីសន្និសីទទីក្រុងហ្សឺណែវ លោកបានរៀបរាប់ថា ប្រទេសកម្ពុជាស្ថិតនៅក្នុងភាពចលាចល តើវាស្ថិតនៅក្នុងអំឡុងពេលដែលចលនា កុម្មុយនីស្តនៅតាមមូលដ្ឋានកំពុងតែមានភាពខ្លាំងក្លាឡើង ដោយសារថាមិនមានវត្តមានវៀតណាម ឬក៏ថា វៀតណាមមិនអនុញ្ញាតឲ្យកម្ពុជា ចូលរួមនៅក្នុងសន្និសីទទីក្រុងហ្សឺណែវទេ?

[១៥:១៣:០៤]

**ឆ៖** តាមខ្ញុំចាំ ក្រោយកិច្ចព្រមព្រៀងហ្សឺណែវ ចលនាមិនក្តៀវក្លាទេ។ គឺទ្រុឌទ្រោមអស់ស្ទើរវលាយ ដូចជាខ្ញុំបានជម្រាបហើយ គឺថា មួយកិច្ចព្រមព្រៀងហ្សឺណែវ ស្តីអំពីបញ្ហាកម្ពុជា គឺឲ្យរំសាយកម្លាំងប្រដាប់អាវុធឲ្យអស់ ហើយឲ្យអ្នកតស៊ូទៅចូលរួមរស់នៅក្នុងសង្គមជាតិ គឺក្រោមការគ្រប់គ្រងរបស់រាជរដ្ឋាភិបាលពេលនោះ។ ប៉ុន្តែវាមានបានសុខឯណា ព្រោះត្រូវគេចោទប្រកាន់ថា ជាខ្មែរវៀតមិញ។ ដូច្នោះ ត្រូវចាប់ ត្រូវចង ត្រូវបង្ក្រាប ត្រូវសម្លាប់ ជាពិសេសនៅពេលបោះឆ្នោតសាកល សង្គមរាស្ត្រនិយមនោះ។ អ្នកខ្លះ ត្រូវគេចាក់ភ្នែក ត្រូវអីៗ ដូច្នោះប្រជាជនខ្លះទាល់តែលក់ស្រែ លក់ចម្ការយក

លុយទៅលោះប្ដីអីៗមក។ ដូច្នោះគ្មានសេចក្ដីសុខអីទេ ក្រោយកិច្ចព្រមព្រៀងហ្សឺណែវនោះ វាលំបាកវេទនាគេចព្រៃ ពួកអ្នកដែលធ្លាប់ដឹកនាំចូលព្រៃទាំងអស់ នៅពួនព្រៃ ដូចជានៅនិរតី នៅពាយព្យ នៅណាៗច្រើនកន្លែងណាស់ រត់ ខ្ចាត់ខ្ចាយអស់ ដូចជាខ្ញុំជម្រាបអ៊ីចឹង គឺនៅសល់តែពីរសាខាទេ ហើយសាខានេះលួចលាក់ទៀតផង។ សល់តែពីរសាខា សល់តែឈ្មោះទេ គ្មានប្រជុំ គ្មានរៀនសូត្រអីទេ គឺសាខាត្រាំកក់នេះមួយ ហើយនិងសាខាភូមិពាមនេះមួយ នៅសល់តែប៉ុណ្ណឹង ក្រៅពីហ្នឹងអស់រលីង គ្មានសល់ទេ។

[១៥:១៥:៥១]

**ស៖** តើបក្សពលករកម្ពុជាមានបានឃើញថា ត្រូវតែមានតម្រូវការដើម្បីបង្កើតអង្គភាពសម្ងាត់ដើម្បីការពារទៅដល់កម្មាភិបាល និងសកម្មជននយោបាយរបស់ខ្លួន ក៏ដូចជាដើម្បីវាយប្រហារទៅលើខ្មាំងដែរឬទេ?

**ឆ៖** តាមខ្ញុំចាំ ពេលដំបូងមិនមានទេ អត់មានទេ។ មានតែគេច មានតែរត់ ប៉ុន្តែដល់គេធ្វើខ្លាំងពេក វាមានចលនាបះបោរនៅសំឡូត ថ្ងៃទីប៉ុន្មានទេ ខ្ញុំភ្លេចទៅហើយ។ ដូចជាមករា កុម្ភៈ មានការបះបោរនៅសំឡូត ពីព្រោះគ្រាន់តែមើលកាសែតក៏គេចាប់ គ្រាន់តែទាក់ទងនិយាយគ្នានៅក្នុង ជាពិសេសនៅមូលដ្ឋានចាស់ហ្នឹងក៏ប៉ូលិស គិញសម្ងាត់របស់ លន់ នល់ តាមចាប់ តាមចង ធ្វើបាប កាប់សម្លាប់ចលនាចេះតែក្ដៅឡើងៗៗៗ វាផុសមានការតស៊ូនៅសំឡូតនេះ។ នេះមូលហេតុដើមវាអ៊ីចឹង។ ខ្លះរត់ទៅគេចទៅនៅភ្នំ ទៅនៅអីទៅ។ ការពិតវាមានអ៊ីចឹង។

អត់ទោស ខ្ញុំហត់ណាស់។

[១៥:១៩:៥៤]

**ប្រធានអង្គជំនុំ៖**

បាទ, ឥឡូវនេះដោយសារជនជាប់ចោទបានបង្ហាញនូវការប្រឹងប្រែងនៅក្នុងការឆ្លើយតបទៅនឹងសំណួរ តាំងពីព្រឹកមកដែរ ហើយនៅពេលនេះ ដោយសារវ័យចាស់ដែលគាត់បង្ហាញនូវភាពហត់ ដើម្បីឲ្យគាត់មានឱកាសសម្រាក និងអាចឆ្លើយនឹងសំណួរនៅថ្ងៃស្អែកបានល្អ។ អង្គជំនុំជម្រះទទួលសំណូមពរនេះ ហើយប្រកាសផ្អាកនូវកិច្ចដំណើរការសវនាការដេញដោលសួរចម្លើយជនជាប់ចោទសម្រាប់ថ្ងៃដំបូងនេះត្រឹមនេះ។ ហើយអង្គជំនុំជម្រះប្រកាសថា សវនាការនឹងលើកបន្តទៅថ្ងៃស្អែក ថ្ងៃអង្គារ ទី៦ ខែធ្នូ ឆ្នាំ២០១១ ដោយចាប់ផ្ដើមពីម៉ោងប្រាំបួនព្រឹកទៅ សូមភាគី និងសាធារណជនជ្រាប និងសូម

អញ្ជើញចូលរួមនៅក្នុងសវនាការឲ្យបានមុនពេលម៉ោងប្រាំបួនព្រឹកជាកំណត់។

ហើយអនុរក្សមន្ទីរឃុំឃាំងនាំខ្លួនជនជាប់ចោទទាំងបីរូប ត្រឡប់ទៅកាន់មន្ទីរឃុំឃាំងវិញចុះ ហើយឲ្យនាំខ្លួនគាត់ត្រឡប់មកកាន់បន្ទប់សវនាការនេះវិញ នៅព្រឹកថ្ងៃស្អែកឲ្យបានមុនម៉ោងប្រាំបួនជាកំណត់៕

សូមសម្រាកចុះ!

*(សវនាការផ្អាកនៅម៉ោង ១៥:២១ នាទី)*